ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

# ការព្យាករណ៍ទីផ្សារកម្លាំងពលកម្មនៅកម្ពុជា ឆ្នាំ២០១៧-២០២៧

គម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ADB/AFD Loan No.3167/8305-CAM

ឆ្នាំ២០២០

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បី **កំណើន ការងារ សមធម៌** និង**ប្រសិទ្ធភាព** ក្នុងការកសាងមូលដ្ឋានឆ្ពោះទៅកាន់ការសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ និងឆ្នាំ២០៥០ ដោយបានផ្តល់អាទិភាពខ្ពស់ជាងគេបំផុតលើការអភិវឌ្ឍធនធានមនុស្សប្រកបដោយ ចំណេះដឹង សមត្ថភាព ជំនាញ សីលធម៌វិជ្ជាជីវៈ និងផលិតភាពការងារខ្ពស់។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំខាន់ៗជាច្រើន ពិសេសបានដាក់ឱ្យអនុវត្តនូវ **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥** និង**គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥**។

ដើម្បីចូលរួមគាំទ្រយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញនូវ**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣** ដោយនៅក្នុងយុទ្ធសាស្ត្រទី២ គឺបានកំណត់អំពី **"ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ"**។ ជាក់ស្តែង អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈគម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាវិជ្ជាជីវៈ (TVETSDP/ADB Loan No. 3167-CAM (COL) & AFD Loan No. 8305-CAM (AFD) បាននិងកំពុងដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រ និងអនុវត្តនូវផែនការសកម្មភាពរបស់គោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រខាងលើនេះ ដែលមានគោលបំណងបួន គឺ ១)បង្កើនការទទួលបានកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២)កែលម្អគុណភាព និងភាពឆ្លើយតបនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ៣)បង្កើនការចូលរួមរបស់និយោជកក្នុងការផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និង ៤)ពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ នៅក្នុងនោះ គម្រោងបានសិក្សាអំពីការព្យាករណ៍ទីផ្សារកម្លាំងពលកម្មនៅកម្ពុជា ដែលមានចំណុចសំខាន់ដូចខាងក្រោម៖

- ការវិភាគ និងផ្សព្វផ្សាយពីតម្រូវការកម្លាំងពលកម្ម (ជំនាញ) លើទីផ្សារការងារ
- វិស័យអាទិភាពដែលកំពុងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម នៅកម្ពុជា
- ការផ្គូផ្គងរវាងអ្នកមានតម្រូវការ និងអ្នកផ្តល់ការបណ្តុះបណ្តាល (គម្លាតជំនាញ)។

អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា សៀវភៅស្តីពី **"ការព្យាករណ៍ទីផ្សារកម្លាំងពលកម្មនៅកម្ពុជា ឆ្នាំ២០១៧-២០២៧"** នឹងផ្តល់ជាទស្សនាទាន និងវិធីសាស្ត្រក្នុងការវិភាគ និងព្យាករណ៍ពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មដែលស្ថាប័នពាក់ព័ន្ធអាចយកទៅប្រើប្រាស់ដើម្បីអនុវត្តលើការងារជាក់ស្តែង និងរៀបចំផែនការយុទ្ធសាស្ត្រក្នុងការពង្រឹងគុណភាព និងការប្រកួតប្រជែងនៃទីផ្សារការងារនៅកម្ពុជា។

ថ្ងៃ ចន្ទ ៩កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០

**អគ្គនាយក**

**ហ៊ីង ស៊ីដេត**

**មាតិកា**


**អក្សរកាត់** ix

**សេចក្តីសង្ខេប** x

**ផ្នែកទី១៖ ក្របខ័ណ្ឌនៃការវិភាគ** **២**

**១.១ សេចក្តីផ្តើម** **៣**

**១.២ ក្របខ័ណ្ឌនៃការវិភាគ៖ គំរូលំហូរនៃទីផ្សារការងារ** (The Analytical Framework: A Stock-flow Model of The Labor Market) **៣**

**១.៣ ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** (TVET) **និងការចូលក្នុងកម្លាំងពលកម្ម** **៥**

១.៣.១ ការកំណត់ការចេញពីប្រព័ន្ធ TVET ៥

១.៣.២ ចំនួននៃកំណើន (Number of Births) ៦

១.៣.៣ ចំនួនប្រជាជនក្នុងវ័យបណ្តុះបណ្តាល ៧

១.៣.៤ ទិដ្ឋភាពទូទៅនៃការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអប់រំ និងប្រព័ន្ធ TVET នាពេលបច្ចុប្បន្ន ៨

១.៣.៥ ការចុះឈ្មោះចូលរៀនក្នុងសាលារៀន ១០

១.៣.៦ អត្រាចុះឈ្មោះចូលរៀន ១២

**ផ្នែកទី២៖ ការប៉ាន់ស្មានការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងលំហូរ** **១៥**

**២.១ លំហូរនៃប្រព័ន្ធអប់រំ៖ ការចូលរៀន និងការចាកចេញ** **១៥**

២១.១. ចំនួនអ្នកចាកចេញសរុប (Total Exits) ១៦

២.១.២ ចំនួនអ្នកចាកចេញពីប្រព័ន្ធអប់រំសរុបក្នុងរយៈពេលពីឆ្នាំ២០០៦ ដល់ ២០១៧ ១៧

២.១.៣ ចំនួនអ្នកចាកចេញពីប្រព័ន្ធអប់រំសរុបតាមភេទ ប្រភេទ និងឆ្នាំ ១៨

២.១.៤ ចំនួនអ្នកចាកចេញពីប្រព័ន្ធអប់រំទៅតាមកម្រិតនៃការអប់រំ ១៩

២.១.៥ ការចេញពីប្រព័ន្ធអប់រំតាមរយៈការទទួលបានកម្រិតនៃការអប់រំ ២១

**២.២ សូចនាករលំហូរ** (Flow Indicators) **២១**

២.២.១ ត្រួតថ្នាក់ ២២

២.២.២ បោះបង់ការសិក្សា ២៣

**ផ្នែកទី៣៖ ការព្យាករណ៍តម្រូវការពលកម្ម** **២៥**

**៣.១ ការវិវត្តន៍សេដ្ឋកិច្ចកម្ពុជា៖ ផលិតកម្ម ការងារ និងផលិតភាព** **២៦**

៣.១.១ ផលិតកម្មសរុប ២៦

៣.១.២ តម្លៃបន្ថែមសរុបតាមវិស័យសេដ្ឋកិច្ច ២៧

៣.១.៣ ចំណែកផលិតកម្មនៃវិស័យសំខាន់ៗ ៣០

**៣.២ មែកធាងនៃសេដ្ឋកិច្ច** (The Branches) **៣១**

៣.២.១ កសិកម្ម ៣១

៣.២.២ ឧស្សាហកម្ម ៣២

៣.២.៣ កម្មន្តសាល ៣៣

៣.២.៤ សេវាកម្ម ៣៤

**៣.៣ ការចូលរួមចំណែកនៃវិស័យសំខាន់ៗក្នុងការបង្កើនតម្លៃបន្ថែម ៣៥**

**៣.៤ ការចូលរួមចំណែកនៃមែកធាងសេដ្ឋកិច្ច ៣៦**

**ផ្នែកទី៤៖ ការវិវឌ្ឍន៍នៃពលរដ្ឋក្នុងវ័យការងារ (WAP) កម្លាំងពលកម្ម និងការងារ ៣៨**

**៤.១ ពលរដ្ឋក្នុងវ័យការងារ កម្លាំងពលកម្ម និងការងារ ៣៩**

**៤.២ តួនាទីស្ត្រីក្នុងទីផ្សារការងារ ៤៥**

**ផ្នែកទី៥៖ សេណារីយ៉ូទីផ្សារការងារ ឆ្នាំ២០១៧-២០២៧ ៥០**

**៥.១ តម្រូវការកម្លាំងពលកម្មក្នុងលក្ខខណ្ឌលំហូរ ឆ្នាំ២០១៧-២០២៧ ៥២**

៥.១.១ រចនាសម្ព័ន្ធការងារ ៥៣

៥.១.២ សេណារីយ៉ូនៃតម្រូវការកម្លាំងពលកម្ម ៥៨

**៥.២ ការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងលក្ខខណ្ឌផ្គត់ផ្គង់ និងលំហូរ ៦៧**

៥.២.១ ការព្យាករណ៍ការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងលក្ខខណ្ឌលំហូរ ៦៨

៥.២.២ សេណារីយ៉ូការផ្គត់ផ្គង់កម្លាំងពលកម្មតាមកម្រិតអប់រំ ៦៨

**ផ្នែកទី៦៖ សេណារីយ៉ូប្រាំឆ្នាំ ២០១៧-២០២២ ៧២**

**៦.១ សេចក្តីផ្តើម ៧៣**

**៦.២ តម្រូវការកម្លាំងពលកម្មតាមវិស័យ ៧៤**

៦.២.១ មុខរបរ និងជំនាញ ៧៦

៦.២.២ តម្រូវការជំនាញ និងតម្រូវការបណ្តុះបណ្តាល ៧៧

**៦.៣ ផ្នែកផ្គត់ផ្គង់៖ ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ៨២**

៦.៣.១ ការចុះឈ្មោះចូលរៀន និងវគ្គបណ្តុះបណ្តាល (C1, C2 and C3) ៨២

៦.៣.២ សិស្សដែលបញ្ចប់ការសិក្សាជំនាញ (C1, C2 and C3) ៨៥

**៦.៤ ឧត្តមសិក្សា ៨៥**

៦.៤.១ ការចុះឈ្មោះចូលរៀន ៨៥

៦.៤.២ សិស្សដែលបញ្ចប់ការសិក្សា ៨៦

**៦.៥ សិស្សបញ្ចប់ពីប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងទីផ្សារការងារ ៨៧**

**ផ្នែកទី ៧ ៖ សង្ខេប និងការផ្តល់យោបល់ពីគោលនយោបាយ ៩០**

**ឯកសារយោង ១០១**

**ឧបសម្ព័ន្ធ ១០២**

**ឧបសម្ព័ន្ធទី១៖ និន្នាការប្រជាសាស្ត្រ ១០២**

**ឧបសម្ព័ន្ធទី២៖ ការអប់រំទូទៅ ១០៩**

**ឧបសម្ព័ន្ធទី៣៖ ទីផ្សារការងារសម្រាប់ទស្សនៈរយៈពេលវែង ១១៦**

# បញ្ជីរូបភាព និងតារាង

## បញ្ជីរូបភាព


រូបភាពទី១. លំហូរតំណាងទីផ្សារការងារ ៣

រូបភាពទី២. ចំនួនកំណើតក្នុងប្រទេសកម្ពុជា ចាប់ពីឆ្នាំ ១៩៥០ ដល់២១០០(គិតជាពាន់) ៦

រូបភាពទី៣. ប្រទេសកម្ពុជា compulsory and post-compulsory school age population in thousand 1980-2010 ៨

រូបភាពទី៤. ការចុះឈ្មោះ និងប្រជាជនដែលគ្រប់អាយុបណ្តុះបណ្តាល ការបែងចែក%តាមកម្រិតនៃការអប់រំ និងក្រុមអាយុដែលត្រូវគ្នាចាប់ពីឆ្នាំ២០១៦ និង ២០១៧ ១០

រូបភាពទី៥. ប្រទេសកម្ពុជា ភាពខុសគ្នារវាង GER និង NER តាមភេទ និងកម្រិតអប់រំក្នុងឆ្នាំសិក្សា ២០១៥/១៦ និង ២០១៧/១៨ ១៣

រូបភាពទី៦. ប្រទេសកម្ពុជា ភាពខុសគ្នារវាងសិស្សប្រុស និងស្រីក្នុង GER និង NER តាមកម្រិតអប់រំក្នុងឆ្នាំសិក្សា ២០០៥/២០០៦ និង ២០១៧/២០១៨ ១៤

រូបភាពទី៧. ការចូលរៀន ការចេញពីប្រព័ន្ធអប់រំ និងសមតុល្យនៃការចុះឈ្មោះចូលរៀន (ចំនួនសរុបពីឆ្នាំសិក្សា ២០០៥/០៦ និង ២០១៦/២០១៧) ១៧

រូបភាពទី៨. សិស្សប្រុស និងស្រី ចំនួនចូលរៀនថ្មី សិស្សដែលចេញ និងសមតុល្យនៃការចុះឈ្មោះចូលរៀនចាប់ពីឆ្នាំសិក្សា ២០០៥/២០០៦ ដល់ ២០១៦/១៧ ១៨

រូបភាពទី៩. ការបោះបង់ការសិក្សា តាមភេទ និងកម្រិតនៃការអប់រំទៅតាមកម្រិត ឆ្នាំសិក្សា២០០៥/២០០៦ និង២០១៦/១៧ ២០

រូបភាពទី១០. អត្រាត្រួតថ្នាក់តាមភេទ និងអាយុ តាមឆ្នាំសិក្សា២០០៥/០៦ និង ២០១៧/១៨ ២២

រូបភាពទី១១. ការបោះបង់ការសិក្សា %តាមកម្រិត ឆ្នាំ២០០៥/០៦ និង២០១៦/១៧ %ស្ត្រីតាមកម្រិត ២៤

រូបភាពទី១២. អត្រាបោះបង់ការសិក្សាតាមកម្រិតថ្នាក់ និងភេទក្នុងឆ្នាំសិក្សា ២០០៥/០៦ និង២០១៦/១៧ (តាមភេទ) ២៤

រូបភាពទី១៣. អត្រាកំណើត ផ.ស.ស. (GDP) ពីឆ្នាំ២០០០/០១ ទៅ ២០១៦/១៧ ២៧

រូបភាពទី១៤. កសិកម្ម តម្លៃបន្ថែមដុល និងអត្រាកំណើនចាប់ពីឆ្នាំ២០០០/០១ ទៅ ២០១៦/១៧ ២៨

រូបភាពទី១៥. ឧស្សាហកម្ម តម្លៃបន្ថែមដុល អត្រាកំណើនចាប់ពីឆ្នាំ២០០០/០១ ដល់ ២០១៦/១៧ ២៩

រូបភាពទី១៦. សេវាកម្ម តម្លៃបន្ថែមដុល អត្រាកំណើនចាប់ពីឆ្នាំ២០០០/០១ ដល់ ២០១៦/១៧ ២៩

រូបភាពទី១៧. តម្លៃបន្ថែមដុលនៅថ្លៃបច្ចុប្បន្ន និងការបែងចែក%តាមវិស័យសេដ្ឋកិច្ចចម្បងចាប់ពីឆ្នាំ២០០០-២០១៧ ៣០

រូបភាពទី១៨. វិស័យកសិកម្ម សមាសភាព%នៃផលិតកម្មតាមមែកធាងសេដ្ឋកិច្ច (តម្លៃបច្ចុប្បន្ន) ពីឆ្នាំ២០០០-២០១៧ ៣១

រូបភាពទី១៩. តម្លៃឧស្សាហកម្មបន្ថែម សមាសភាព%ដោយអនុផ្នែកសំខាន់ (តម្លៃបច្ចុប្បន្ន) ឆ្នាំ២០០០-២០១៧ ៣២

រូបភាពទី២០. កម្មន្តសាល ដែលជាចំណែកមែកធាងសេដ្ឋកិច្ចសំខាន់ៗក្នុងឆ្នាំ២០០០ និង ២០១៧ ៣៣

រូបភាពទី២១. សេវាកម្ម តម្លៃបន្ថែម សមាសភាព%ដោយមែកធាងសេដ្ឋកិច្ចសំខាន់ៗ (តម្លៃបច្ចុប្បន្ន) ឆ្នាំ២០០០ និង ឆ្នាំ ២០១៧ ៣៤

រូបភាពទី២២. ការចូលរួមចំណែកក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗទាំងបីដល់កំណើន នៃតម្លៃបន្ថែមក្នុងឆ្នាំ២០០០-២០០៩, ២០០៩-២០១៧ និងពីឆ្នាំ២០១៦ ដល់ ២០១៧ ៣៥

រូបភាពទី២៣. ការផ្លាស់ប្តូរដែលរួមចំណែកពីមែកធាងសេដ្ឋកិច្ចចំនួន២១ ក្នុងចន្លោះឆ្នាំ២០០០-២០០៩ និង ២០០៩-២០១៧ ៣៧

រូបភាពទី២៤. %ចំណែកការងារនៃវិស័យសេដ្ឋកិច្ច ចាប់ពីឆ្នាំ២០០៧-២០១៧ ៤១

រូបភាពទី២៥. ការងារសរុបតាមស្ថានភាព សមាសភាព%នៅឆ្នាំ២០០៧, ២០១២ និង ២០១៧ ៤២

រូបភាពទី២៦. អត្រាមានការងារធ្វើ កំណើន%នៃក្រុមដែលមានការងារទៅតាមកម្រិតនៃការអប់រំខុសៗគ្នាចាប់ពីឆ្នាំ២០១២-២០១៧ ៤៤

រូបភាពទី២៧. អត្រានៃការងារ (អាយុ១៥-៦៤) និងដោយក្រុមអាយុសំខាន់ឆ្នាំ២០០៧ និង ២០១៧ ៤៥

រូបភាពទី២៨. %នៃស្ត្រីលើការងារសរុប និងវិស័យសេដ្ឋកិច្ចចម្បង ឆ្នាំ២០០៧ និង ២០១៧ ៤៥

រូបភាពទី២៩. ស្ត្រីដែលមានការងារធ្វើទៅតាមស្ថានភាពការងារឆ្នាំ២០០៧ និង ២១០៧ និងភាពខុសគ្នា ៤៦

រូបភាពទី៣០. %ស្ត្រីក្នុងមុខរបរនីមួយៗឆ្នាំ២០០៧ និង២០១៧ ៤៧

រូបភាពទី៣១. ការងារសម្រាប់ក្រុមដែលមានអាយុពី១៥-២៤ឆ្នាំនិងការបែងចែកតាមកម្រិតនៃការអប់រំដែលទទួលបានឆ្នាំ២០១៧ ៤៨

រូបភាពទី៣២. អត្រាការងាររបស់ស្ត្រីតាមក្រុមអាយុក្នុងឆ្នាំ២០០៧ និង ២០១៧ និងភាពខុសគ្នា ៤៩

រូបភាពទី៣៣. អត្រាការងារជាក់លាក់របស់បុរស និងស្ត្រីតាមក្រុមអាយុ និងភាពខុសគ្នាតាមភេទក្នុងឆ្នាំ២០១៧ ៤៩

រូបភាពទី៣៤. ការងារតាមកម្រិតនៃការអប់រំ (គិតជាខ្ទង់ពាន់) និង%ឆ្នាំ២០០៧, ២០១២ និង ២០១៧ ៥៤

រូបភាពទី៣៥. ចំនួនការងារតាមក្រុមអាយុសំខាន់ៗ និងសមាសភាព%តាមឆ្នាំ២០០៧, ២០១២,និង២០១៧ ៥៥

រូបភាពទី៣៦. ការងារ តាមវ័យជំនាន់ដែលចូលក្នុងការងារ និងចេញពីការងារទៅតាមក្រុមអាយុ (គិតជាខ្ទង់ពាន់) ចាប់ពីឆ្នាំ២០០៧-២០១៧ ៥៦

រូបភាពទី៣៧. ការងារ វ័យអ្នកដែលចូលក្នុងវិស័យការងារ ចេញពីវិស័យការងារ និងតុល្យភាព (គិតជាខ្ទង់ពាន់) ចាប់ពីឆ្នាំ២០០៧-២០១៧ ៥៦

រូបភាពទី៣៨. ការកើនឡើងការងារសរុបជាមធ្យមប្រចាំឆ្នាំ និងការងារក្នុងវិស័យបីសំខាន់ៗ (កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម) រវាងឆ្នាំ២០១១ និង ២០១៧ (តម្លៃគិតជាពាន់) ៦០

រូបភាពទី៣៩. ការងារតាមវិស័យសេដ្ឋកិច្ចសំខាន់ៗ តម្លៃជាក់ស្តែងសម្រាប់អំឡុងឆ្នាំ២០០៧-២០១៧ និងតម្លៃព្យាករណ៍សម្រាប់ឆ្នាំ២០១៧-២០២៧ ៦២

របភពទី៤០. ការផ្គត់ផ្គង់ពលកម្មក្នុងលក្ខខណ្ឌលំហូរ (គិតជាខ្ទង់ពាន់) ឆ្នាំ២០០៨-២០២៧ ៦៨

រូបភាពទី៤១. រចនាសម្ព័ន្ធនៃអ្នកដែលចេញពីប្រព័ន្ធអប់រំតាមកម្រិតនៃការអប់រំក្នុងឆ្នាំ២០២៧ ក្នុងជម្រើសនៃសេណារីយ៉ូទាំងពីរនៃអត្រាឆ្លងភូមិសិក្សា និងភាពខុសគ្នា ៧០

រូបភាពទី៤២. ចំនួនអ្នកដែលចូលក្នុងវ័យគ្រប់អាយុធ្វើការ និងអ្នកចេញពីប្រព័ន្ធអប់រំ (សេណារីយ៉ូទី២) (តម្លៃគិតជាខ្ទង់ពាន់) ឆ្នាំ២០១៨-២០២៧ ៧០

រូបភាពទី៤៣. ចំនួននិស្សិតដែលបញ្ចប់ការសិក្សាតាមកម្រិត និងតាមប្រភេទគ្រឹះស្ថានក្នុងឆ្នាំសិក្សា២០១៧-២០១៨ ៨៦

# តារាង


តារាងទី១. ចំនួនប្រជាជនដែលមានអាយុបណ្តុះបណ្តាលក្នុងប្រទេសកម្ពុជា តាមក្រុមអាយុ តម្លៃដាច់ខាតគិតជាខ្ទង់ពាន់ និង% ចាប់ពីឆ្នាំ១៩៨០ ដល់ ២០៥០ ៧

តារាងទី២. ប្រទេសកម្ពុជា; ចំនួនប្រជាជនដែលគ្រប់អាយុទទួលការបណ្តុះបណ្តាលទៅតាមក្រុមអាយុ បម្រែបម្រួលជា% ចាប់ពីឆ្នាំ១៩៨០ ដល់ ២០១៥ និងពីឆ្នាំ២០១៥ ដល់ ២០៥០ ៨

តារាងទី៣. ប្រទេសកម្ពុជា; ការចូលរៀន, ចំនួនប្រជាជនដែលបណ្តុះបណ្តាល និងអនុបាតរវាងការចូលរៀន និងចំនួនប្រជាជនទៅតាមអាយុ ឆ្នាំសិក្សាពី២០១៦ដល់២០១៧ និង ២០១៧ដល់២០១៨ (គិតជាពាន់) ៩

តារាងទី៤. ចំនួនចុះឈ្មោះចូលរៀនក្នុងប្រទេសកម្ពុជា គ្រប់អាយុ និងលើសអាយុចូលរៀនចាប់ពីឆ្នាំសិក្សា២០០៥/២០០៦ ដល់ឆ្នាំសិក្សា២០១៧/២០១៨ ១០

តារាងទី៥. ការចុះឈ្មោះចូលរៀនក្នុងប្រទេសកម្ពុជា ការបែងចែក%នៃសិស្សដែលលើសអាយុទៅតាមកម្រិតនៃការអប់រំ និងអត្រា%លើការចុះឈ្មោះចូលរៀនសរុបឆ្នាំ២០០៥-០៦ និង ២០១៧-១៨ ១១

តារាងទី៦. ការចុះឈ្មោះចូលរៀនក្នុងប្រទេសកម្ពុជា %នៃសិស្សស្រីដែលគ្រប់អាយុ លើសអាយុចូលរៀនឆ្នាំសិក្សា២០០៥-០៦ និង ២០១៧-១៨ ១២

តារាងទី៧. ប្រទេសកម្ពុជា អត្រារួមនៃការសិក្សា និងអត្រារួមពិតនៃការមានការងារធ្វើតាមភេទ ចាប់ពីឆ្នាំ២០០៥/២០០៦ និង ២០១៧/២០១៨ ១៣

តារាងទី៨. ការចុះឈ្មោះចូលរៀន ចាកចេញ និងភាពខុសគ្នានៃការចុះឈ្មោះតាមភេទឆ្នាំ២០០៦ និងឆ្នាំ២០១៧ ១៨

តារាងទី៩. ការចេញពីការអប់រំសរុបទៅតាមភេទ ប្រភេទ និងឆ្នាំ ចាប់ពីឆ្នាំ២០០៦ ដល់ ២០១៧ ១៩

តារាងទី១០. ការបោះបង់ការសិក្សាតាមភេទ និង%នៃសិស្សស្រីដែលចេញពីការអប់រំ ឆ្នាំសិក្សា២០០៥/០៦ និង ២០១៦/១៧ ១៩

តារាងទី១១. ការចេញពីការអប់រំសរុបទៅតាមភេទ ប្រភេទ និងឆ្នាំ ចាប់ពីឆ្នាំ២០០៦ ដល់ ២០១៧ ១៩

តារាង១២. ការចេញពីការអប់រំសរុប តាមការទទួលបានពីការអប់រំ តម្លៃដាច់ខាត និង%ចាប់ពីឆ្នាំ២០០៥ ដល់ ២០១៧ ២១

តារាងទី១៣. សិស្សត្រួតថ្នាក់តាមភេទ និងកម្រិតនៃការអប់រំ តម្លៃដាច់ខាត និងអត្រាត្រួតថ្នាក់ ២២

តារាងទី១៤. ការបោះបង់ការសិក្សាតាមភេទ និងកម្រិតនៃការអប់រំ តម្លៃដាច់ខាតគិតជាខ្ទង់ពាន់ និងអត្រាត្រួតថ្នាក់ ២៣

តារាងទី១៥. តម្លៃបន្ថែមដុលសរុប តាមវិស័យ និង ផ.ស.ស. ចាប់ពីឆ្នាំ២០០០-២០១៧ តម្លៃ២០០០ថេរ គិតជាពាន់លានរៀល ២៦

តារាងទី១៦. វិស័យសេដ្ឋកិច្ចចម្បងៗ អត្រាកំណើនជាមធ្យមចាប់ពីឆ្នាំ២០០០-២០០៧ ឆ្នាំ២០០០-២០០៩ និងឆ្នាំ២០០៩-២០១៧ ២៧

តារាងទី១៧. កសិកម្ម តម្លៃបន្ថែម អត្រាកំណើនជាមធ្យមប្រចាំឆ្នាំនៃមែកធាងសេដ្ឋកិច្ចសំខាន់ៗចាប់ពីឆ្នាំ២០០០-២០០៩ ឆ្នាំ២០០៩-២០១៧ និងពីឆ្នាំ២០០០-២០១៧ ៣១

តារាងទី១៩. កម្មន្តសាល តម្លៃបន្ថែម អត្រាប្រចាំ អត្រាកំណើនប្រចាំឆ្នាំជាមធ្យមនៃមែកធាងសេដ្ឋកិច្ចធំៗ និងវិស័យសរុប ឆ្នាំ២០០០-២០០៩, ឆ្នាំ២០០៩-២០១៧ និងឆ្នាំ២០០០-២០១៧ ៣៣

តារាងទី២០. សេវាកម្ម តម្លៃបន្ថែម អត្រាកំណើនប្រចាំឆ្នាំជាមធ្យមនៃមែកធាងសេដ្ឋកិច្ចធំៗ និងវិស័យសរុបចាប់ពីឆ្នាំ២០០០-២០០៩, ២០០៩-២០១៧ និងឆ្នាំ២០០០-២០១៧ ៣៤

តារាងទី២១. ការចូលរួមចំណែករបស់មែកធាងសេដ្ឋកិច្ចដើម្បីកំណើនសេដ្ឋកិច្ចក្នុងរយៈពេល ពីឆ្នាំ២០០០-២០០៩ និងឆ្នាំ២០០៩-២០១៧ ៣៦

តារាងទី២២. ចំនួនប្រជាជនដែលគ្រប់អាយុធ្វើការ កម្លាំងពលកម្ម និងការងារ (តម្លៃគិតជាខ្ទង់ពាន់) ចាប់ពីឆ្នាំ២០០៧-២០១៧ ៣៩

តារាងទី២៣. ចំនួនប្រជាជនដែលគ្រប់អាយុធ្វើការ កម្លាំងពលកម្ម និងការងារ តម្លៃដាច់ខាត និងបម្រែបម្រួលជា% ឆ្នាំ ២០០៧-២០១៧ និង២០១២-២០១៧ ៣៩

តារាងទី២៤. ការងារសរុប (អាយុ១៥ ដល់៦៤) តាមវិស័យសេដ្ឋកិច្ចសំខាន់ៗ តម្លៃដាច់ខាត និងសមាសភាពជា% ចាប់ពីឆ្នាំ២០០៧-២០១៧ ៤០

តារាងទី២៥. ការងារសរុប (អាយុ១៥ ដល់៦៤) តាមវិស័យសេដ្ឋកិច្ចសំខាន់ៗបម្រែបម្រួលតម្លៃដាច់ខាត និងបម្រែបម្រួលជា% ក្នុងរយៈពេលចាប់ពីឆ្នាំ ២០០៧-២០១៧ ៤០

តារាងទី២៦. ការងារសរុប (១៥ ដល់៦៤) តាមស្ថានភាព តម្លៃដាច់ខាត (គិតជាពាន់) ក្នុងឆ្នាំ២០០៧, ២០១២ និង ២០១៧ ការផ្លាស់ប្តូរដាច់ខាតរវាងឆ្នាំ២០០៧-២០១២ និង ២០១២-១៧ ៤១

តារាងទី២៧. ការងារសរុប (១៥ ដល់៦៤) តាមមុខរបរ តម្លៃដាច់ខាតនៅក្នុងសមាសភាព (គិតជាពាន់ និង%) ឆ្នាំ២០០៧, ឆ្នាំ ២០១២ និង ឆ្នាំ២០១៧ ៤២

តារាងទី២៨. ការងារសរុបតាមមុខរបរគិតជាខ្ទង់ពាន់ ការផ្លាស់ប្តូរសរុប និងជាមធ្យមប្រចាំឆ្នាំក្នុងឆ្នាំ២០០៧-២០១៧ និងឆ្នាំ២០១២-២០១៧ ៤៣

តារាងទី២៩. ការងារសរុប (១៥ ដល់៦៤) ដោយទទួលបានការអប់រំ តម្លៃដាច់ខាតនៅក្នុងសមាសភាព (គិតជាពាន់) និង% ២០០៧, ២០១២ និង ២០១៧ ៤៤

តារាងទី៣០. ការងារសរុបទៅតាមកម្រិតនៃការអប់រំ (គិតជាពាន់) បម្រែបម្រួលសរុប និងប្រចាំឆ្នាំក្នុងឆ្នាំ២០០៧-២០១៧ និង ២០១២-២០១៧ ៤៤

តារាងទី៣១. ទិន្នន័យស្រ្តីក្នុងការងារសរុបតាមមុខរបរ តម្លៃដាច់ខាតនៅក្នុងសមាសភាព (គិតជាពាន់) និង%ចាប់ពីឆ្នាំ២០០៧, ២០១៧ និងខុសគ្នា ៤៧

តារាងទី៣២. ការងារតាមភេទ និងកម្រិតនៃការអប់រំដែលទទួលបានក្នុងឆ្នាំ២០០៧ និង២០១៧ និងភាពខុសគ្នា ៤៨

តារាងទី៣៣. អត្រាមានការងារសរុបតាមភេទប្រុស ស្រី និងភាពខុសគ្នាតាមភេទក្នុងឆ្នាំ២០០៧ និង ២០១៧ ៤៨

តារាងទី៣៤. ការងារតាមកម្រិតនៃការអប់រំ និងក្រុមអាយុ ឆ្នាំ២០០៧ ២០១២ និង ២០១៧ ៥៣

តារាងទី៣៥. ការងារតាមកម្រិតនៃការអប់រំ (គិតជាខ្ទង់ពាន់) និង%ឆ្នាំ២០០៧ ២០១២ និង ២០១៧ ៥៣

តារាងទី៣៦. ចំនួនអ្នកមានការងារធ្វើតាមក្រុមអាយុ តម្លៃដាច់ខាត និងសមាសភាព% អាយុជាមធ្យម និង%នៃក្រុមអាយុ ១៥-២៤ ឆ្នាំ២០០៧, ២០១២, និងឆ្នាំ២០១៧ ៥៤

តារាងទី៣៧. ការងារ ការចូលក្នុងវិស័យការងារតាមជំនាន់គិតជាពាន់ ឆ្នាំ២០០៧-២០១៧ ៥៥

តារាងទី៣៨. ការងារ វ័យអ្នកដែលចូលក្នុងវិស័យការងារ ចេញពីវិស័យការងារ និងតុល្យភាពក្នុងឆ្នាំ២០០៧-២០១៧ និងសមាសភាពជា%ទៅតាមកម្រិតនៃការអប់រំ ៥៧

តារាងទី៣៩. ចំនួនការងារដុលសម្រាប់អ្នកដែលមានវ័យចូល និងចេញពីវិស័យការងារ និងតុល្យភាពទៅតាមកម្រិតនៃការអប់រំ ឆ្នាំ២០០៧-២០១៧ ៥៧

តារាងទី៤០. ចំនួនអ្នកមានការងារធ្វើតាមក្រុមអាយុ ប្រូបាប៊ីលីតេចំពោះអ្នកចេញពីទីផ្សារការងារសម្រាប់ក្រុមនីមួយៗក្នុងឆ្នាំ២០១៧ និងការប៉ាន់ប្រមាណចំនួនអ្នកចេញពីទីផ្សារការងារសម្រាប់អំឡុងឆ្នាំ២០១៧-២០២៧ (គិតជាខ្ទង់ពាន់) ៥៨

តារាងទី៤១. ផលិតកម្ម (គិតជាពាន់លានរៀល) ការងារ (គិតជាខ្ទង់ពាន់) និងផលិតភាពតាមវិស័យ (គិតជាដុល្លារ) តម្លៃប្រចាំឆ្នាំ (២០០៧-២០១៧) បម្រែបម្រួលដាច់ខាត និងបម្រែបម្រួលជា% ៥៩

តារាងទី៤២. អត្រាកំណើនការងារប្រចាំឆ្នាំក្នុងជម្រើសសេណារីយ៉ូទាំង៩នៃកំណើន ផ.ស.ស. និងអេឡាស្ទិកនៃប្រាក់ចំណូលការងារ និងឆ្នាំចាប់ផ្ដើមមានកំណើនការងារក្នុងសេណារីយ៉ូទាំង៩ ៦១

តារាងទី៤៣. តម្លៃបន្ថែមសរុប (គិតជាពាន់លាននៃ២០០០រៀល) ការងារ (គិតជាខ្ទង់ពាន់) និងផលិតភាព (គិតជាដុល្លារ) តម្លៃដាច់ខាតក្នុងឆ្នាំ២០១៧ ២០២៤ និង២០២៧ ព្រមទាំងបម្រែបម្រួលដាច់ខាត និងបម្រែបម្រួលជា% (២០១៧-២០២៧) ៦១

តារាងទី៤៤. ចំនួនប្រជាជនដែលមានវ័យធ្វើការ ចំនួនការងារ និងអត្រាការងារសរុបក្នុងជម្រើសសេណារីយ៉ូទីបី នៃកំណើនការងារ និងអេឡាស្ទិកក្នុងឆ្នាំ២០១៧ និង២០២៧ ៦២

តារាងទី៤៥. កម្រិតការងារសរុប និងកម្រិតការងារនៃវិស័យសំខាន់ៗទាំងបីក្នុងឆ្នាំ២០១៧ និង២០២៧ សមាសភាពជា%តាមវិស័យ តម្រូវការបន្ថែមសម្រាប់វិស័យសរុប និងសម្រាប់វិស័យនីមួយៗ ៦៣

តារាងទី៤៦. ចំនួនអ្នកដែលមានវ័យចូលធ្វើការទៅតាមកម្រិតអប់រំក្នុងឆ្នាំ២០១៨ និង២០២៧ តម្លៃដាច់ខាត និងសមាសភាពជា% ៦៤

តារាងទី៤៧. ការងារទៅតាមកម្រិតអប់រំក្នុងឆ្នាំ២០១៧ និង២០២៧ ចំនួនអ្នកដែលមានវ័យធ្វើការ និងអ្នកដែលមានវ័យចេញពីវិស័យការងារ ព្រមទាំងតម្រូវការបន្ថែមទៅតាមកម្រិតអប់រំក្នុងអំឡុងឆ្នាំ២០១៧-២០២៧ (តម្លៃគិតជាពាន់) ៦៥

តារាងទី៤៨. ការចេញពីប្រព័ន្ធអប់រំតាមកម្រិតនៃការអប់រំក្នុងសេណារីយ៉ូពីរនៃអត្រាឆ្លងភូមិសិក្សាចាប់ពីឆ្នាំ២០១៨-២០២៧ ៦៩

តារាងទី៤៩. តម្រូវការពលកម្មក្នុងលក្ខខណ្ឌលំហូរ សក្ដានុពលនៃការផ្គត់ផ្គង់តាមកម្រិតនៃការអប់រំ និងអនុបាតរវាងតម្រូវការពលកម្មក្នុងលក្ខខណ្ឌលំហូរ និងសក្ដានុពលផ្គត់ផ្គង់ (ឆ្នាំ២០១៧-២០២៧) ៧១

តារាងទី៥០. តម្រូវការជំនួស តម្រូវការបន្ថែម និងតម្រូវការពលកម្ម (ឆ្នាំ២០១៨-២០២២) ៧៣

តារាងទី៥១. តម្លៃបន្ថែមសរុប ការងារ ផលិតភាពពលកម្ម និងចំនួនប្រជាជនដែលមានវ័យត្រូវធ្វើការ និងអត្រាការងាតម្លៃដាច់ខាត បម្រែបម្រួលដាច់ខាត និងបម្រែបម្រួលជា% (ឆ្នាំ២០១៧-២០២២) ៧៤

តារាងទី៥២. កម្រិតការងារ (គិតជាខ្ទង់ពាន់) ចំណែកការងារ តម្រូវការបន្ថែម (គិតជាខ្ទង់ពាន់)តាមវិស័យ ឆ្នាំ២០១៧-២០២២ ៧៤

តារាងទី៥៣. តម្រូវការបន្ថែម តម្រូវការជំនួស តម្រូវការពលកម្ម អ្នកចូលក្នុងទីផ្សារការងារ ចលនាអន្តរវិស័យ (តម្លៃគិតជាខ្ទង់ពាន់) ឆ្នាំ២០១៧-២០២២ ៧៥

តារាងទី៥៤. អ្នកចូលក្នុងការងារតាមវិស័យ និងមកពីប្រភពដើម (តម្លៃគិតជាខ្ទង់ពាន់) ឆ្នាំ២០១៧-២០២២ ៧៦

តារាងទី៥៥. ការងារតាមមុខរបរ ឆ្នាំ២០១២, ២០១៧ និងឆ្នាំ២០២២ (គិតជាខ្ទង់ពាន់) ៧៦

តារាងទី៥៦. ការងារតាមមុខរបរ តម្រូវការបន្ថែមឆ្នាំ២០១២-២០១៧ និងឆ្នាំ២០១៧-២០២២ (គិតជាខ្ទង់ពាន់) ៧៧

តារាងទី៥៧. ចំនួនអ្នកដែលចូលក្នុងវិស័យការងារតាមមុខរបរសំខាន់ៗ តម្លៃដាច់ខាត (គិតជាពាន់) និងសមាសភាពជា% ឆ្នាំ២០១៧-២០២២ ៧៨

តារាងទី៥៨. ការចុះឈ្មោះចូលរៀនក្នុងវគ្គបណ្ដុះបណ្ដាលវិញ្ញាបនបត្រតាមភេទចាប់ពីឆ្នាំសិក្សា២០១២-២០១៣ ដល់ ឆ្នាំសិក្សា ២០១៨-២០១៩ ៨២

តារាងទី៥៩. ការចុះឈ្មោះចូលរៀនតាមភេទ និងសមាសភាពជា%តាមកម្រិតចាប់ពីឆ្នាំ២០១២-២០១៣ ដល់ឆ្នាំសិក្សា ២០១៨-២០១៩ ៨២

តារាងទី៦០. ការចុះឈ្មោះចូលរៀនក្នុងវគ្គវិញ្ញាបនបត្រ%នៃស្ត្រីចាប់ឆ្នាំសិក្សា ២០១២-២០១៣ ដល់ឆ្នាំសិក្សា ២០១៨-២០១៩ ៨៣

តារាងទី៦១. វគ្គបណ្ដុះបណ្ដាល TVET តាមជំនាញក្នុងឆ្នាំសិក្សា២០១៧-២០១៨ ៨៣

តារាងទី៦២. ការចុះឈ្មោះចូលរៀនវគ្គវិញ្ញាបនបត្រក្នុងឆ្នាំសិក្សា២០១៧-២០១៨ ៨៤

តារាងទី៦៣. ចំនួនស្ត្រីចូលរៀនតាមវគ្គ តម្លៃដាច់ខាតក្នុងឆ្នាំសិក្សា២០១៧-២០១៨ ៨៤

តារាងទី៦៤. ចំនួនសិស្សដែលបញ្ចប់វគ្គបណ្ដុះបណ្ដាលតាមភេទ និងកម្រិត តម្លៃដាច់ខាត និង ការចុះឈ្មោះចូលរៀនឆ្នាំសិក្សា ២០១៧-២០១៨ ៨៥

តារាងទី៦៥. ចំនួនចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សាក្នុង TVET តាមភេទ និងកម្រិតឆ្នាំសិក្សា២០១៧-២០១៨ ៨៥

តារាងទី៦៦. ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាតាមភេទ កម្រិតអប់រំ និងប្រភេទគ្រឹះស្ថានចាប់ពីឆ្នាំសិក្សា ២០១២/១៣ ដល់ឆ្នាំសិក្សា ២០១៧/១៨ ៨៧

# អក្សរកាត់

| | |
|---|---|
| ADB | Asian Development Bank |
| AFD | Agene Francaise de Development |
| CBR | Crude Birth Rate |
| DLMI | Department of Labour Market Information |
| EMIS | Education Management Information System |
| GVA | Gross Value Added |
| IMR | Infant Mortality Rate |
| LEB | Life Expectancy at Birth |
| MEF | Ministry of Economy and Finance |
| MLVT | Ministry of Labour and Vocational Training |
| NEA | National Employment Agency |
| NIS | National Institute of Statistics |
| TFR | Total Fertility Rate |
| TL | Team Leader |
| TVET | Technical Vocational Education and Training |
| UNDESA | United Nations Department of Economic and Social Affairs |
| WAP | Working Age Population |

# សេចក្ដីសង្ខេប

*ទិសដៅគម្រោង*

គោលបំណងសំខាន់នៃការស្រាវជ្រាវ គឺដើម្បីកំណត់ការព្យាករណ៍ដែលអនុញ្ញាតឱ្យផ្ទៀងផ្ទាត់ភាពជាប់ទាក់ទងរវាងប្រព័ន្ធអប់រំ និងប្រព័ន្ធបណ្ដុះបណ្ដាលវិជ្ជាជីវៈ ព្រមទាំងតម្រូវការជំនាញសម្រាប់ទីផ្សារការងារ។

លក្ខខណ្ឌប្រតិបត្តិ (TOR) ពិតជាត្រូវការការព្យាករណ៍រយៈពេល ៥ ឆ្នាំលើតម្រូវការ និងការផ្គត់ផ្គង់ជំនាញតាមតំបន់ តាមវិស័យឧស្សាហកម្ម និងតាមមុខរបរ។ ការស្នើសុំបែបនេះ ស្របទៅនឹងទស្សនៈរបស់អតិថិជន ដែលមិនអាចត្រូវបានឆ្លើយតបទាំងស្រុងសម្រាប់ហេតុផលមួយចំនួន ដែលសំខាន់បំផុត គឺកង្វះព័ត៌មានស្ថិតិចាំបាច់ ដើម្បីឈានដល់លទ្ធផល ហើយលទ្ធផលដែលមិនអាចទទួលបានតាមរយៈការសិក្សាឯកសារ សូម្បីតែនៅក្នុងប្រទេសមួយចំនួនដែលមានឯកសារស្ថិតិធំជាង និងសំបូរបែបក៏ដោយ។ តម្រូវការ និងការផ្គត់ផ្គង់ជំនាញអាចត្រូវបានដោះស្រាយតែជាមួយការស្ទង់មតិ ហើយលទ្ធផលនឹងមានសុពលភាពក្នុងរយៈពេលមិនលើសពីពីរទៅបីឆ្នាំទេ។

ដោយមើលឃើញពីស្ថានភាពនេះ ក្រុមការងារបានសម្រេចចិត្តប្រើវិធីសាស្ត្រថ្មីមួយដែលអនុញ្ញាតឱ្យបង្កើតតម្រូវការកម្លាំងពលកម្ម និងសេណារីយ៉ូផ្គត់ផ្គង់កម្លាំងពលកម្មតាមរយៈការសម្រេចបាននូវការអប់រំ។ ខណៈពេលដែលទិន្នន័យដែលមានសម្រាប់ធ្វើការជ្រើសយកទិន្នន័យរយៈពេល ១០ឆ្នាំនៅពេលណាដែលលទ្ធភាពនៃការសិក្សាផ្ដល់នូវតម្លៃប្រចាំឆ្នាំ។

ការសិក្សានេះរំលឹកផងដែរថា លទ្ធភាពហិរញ្ញវត្ថុរបស់គម្រោងមិនអាចគាំទ្រដល់ការប្រមូលទិន្នន័យបឋមដែលជាកិច្ចការអាចធ្វើទៅបានជាមួយនឹងគម្រោងវាស់ស្ទង់ជំនាញដែលបានរំពឹងទុករួចហើយ។ ទោះជាយ៉ាងណាលទ្ធផលនៃការស្រាវជ្រាវនេះផ្ដល់នូវបរិបទវិភាគជាទូទៅ ដែលការស្រាវជ្រាវនាពេលអនាគតលើជំនាញអាចត្រូវបានកំណត់។

*រចនាសម្ព័ន្ធនៃរបាយការណ៍*

របាយការណ៍មានបីផ្នែកៈ

- ផ្នែកទីមួយៈ បង្ហាញពីការរកឃើញសំខាន់ៗនៃសកម្មភាពស្រាវជ្រាវដែលទាក់ទងទៅនឹងការវិភាគផ្ទៃប្រវត្តិនៃនិន្នាការប្រជាសាស្ត្រ ការវិវត្តនៃប្រព័ន្ធអប់រំដែលបានកំណត់យ៉ាងទូលំទូលាយ ការវិវត្តនៃកម្រិតផលិតកម្ម និងរចនាសម្ព័ន្ធរបស់វានៅក្នុងរយៈពេលឆ្នាំ២០០៧-២០១៧ ការវិវត្តនៃទីផ្សារការងាររយៈពេលវែង និងការវិភាគជាក់លាក់នៃនិន្នាការទីផ្សារការងារក្នុងទសវត្សរ៍ចុងក្រោយនេះ។
- ផ្នែកទីពីរៈ បង្ហាញពីតម្រូវការកម្លាំងពលកម្ម និងសេណារីយ៉ូការផ្គត់ផ្គង់កម្លាំងពលកម្មទៅតាមកម្រិតនៃការអប់រំសម្រាប់រយៈពេលចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២៧។
- ផ្នែកទីបីៈ បង្ហាញពីការសង្កេតជាបន្តបន្ទាប់ដែលបង្កើតដោយសកម្មភាពស្រាវជ្រាវ ផលប៉ះពាល់សំខាន់ៗនៃការរកឃើញ ក៏ដូចជាសំណូមពរគោលនយោបាយមួយចំនួនផងដែរ។

ដើម្បីផ្ដោតលើលទ្ធផលនៃការវិភាគពីសាវតា និងសេណារីយ៉ូរមួយចំនួន របាយការណ៍នេះបានបញ្ចូលឧបសម្ព័ន្ធបីរួមមានៈ

- និន្នាការប្រជាសាស្ត្ររយៈពេលវែង។
- ការវិវត្តនៃប្រព័ន្ធអប់រំដែលបានកំណត់យ៉ាងទូលំទូលាយ។
- ការវិវត្តរយៈពេលវែងនៃរចនាសម្ព័ន្ធទីផ្សារការងារ។

ដើម្បីឱ្យលម្អិតបន្ថែមទៀត ផ្នែកទីមួយនេះត្រូវបានបែងចែកជា៦ផ្នែកដូចខាងក្រោម៖

**ផ្នែកទី១៖** បង្ហាញអំពីក្របខ័ណ្ឌដែលគាំទ្រតម្រូវការវិភាគតម្រូវការការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងលំហូរ ដើម្បីផ្ទៀងផ្ទាត់ភាពជាប់ទាក់ទងគ្នារវាង "ផលិតកម្ម" នៃប្រព័ន្ធបណ្តុះបណ្តាលក្នុងប្រទេសកម្ពុជា និងតម្រូវការទីផ្សារការងារទៅតាមកម្រិតនៃការអប់រំ។

**ផ្នែកទី២៖** ប៉ាន់ស្មានការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងលំហូរ។ ផ្នែកនេះត្រូវបានពិភាក្សាអំពីវិធីសាស្ត្រដើម្បីប៉ាន់ស្មានការចាកចេញពីប្រព័ន្ធអប់រំតាមប្រភេទនិងកម្រិតនៃការអប់រំ និងវិភាគការវិវត្តដូចជា៖

- ចំនួនការចុះឈ្មោះចូលរៀនសរុប និងសូចនាករសំខាន់ៗ (អត្រាចុះឈ្មោះចូលរៀនសរុប និងអត្រាចុះឈ្មោះចូលរៀនសុទ្ធ)។
- ការចាកចេញតាមភេទ ប្រភេទ និងកម្រិតនៃការអប់រំ ដោយវិភាគនិន្នាការនៃការរៀនត្រួតថ្នាក់ និងការបោះបង់ការសិក្សាផងដែរ។

**ផ្នែកទី៣៖** ផ្តោតទៅលើការវិភាគនៃប្រព័ន្ធផលិតកម្មនៅប្រទេសកម្ពុជា។ របាយការណ៍នេះពិភាក្សាអំពីអត្រានៃកំណើនផលិតផលក្នុងស្រុកសរុប និងតម្លៃដុលបន្ថែមតាមវិស័យនិងផ្នែកក្នុងរយៈពេលពីឆ្នាំ២០០៧-២០១៧ ក៏ដូចជាផលប៉ះពាល់នៃអត្រាកំណើនខុសគ្នាលើរចនាសម្ព័ន្ធផលិតកម្ម ការចូលរួមចំណែករបស់វិស័យនីមួយៗ និងផ្នែកនីមួយៗក្នុងកំណើនផលិតកម្ម។

**ផ្នែកទី៤៖** វិភាគអំពីការវិវត្តនៃប្រជាជនក្នុងវ័យការងារ កម្លាំងពលកម្ម និងការងារដោយបង្ហាញពីការវិវត្តនៃការងារតាមវិស័យ ស្ថានភាពការងារ តាមមុខរបរនិងកម្រិតនៃការអប់រំ ព្រមទាំងពិភាក្សាអំពីវត្តមាន បរិមាណនិងគុណភាពរបស់ស្ត្រីនៅក្នុងទីផ្សារការងារកម្ពុជា។

**ជំពូកទី២** នៃរបាយការណ៍គឺផ្តោតទៅលើបទបង្ហាញនៃវិធីសាស្ត្រដែលបានប្រើប្រាស់ដើម្បីបង្កើតសេណារីយ៉ូនៃតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងលំហូរ និងការពិភាក្សាអំពីលទ្ធផលជាក់ស្តែងដោយបែងចែកជាបីផ្នែកដូចខាងក្រោម៖

**ផ្នែកទី៥.១៖** ផ្នែកនេះបានបង្ហាញពីការប៉ាន់ប្រមាណសេណារីយ៉ូនៃតម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរសម្រាប់ឆ្នាំ២០១៧-២០២៧។ បន្ទាប់ពីធ្វើការពិភាក្សាអំពីបញ្ហាធ្ងន់ធ្ងរដែលកើតឡើងដោយកង្វះទិន្នន័យ និងព័ត៌មានដែលបានបាត់មួយចំនួន យើងបានប៉ាន់ប្រមាណនៅផ្នែកដំបូងនៃផ្នែកវិភាគការផ្លាស់ប្តូររចនាសម្ព័ន្ធការងារ រវាងឆ្នាំ២០០៧ និង២០១៧ ទាក់ទងនឹងរចនាសម្ព័ន្ធអាយុនិងការទទួលបានការអប់រំ ការប៉ាន់ប្រមាណបច្ចុប្បន្ននៃតម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរក្នុងរយៈពេលតែមួយ។ វាអនុញ្ញាតឱ្យមានការយល់ដឹងកាន់តែប្រសើរអំពីឧបករណ៍វិភាគ ហើយវាមានប្រយោជន៍ក្នុងការពន្យល់ពីវិធី ដែលបរិមាណការងារបានផ្លាស់ប្តូរតាមពេលវេលា។ ផ្នែកទីពីរនៃផ្នែកនេះផ្តោតទៅលើការបង្ហាញអំពីវិធីសាស្ត្រ ដែលបានប្រើប្រាស់ ដើម្បីកសាងសេណារីយ៉ូដោយពិភាក្សាអំពីលក្ខណៈវិនិច្ឆ័យដែលត្រូវបានជ្រើសរើស ដើម្បីជ្រើសរើសអថេរសេណារីយ៉ូពីរ (អត្រានៃកំណើនផលិតកម្មនិងភាពបត់បែននៃប្រាក់ចំណូលការងារ) បង្ហាញពីសេណារីយ៉ូជំនួសនៃតម្រូវការបន្ថែម វិភាគលើភាពជាប់ទាក់ទងរបស់ពួកគេជាមួយនឹងកំណើនប្រជាជនក្នុងវ័យការងារ។ បន្ទាប់មកធ្វើការពិភាក្សាអំពីការវិវត្តន៍ដែលអាចកើតមាននៃតម្រូវការបន្ថែមនៃវិស័យសំខាន់ៗទាំង៣ ហើយថាតើបញ្ហានេះនឹងជះឥទ្ធិពលយ៉ាងណាលើរចនាសម្ព័ន្ធការងារក្នុងរយៈពេលជប់ឆ្នាំខាងមុខ? ផ្នែកចុងក្រោយនៃផ្នែកនេះ ស្នើឱ្យមានសេណារីយ៉ូដ៏សាមញ្ញមួយអំពីការវិវឌ្ឍន៍នៃតម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរតាមកម្រិតនៃការអប់រំ។

**ផ្នែកទី៥.២** ៖ ផ្នែកនេះធ្វើការប៉ាន់ស្មានសេណារីយ៉ូនៃការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងលំហូរ និងវិភាគភាពជាប់ទាក់ទងរវាងតម្រូវការការងារដែលរំពឹងទុកនិងការផ្គត់ផ្គង់កម្លាំងពលកម្មដែលរំពឹងទុក។ ការប៉ាន់ប្រមាណនៃការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងលំហូរ គឺផ្អែកទៅលើការចាកចេញដែលរំពឹងទុកពីដំណាក់កាលបណ្តុះបណ្តាល

នៃជីវិត។ ការប៉ាន់ស្មាននៃការចាកចេញបែបនេះគឺផ្អែកលើសេណារីយ៉ូពីរដែលមានអត្រារស់រានមានជីវិតខុសគ្នា។ ទីមួយសន្មត់ថា អត្រានៃការរស់រានមានជីវិតនឹងនៅតែថេរ និងទីពីរសន្មត់ថា អត្រានៃការរស់រានមានជីវិតនឹងប្រសើរឡើងជាលំដាប់។ ម្យ៉ាងវិញទៀតផ្នែកចុងក្រោយនៃផ្នែកនេះយើងធ្វើការពិភាក្សាពីតួនាទីនៃការចាកចេញពីវិទ្យាស្ថានបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈ (TVET) និងសាកលវិទ្យាល័យ។

**ផ្នែកទី៦៖** ផ្នែកនេះផ្តោតលើរយៈពេលឆ្នាំ២០១៧-២០២២ និងផ្តល់នូវការប៉ាន់ស្មានបរិមាណនិងសូចនាករគុណភាពនៃតម្រូវការជំនាញ (តម្រូវការកម្លាំងពលកម្មដែលទាក់ទងនឹងលំហូរតាមកម្រិតនៃការអប់រំ) និងតម្រូវការនៃការបណ្តុះបណ្តាលជាក់ស្តែងដោយប្រៀបធៀបជាមួយនឹងប្រព័ន្ធ TVET។

**ជំពូកទី៣** នៃរបាយការណ៍ផ្តល់នូវការពិចារណាចុងក្រោយ និងសំណូមពរគោលនយោបាយផ្អែកលើការរកឃើញសំខាន់ៗនៃការវិភាគ។

*ការរកឃើញសំខាន់ៗ*

**ប្រជាសាស្ត្រ៖** ចន្លោះឆ្នាំ១៩៥០ និងឆ្នាំ ២០១៥ ប្រជាជនកម្ពុជាបានកើនឡើងពី ៤,៤លាននាក់ទៅ ១៥,៥លាននាក់ ហើយត្រូវបានប៉ាន់ស្មានថានឹងឈានដល់កម្រិតអតិបរិមាជិត ២៥លាននាក់នៅឆ្នាំ២០៨០។ ហើយបន្ទាប់មកនឹងថយចុះបន្តិចក្នុងរយៈពេល ២០ឆ្នាំខាងមុខ។ កំណើនប្រជាជនសរុបមានភាពស្របគ្នាជាមួយនឹងការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៃរចនាសម្ព័ន្ធអាយុ។ ពិសេសជាងនេះទៅទៀត ចំណែកនៃប្រជាជនក្នុងវ័យធ្វើការបានឡើងដល់ ៦៤.៣% ដែលធ្វើឱ្យប្រទេសកម្ពុជាមានលទ្ធភាពទទួលបានផលចំណេញពីភាគលាភប្រជាសាស្ត្រ ប្រសិនបើមានការវិនិយោគគ្រប់គ្រាន់។ អត្រានៃការមានកូននៅតែខ្ពស់ជាងកម្រិតនៃការជំនួស (កុមារ ២.៧នាក់ក្នុងស្ត្រីម្នាក់) ប៉ុន្តែចំនួនកំណើតត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះពី ៣៦៦,០០០នាក់ ទៅ ៣១៨,០០០នាក់នៅពាក់កណ្តាលសតវត្សរ៍មកនៅ ២៤០,០០០នាក់ នៅចុងសតវត្សរ៍នេះ។ ចំពោះផលប៉ះពាល់គឺថា៖

- ប្រជាជនក្នុងវ័យបណ្តុះបណ្តាល (ពីអាយុ៦ឆ្នាំ ទៅ២៤ឆ្នាំ) ត្រូវបានគេរំពឹងថានឹងមានស្ថេរភាពប្រហែល ៦.២ ទៅ ៦.៥លាននាក់រហូតដល់ពាក់កណ្តាលសតវត្សរ៍ ដោយចំនួនប្រជាជនក្នុងវ័យបណ្តុះបណ្តាលដែលមានលក្ខណៈប្រែប្រួលមានប្រមាណ ៣លាននាក់ ហើយនៅក្នុងវិស័យអប់រំដែលមិនមែនជាកាតព្វកិច្ច ប្រហែល ៣.៤លាននាក់។
- ប្រជាជនក្នុងវ័យការងារនឹងបន្តកើនឡើង ប៉ុន្តែក្នុងអត្រាធ្លាក់ចុះ ហើយប្រហែលជាឆ្នាំ២០៥០ វានឹងមានស្ថេរភាព។

**ចរន្តអប់រំ៖** ចាប់ផ្តើមពីឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាបានប្រឈមនឹងបញ្ហាក្នុងការកសាងប្រព័ន្ធអប់រំជាតិឡើងវិញ។ កិច្ចខិតខំប្រឹងប្រែងដំបូងត្រូវបានដឹកនាំជាក់ស្តែង ដើម្បីផ្តល់សាលាមត្តេយ្យ បឋម និងការអប់រំក្រៅប្រព័ន្ធ។ ហើយក្នុងរយៈពេល ៣០ឆ្នាំក្រោយ ប្រព័ន្ធអប់រំនៅកម្ពុជាទទួលបានការអភិវឌ្ឍគួរឱ្យកត់សម្គាល់។

ខណៈពេលដែលចំនួនសិស្សកើនឡើងស្ទើរតែទ្វេដង ចំនួនសាលារៀនបានកើនឡើង ២ដងកន្លះចំនួនថ្នាក់កើនឡើង ១៦៥.១% និងបុគ្គលិកកើនឡើង ២២៥.១%។

ក្នុងអំឡុងទសវត្សរ៍ទី៨០ ចំនួនសិស្សបានកើនឡើងតែក្នុងលក្ខណៈមិនសូវសំខាន់ប៉ុណ្ណោះ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់ក្នុងការកសាងសាលារៀនថ្មី និងការជួលបុគ្គលិកបន្ថែមដោយពីមុនកើនឡើង ៤៤.១% ក្រោយមកទៀត ៧២.៩%។ ក្នុងទសវត្សរ៍ទី៩០ ចំនួនសិស្សបានកើនឡើងប្រមាណ ៧៦% ដោយសារការកើនឡើងនៃចំនួនកំណើត

ដែលបានចុះឈ្មោះក្នុងទសវត្សរ៍ទី៨០។ ការផ្ទុះឡើងនៃតម្រូវការនេះត្រូវបានប្រឈមមុខ ជាពិសេសតាមរយៈការពង្រីកចំនួនថ្នាក់ (៦៣%) និងតាមរបៀបដែលតិចជាងនេះដោយការកើនឡើងចំនួនសាលារៀន (២៤.៩%) និងបុគ្គលិកបានកើនឡើង ៣១.៩%។ នៅក្នុងទសវត្សរ៍ដំបូងនៃសហស្សវត្សរ៍ថ្មីនេះ ខណៈពេលដែលអត្រានៃកំណើនចំនួនសិស្សបានធ្លាក់ចុះដល់ ១១.៨% ចំនួនសាលារៀនបានកើនឡើងជាង ៥០% ហើយចំនួនថ្នាក់រៀនកើន ២១.៣% និងចំនួនបុគ្គលិកកើន ២៩.៩%។

បច្ចុប្បន្ននេះ ចំនួនប្រជាជនតិចជាងពាក់កណ្ដាលនៃចំនួនប្រជាជនក្នុងវ័យបណ្ដុះបណ្ដាល បានចុះឈ្មោះចូលរៀននៅស្ថាប័នអប់រំបណ្ដុះបណ្ដាលមួយចំនួន ប៉ុន្តែ%គឺទាក់ទងទៅនឹងកម្រិតអប់រំទៅវិញ៖ ចាប់ពី ៩៩% នៅបឋមសិក្សាដល់២៨% នៅអនុវិទ្យាល័យហើយរហូតដល់ ៧% នៅសាកលវិទ្យាល័យដែល ២/៣ បានចុះឈ្មោះចូលរៀនបឋមសិក្សា ១៩.២% នៅអនុវិទ្យាល័យ ៩.៣% នៅមធ្យមសិក្សាទុតិយភូមិ (នេះរាប់បញ្ចូលទាំងសិស្សប្រុស និងសិស្សស្រីដែលបានចុះឈ្មោះចូលរៀននៅ C១, C២ និង C៣) ហើយមានតែប្រមាណ ៥%ប៉ុណ្ណោះ ដែលរៀននៅសាកលវិទ្យាល័យ និងការអប់រំជាន់ខ្ពស់នៅ TVET។

ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះចំនួនអ្នកចុះឈ្មោះចូលរៀនក្នុងវិស័យអប់រំ (ថ្នាក់ទី១ ដល់ថ្នាក់ទី១២) បានថយចុះបន្តិច។ មូលហេតុចម្បងនៃនិន្នាការនេះគឺការធ្លាក់ចុះចំនួនសិស្សដែលមានអាយុច្រើនក្នុងរយៈពេល ដប់ឆ្នាំចុងក្រោយនេះមានច្រើនជាងពាក់កណ្ដាល (ពី ១លាននាក់មកត្រឹមតិចជាងកន្លះលាននាក់)។ "ការធ្វើឱ្យទៀងទាត់" នៃការចុះឈ្មោះដែលទាក់ទងនឹងអាយុកំណត់ចូលរៀន បានបង្រួមជាលំដាប់នៃអត្រាចុះឈ្មោះចូលរៀនសរុប និងអត្រាចុះឈ្មោះចូលរៀនសុទ្ធ។ វាក៏ត្រូវគូសបញ្ជាក់ផងដែរថាពេលនេះវត្តមានកូនសិស្សនៅក្នុងវិស័យអប់រំគឺសិស្សស្រីច្រើនខ្ពស់ជាងសិស្សប្រុស។ នេះជាការពិតសម្រាប់ចំនួនសរុបសម្រាប់កម្រិតអប់រំទាំងអស់ (ដែលអត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់សិស្សស្រីគឺ ៦១.៦% ទល់នឹង ៥៧.៦% សម្រាប់សិស្សប្រុស)។

រចនាសម្ព័ន្ធនៃការចាកចេញតាមកម្រិតអប់រំផ្ដល់នូវវិធានដុលសរុបដំបូងនៃប្រសិទ្ធភាពនៃប្រព័ន្ធអប់រំ។ ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ ចំនួននៃការចាកចេញពីចរន្តអប់រំបានថយចុះជាលំដាប់ដោយសារការកាត់បន្ថយការចូលរៀន និងការធ្វើឱ្យទៀងទាត់នៃដំណើរការអប់រំ។ រហូតមកដល់ពេលនេះវាទាបជាង ៣០ម៉ឺននាក់ដូចដែលយើងអាចដឹងបាន ដោយផ្អែកលើចំនួនកំណើតនិងអត្រាមរណភាពរបស់កុមារ។ ទោះបីជាមានការរីកចម្រើនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ក៏ការបោះបង់ការសិក្សានៅតែតំណាងឱ្យ ៧៧%នៃការចាកចេញសរុប។ ទោះជាយ៉ាងណាក៏ដោយ វាជាវិឌ្ឍមានដែលផ្ទុយពីអតីតកាល ភាពជាប់ទាក់ទងនៃការបោះបង់ចោលនៃការសិក្សាគឺមានកម្រិតអប្បបរមានៅក្នុងការអប់រំបឋម និងអតិបរមានៅក្នុងការអប់រំជាន់ខ្ពស់។

ការវិវត្តន៍រចនាសម្ព័ន្ធនៃការចាកចេញតាមកម្រិតនៃការបញ្ចប់ការអប់រំ ខណៈពេលដែលបង្ហាញឱ្យឃើញនូវវឌ្ឍនភាពដែលសម្រេចបានដោយចរន្តអប់រំ បង្ហាញថាប្រទេសកម្ពុជានៅតែស្ថិតនៅលើផ្លូវដ៏វែងឆ្ងាយនៅឡើយ ដើម្បីផ្គត់ផ្គង់កម្លាំងពលកម្មដែលមានការអប់រំខ្ពស់ទៅក្នុងទីផ្សារការងារ។ ក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ%នៃការចាកចេញជាមួយការអប់រំនៅកម្រិតវិទ្យាល័យបានកើនឡើងពី ៨.៦% ទៅ ១៥.៦% និងកម្រិតអនុវិទ្យាល័យពី ៧.២% ទៅ ១៩.១%។ ដូច្នេះ%នៃយុវជនចាកចេញពីវិស័យអប់រំដែលមានការអប់រំជាកាតព្វកិច្ចយ៉ាងហោចណាស់បានកើនឡើងពី ១៥.៨% ទៅ ៣៤.៧%។ ទោះយ៉ាងណាក៏ដោយ ស្ទើរតែ ៣០% នៃការចាកចេញត្រូវបានតំណាងដោយសិស្សដែលមិនបានបញ្ចប់ការសិក្សាបឋម ហើយស្ទើរតែ ៣៧% មិនបានបញ្ចប់ការសិក្សានៅអនុវិទ្យាល័យ។

**ផលិតកម្ម** - ក្នុងរយៈពេលជាងបីទសវត្សរ៍កន្លងមកនេះប្រទេសកម្ពុជាទទួលបានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមគួរឱ្យកត់សម្គាល់។ វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្មជំរុញកំណើនសេដ្ឋកិច្ចដ៏គួរឱ្យចាប់អារម្មណ៍ និងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ឥឡូវនេះ គឺមានចំនួនច្រើនជាង ១៤០០ដុល្លារ ហើយបើនិយាយឱ្យចំទៅជាក់ស្តែងបានកើនឡើងទ្វេដងប្រៀបធៀបនឹងឆ្នាំ២០០០។ ហេតុផលនេះបានអនុញ្ញាតឱ្យប្រទេសកម្ពុជាផ្លាស់ប្តូរពីក្រុមប្រទេសដែលមានប្រាក់ចំណូលទាបទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។

ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៧ ផលិតផលក្នុងស្រុកសរុបបានកើនឡើងក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ៧.៧% ។ ទោះជាយ៉ាងណាក៏ដោយដំណើរការនេះនៅឆ្ងាយពីទម្រង់បែបបទ។ ក្នុងរវាងឆ្នាំ២០០០ និង ២០០៩ កំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ជាមធ្យមសម្រេចបាន ៨.៣% ដែលកើនឡើងដល់ ១៣.២% ក្នុងឆ្នាំ២០០៥។ សេដ្ឋកិច្ចកម្ពុជា រងផលប៉ះពាល់យ៉ាងខ្លាំងដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលនៅឆ្នាំ២០០៩ ផលិតផលក្នុងស្រុកសរុបនៅថេរ។ សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញយ៉ាងឆាប់រហ័សក្នុងអត្រាជាមធ្យម ៧% ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៧ ដែលជារយៈពេលមួយដែលលេចចេញជារូបរាងនៃលំយោលរង្វិលទាបបំផុត។ ការធ្លាក់ចុះនៃអត្រាកំណើន ផ.ស.ស. ដែលបានកើតឡើងបន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ចត្រូវបានដាក់បញ្ចូលទៅក្នុងវិស័យកសិកម្ម និងសេវាកម្មដែលអត្រាកំណើនជាមធ្យមបានធ្លាក់ចុះរៀងៗខ្លួនពី ៥.៣% មក ២.១% និងពី ៩.២% មក ៦.៨%។ ប៉ុន្តែផ្ទុយទៅវិញអត្រាកំណើនជាមធ្យមនៃឧស្សាហកម្មបាន កើនឡើងពី ១០.១% ទៅ ១១.២%។

អត្រាខុសគ្នានៃកំណើនតាមវិស័យសេដ្ឋកិច្ចសំខាន់ៗបានជះឥទ្ធិពលលើចំណែកផលិតកម្មរបស់ខ្លួន។ តាំងពីឆ្នាំ២០០០ វិស័យសេវាកម្មមានសារៈសំខាន់បំផុត ហើយបានរក្សាជំហរនេះរហូតមកដល់បច្ចុប្បន្ន ដែលវិស័យនេះបានកើនឡើងពី ៣៩.១%ដល់ ៤២.២%នៃតម្លៃបន្ថែមសរុបនៅឆ្នាំ២០១៧។ ក្នុងឆ្នាំ២០០០ កសិកម្មគឺជាវិស័យសំខាន់ទី២ ដែលមានចំណែក ៣៧.៨% និងធ្លាក់ចុះដល់ ២៤.៩%។ ចំណែកឧស្សាហកម្មបានកើនឡើងពី ២៣.១% ដល់ ៣២.៩%។

តាមរយៈអត្រាកំណើនជាមធ្យមនៃ ផ.ស.ស. និងផលិតកម្មសរុប យើងអាចគណនាការចូលរួមចំណែកនៃវិស័យសំខាន់ៗទាំងបី និងផ្នែកទាំង២១ក្នុងរយៈពេលពីរ គឺឆ្នាំ២០០០-២០០៩ និង ២០១០-២០១៧។ ជាការព្រួយបារម្ភនៃវិស័យសំខាន់ៗទាំងបី ការចូលរួមចំណែករបស់វិស័យកសិកម្មបានធ្លាក់ចុះពីជាង ២០% ទៅ ៧,៣%។ ឧស្សាហកម្មបានកើនឡើងពីប្រមាណ ៣៣% ទៅ ៥២.១% ខណៈពេលដែលចំណែកសេវាកម្មតែងតែខ្ពស់ជាង ៤០%។ ទិន្នន័យលើផ្នែកទាំង២១ បង្ហាញថាបច្ចុប្បន្នវាយនភណ្ឌ (៣១.៣%) សំណង់ (១០.៨%) និងពាណិជ្ជកម្ម (៩.៣%) រួមចំណែកច្រើនជាង ៥០% នៃកំណើនសេដ្ឋកិច្ចសរុប។ ចំណែកឯសេវាកម្មផ្សេងៗ ការដឹកជញ្ជូន អចលនទ្រព្យ សណ្ឋាគារ និងភោជនីយដ្ឋានរួមចំណែកជាង៣០% ប៉ុន្តែផ្នែកកសិកម្មទាំងអស់រួមទាំងដំណាំបានចូលរួមចំណែកតិចជាង ៥%។

**ទីផ្សារការងារ** - ទោះបីមានវិបត្តិឆ្នាំ២០០៩ ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៧ ការងារសរុបបានកើនឡើងក្នុងអត្រាប្រចាំឆ្នាំជាមធ្យម ២.៨% (១៩៣,០០០នាក់ក្នុងមួយឆ្នាំ)។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ កំណើនការងារប្រចាំឆ្នាំមានកម្រិតខ្ពស់បន្តិចហើយស្មើនឹង ២១៣,០០០នាក់។

នៅឆ្នាំ២០០៧ បុគ្គលិក ដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន ៥៨% និង សេវាកម្មមានចំនួន ២៧% ហើយឧស្សាហកម្មមានចំនួន ១៥%។ ការងារក្នុងវិស័យកសិកម្មបានចាប់ផ្តើមធ្លាក់ចុះក្នុងឆ្នាំ២០១២ ក្នុងអត្រាប្រចាំឆ្នាំ ១៩៣,០០០នាក់ក្នុងមួយឆ្នាំ តែភាគច្រើនត្រូវបានបំពេញដោយការកើនឡើងនៃសេវាកម្ម (១៦១,០០០នាក់) និង

ឧស្សាហកម្ម (១៧៨,០០០នាក់)។ ជាលទ្ធផលក្នុងឆ្នាំ២០១៧ ការងារក្នុងវិស័យកសិកម្មមានចំនួន ៣៧% ការងារក្នុងវិស័យសេវាកម្មមានចំនួន ៣៦.៨% ចំណែកការងារក្នុងវិស័យឧស្សាហកម្មវិញបានកើនឡើងដល់ ២៦.២%។

ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ទីផ្សារការងារនៅប្រទេសកម្ពុជាមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់។ ក្នុងឆ្នាំ២០០៧ ប្រភេទការងារច្រើនបំផុតគឺអ្នកធ្វើការឱ្យខ្លួនឯងដែលមានចំនួន ៣៨% បន្ទាប់មកបុគ្គលិកគ្រួសារដែលគ្មានបៀវត្សន៍ (៣៦%) និងនិយោជិតដែលមានបៀវត្សន៍មានចំនួនត្រឹមតែ ២៦%។ នៅឆ្នាំ២០១៧ %នៃនិយោជិតដែលមានបៀវត្សន៍មានចំនួនរហូតដល់ ៥១% អ្នកធ្វើការឱ្យខ្លួនឯងបានកើនឡើងដល់ ៤៥% រីឯបុគ្គលិកគ្រួសារដែលគ្មានបៀវត្សន៍ធ្លាក់ចុះមកត្រឹម ៤%។

ក្នុងឆ្នាំ២០០៧ ជាងពាក់កណ្តាលនៃការងារត្រូវបានចាត់ថ្នាក់ជាកម្មករកសិកម្មជំនាញ តែបានធ្លាក់ចុះមកត្រឹម ៣១% នៅក្នុងឆ្នាំ២០១៧។ ទន្ទឹមនឹងនេះ%នៃសិប្បករដែលមានចំនួនតិចជាង ១០% បានកើនឡើងទ្វេដងហើយគិតមកទល់ពេលនេះមាន ២៤% គឺជាក្រុមមុខរបរធំជាងគេទីពីរ ហើយបុគ្គលិកផ្នែកលក់ និងបុគ្គលិកសេវាកម្មបានកើនឡើងពី ១២% ទៅ ១៨%។ ទិន្នន័យស្តីពីមុខរបរក៏បញ្ជាក់ពីវត្តមាននៃកម្មករដែលគ្មានជំនាញ និងទាមទារឱ្យមានការអប់រំខ្ពស់។ គួរកត់សម្គាល់ថាបរិមាណអ្នកគ្រប់គ្រង អ្នកជំនាញ និងអ្នកបច្ចេកទេសបានធ្លាក់ចុះបន្តិចហើយនៅតែទាបជាង ៦%។ ទោះយ៉ាងណាក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ការរីកចម្រើននៃសិប្បកម្ម និងមុខរបរពាក់ព័ន្ធមានចំនួន ៥៤% សេវាកម្ម និងអ្នកលក់មានចំនួន ១៨% ស្មៀនមានចំនួន១៣% នៃកំណើនការងារ ខណៈការចូលរួមពាក់ព័ន្ធផ្សេងទៀតបានមកពីអ្នកដាំដុះ អ្នកជំនាញផ្នែកម៉ាស៊ីន និងអ្នកបច្ចេកទេស។

ទិន្នន័យស្តីពីការអប់រំបញ្ជាក់ថា ការងារនៅប្រទេសកម្ពុជានៅតែប្រឈមនឹងកង្វះខាតនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស។ នៅឆ្នាំ២០០៧ កម្លាំងពលកម្មជិត ៨២% មិនបានបញ្ចប់ការអប់រំជាកាតព្វកិច្ចទេមានតែ ៤.៦% ប៉ុណ្ណោះ ដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង ២.១% ដែលមានសញ្ញាប័ត្រឧត្តមសិក្សា។ លើសពីនេះទៅទៀត ១៨% មិនមានការអប់រំជាផ្លូវការឡើយ។ បន្ទាប់ពីរយៈពេល ១០ឆ្នាំ ស្ថានការណ៍បានប្រសើរឡើងពិតមែន ប៉ុន្តែកម្រិតអប់រំនៃកម្លាំងពលកម្មនៅទាបនៅឡើយគឺ ៧០% មិនបានបញ្ចប់ការអប់រំជាកាតព្វកិច្ចឡើយ។ អ្នកដែលមានការអប់រំខ្ពស់គឺ ៨% និង ៧% មានសញ្ញាប័ត្រក្រោយមធ្យមសិក្សា។ ជាវិជ្ជមានដែលថាក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ៣៤% នៃការងារបន្ថែមត្រូវបានស្រូបយកដោយអ្នកដែលមានការអប់រំក្រោយមធ្យមសិក្សា។ ទោះជាយ៉ាងណាក្នុងរយៈពេលដូចគ្នានេះ ក៏មានការកើនឡើងចំនួននៃការងារដែលមានការអប់រំកម្រិតក្រោមបឋម ឬបឋម។ ទីបំផុតទីផ្សារការងារនៅកម្ពុជាត្រូវបានកំណត់ដោយអត្រាការងារខ្ពស់ ដែលរហូតមកដល់ពេលនេះ គឺខ្ពស់ជាង ៨៤%។ លើសពីនេះទៅទៀតក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ ការងារត្រូវបានប្រមូលផ្តុំកាន់តែច្រើនឡើងៗនៅក្នុងក្រុមមនុស្សវ័យកណ្តាល។

នៅផ្នែកចុងក្រោយនៃរបាយការណ៍ផ្តោតទៅលើទីតាំងរបស់ស្ត្រីនៅក្នុងទីផ្សារការងារនៅកម្ពុជា។ អត្រាការងាររបស់ស្ត្រីមានកម្រិតទាបជាប្រវត្តិសាស្ត្រ ប៉ុន្តែឌីផេរ៉ង់ស្យែលមានការថយចុះ បើទោះបីជាការធ្លាក់ចុះនៃការងារនៅក្នុងវិស័យកសិកម្ម ដែលមានចំនួនភាគច្រើនជាស្ត្រីក៏ដោយ។ ជាទូទៅទិន្នន័យបង្ហាញថាមានភាពប្រសើរឡើងដោយនៅឆ្នាំ២០០៧ ស្ត្រី ៥៩% ធ្វើការក្នុងវិស័យកសិកម្ម ១៤% ក្នុងវិស័យឧស្សាហកម្ម និង ២៦% នៅក្នុងវិស័យសេវាកម្ម។ បន្ទាប់ពីដប់ឆ្នាំក្រោយមកស្ថានភាពមានការផ្លាស់ប្តូរយ៉ាងខ្លាំងបន្ទាប់ពីការផ្លាស់ប្តូរក្នុងការបែងចែកការងារសរុបតាមវិស័យ។ ស្ត្រីធ្វើការក្នុងវិស័យកសិកម្មមានចំនួន ៣៩% និង ២៥% ក្នុងវិស័យឧស្សាហកម្ម ហើយ ៣៦% ក្នុងវិស័យសេវាកម្ម។ ប្រសិនបើយើងគិតពីស្ថានភាពការងារនៅក្នុងឆ្នាំ២០០៧ មានតែស្ត្រីចំនួន ៤១.៥%

ប៉ុណ្ណោះដែលត្រូវបានផ្តល់ប្រាក់ខែ ហើយបានកើនឡើងដល់ ៥៦.៧% នៅក្នុងឆ្នាំ២០១៧ ខណៈដែលស្ត្រីដែលត្រូវបានចាត់ចូលជាអ្នកធ្វើការឱ្យខ្លួនឯងបានកើនឡើងពី ៣៩.៣% ទៅ ៤៥%។ នៅក្នុងឆ្នាំ២០១៧ មុខរបរស្ត្រីប្រមូលផ្តុំនៅក្នុងមុខរបរចំនួន៤ ដែលមានចំនួន ៩០.២% រួមមានកម្មករកសិកម្មជំនាញ (៣២.៥%) កម្មករលក់ (២៣.៥%) សិប្បករនិងកម្មករដែលពាក់ព័ន្ធ (២៣.១%) និងមុខរបរបឋម (១១.១%)។ ក្នុងឆ្នាំ២០០៧ ស្ត្រីភាគច្រើនមានតែនៅក្នុងមុខរបរពីរ (កម្មករសេវាកម្មនិងអ្នកលក់ និងកម្មករកសិកម្ម)។ នៅឆ្នាំ២០១៧ វត្តមានរបស់ស្ត្រីលើសពី ៤០% គឺជាបុគ្គលិកស្មៀន ខណៈដែលវត្តមានរបស់ស្ត្រីក្នុងមុខរបរបច្ចេកទេសបានកើនឡើងពី ២៦.៩% ទៅ ៣៦.២%។ ទោះយ៉ាងណាអ្នកគ្រប់គ្រងជាស្ត្រីមានចំនួនតិចជាងមួយភាគបួន។

កម្រិតអប់រំរបស់ស្ត្រីនៅក្នុងកម្លាំងពលកម្ម គឺនៅតែទាបជាងបុរស។ នៅក្នុងឆ្នាំ២០០៧ ស្ទើរតែ ៩៦% នៃស្ត្រីកម្ពុជានៅក្នុងកម្លាំងពលកម្មមានការអប់រំជាកាតព្វកិច្ចជាអតិបរមា ហើយបន្ទាប់ពី ១០ឆ្នាំ % នៅតែមានកម្រិតខ្ពស់គឺ ៨៧.៥% រីឯបុរសគឺមានចំនួន ៩០.២% ក្នុងឆ្នាំ២០០៧ និង ៨៣% ក្នុងឆ្នាំ២០១៧។

**សេណារីយ៉ូ៖** នៅក្នុងផ្នែកខាងក្រោមរបាយការណ៍បង្ហាញពីស្ថានភាពនៃតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងលំហូរ។

**ផ្នែកតម្រូវការ៖** តម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរធ្វើការកំណត់ចំនួនមនុស្សដែលចូលធ្វើការជាលើកដំបូងក្នុងចន្លោះពេលមួយ។ វាគឺជាផលបូកនៃសមាសធាតុពីរគឺតម្រូវការបន្ថែម និងតម្រូវការជំនួស។ ទីមួយ កំណត់ពីចំនួនការងារបន្ថែមដែលបង្កើតឡើងដោយប្រព័ន្ធសេដ្ឋកិច្ច និងទីពីរ ចំនួនមនុស្សវ័យក្មេងដែលអាចរកការងារធ្វើបានដោយសារការចាកចេញរបស់មនុស្សដែលមានការងារធ្វើពីមុន។ ការសន្មត់ជាបន្តបន្ទាប់នឹងការប្រើប្រាស់ទិន្នន័យរួមគ្នារបស់របាយការណ៍ស្ទាបស្ទង់សេដ្ឋកិច្ចសង្គមកម្ពុជា និងរបាយការណ៍សហប្រជាជាតិអនុញ្ញាតឱ្យយើងធ្វើការប៉ាន់ស្មានទិន្នន័យចាំបាច់ដើម្បីប៉ាន់ស្មានសេណារីយ៉ូនោះគឺជាចំនួនការងារតាមក្រុមអាយុ និងកម្រិតអប់រំនៅឆ្នាំ២០០៧ ២០១២ និង ២០១៧។

**ទម្រង់នៃការវិភាគ៖** ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីគំនិតនៃតម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរ និងដើម្បីបង្កើតទម្រង់ប៉ាន់ស្មានសេណារីយ៉ូ របាយការណ៍នេះនឹងបង្ហាញពីការវិភាគទីផ្សារការងារនៅកម្ពុជាទាក់ទងនឹងលំហូរសម្រាប់ឆ្នាំ២០០៧-២០១៧។ ចាប់ផ្តើមពីតម្លៃនៃបរិមាណក្នុងឆ្នាំ២០០៧ និង២០១៧ ការវិភាគបង្ហាញថាការងារ បានរងផលប៉ះពាល់ដោយការផ្លាស់ប្តូររចនាសម្ព័ន្ធគួរឱ្យកត់សម្គាល់ចំនួនពីរគឺ៖ ១) ការកើនឡើងនៃកម្រិតអប់រំ ២) ការកើនឡើងជាលំដាប់នៃអាយុជាមធ្យម។ និន្នាការទាំងនេះគឺជាលទ្ធផលនៃភាពខុសគ្នានៃបរិមាណ និងគុណភាពរវាងនិយោជិតដែលបានចាកចេញពីការងារនៅក្នុងឆ្នាំ២០០៧-២០១៧ និងអ្នកដែលបានចូលធ្វើការក្នុងពេលតែមួយ។ ចន្លោះពីឆ្នាំ២០០៧ ដល់ ឆ្នាំ២០១៧ ទីផ្សារការងារកម្ពុជាបានស្រូបយកយុវជនចំនួន ២.៦៤២លាននាក់។ ៧១.៩% (១.៩ លាននាក់) នៃការចូលរួមគឺដោយសារតែការបង្កើតការងារបន្ថែម ហើយនៅសល់ ២៨.១% (៧៤១,០០០នាក់) នៃការចាកចេញពីនិយោជិតចាស់។

ការចូលរួមចំណែកទាបនៃតម្រូវការជំនួស ត្រូវបានកំណត់ដោយអាយុមធ្យមនៃការងារដែលមានកម្រិតទាបជាការពិតណាស់ ៩២% នៃការចូលទៅក្នុងទីផ្សារការងារកើតឡើងនៅក្នុងក្រុមអាយុ ៥ឆ្នាំដំបូង (១៥ឆ្នាំ-១៩ឆ្នាំ) និងមួយទៀតនៅក្នុងក្រុមអាយុ (២០ឆ្នាំ-២៤ឆ្នាំ) ។ នៅពេលជំណាលគ្នា ពីភាគបីនៃការចាកចេញប្រមូលផ្តុំនៅក្នុងក្រុមអាយុ ៥៥ឆ្នាំ-៦៤ឆ្នាំ។

បន្ទាប់ពីកែសម្រួលលំហូរទិន្នន័យ ដើម្បីបញ្ចៀសបញ្ហារាប់ទ្វេដងដោយសារអ្នកចូលរៀនកម្រិតឧត្តមសិក្សា និងអ្នកទទួលបានសញ្ញាប័ត្រឧត្តមសិក្សាដែលមានការងារធ្វើរួច។ ការវិភាគបានបង្ហាញថាប្រហែល ២/៣ នៃប្រជាជនដែលមានការងារធ្វើមានកម្រិតអប់រំជាកាតព្វកិច្ច ឬទាបជាងនេះ ១៧.៥% មានកម្រិតអប់រំមធ្យមសិក្សាទុតិយភូមិ និងមានតែ ១៦.៦% ប៉ុណ្ណោះដែលមានកម្រិតអប់រំពីសកលវិទ្យាល័យ ខណៈដែលមនុស្សជាង ៧០% ដែលចេញពីទីផ្សារការងារមានការអប់រំទាបជាងកម្រិតការអប់រំជាកាតព្វកិច្ច។ នេះគឺជាការពន្យល់ពីមូលហេតុនិងរបៀបដែលកម្រិតនៃការអប់រំរបស់និយោជិតបានកើនឡើង។

**សេណារីយ៉ូឆ្នាំ២០១៧-២០២៧៖** របាយការណ៍ប៉ាន់ស្មានតម្រូវការជំនួសដោយការប្រើប្រូបាប៊ីលីតេនៃក្រុមអាយុខុសគ្នាដែលចេញពីទីផ្សារការងារនៅចន្លោះឆ្នាំ២០១៧ និងឆ្នាំ២០២៧។ ដើម្បីធ្វើដូច្នេះបានគេសន្មត់ថាប្រជាជនទាំងអស់ដែលមានអាយុពីវ័យ ៥៥-៦៤ឆ្នាំ នៅក្នុងឆ្នាំ២០១៧ នឹងចាកចេញពីទីផ្សារការងារក្នុងរយៈពេល ១០ឆ្នាំខាងមុខ ហើយអត្រានៃការចាកចេញសម្រាប់ក្រុមអាយុផ្សេងទៀតនឹងស្មើទៅនឹងរយៈពេលមុន។ នេះអាចឱ្យយើងធ្វើការប៉ាន់ស្មានថានឹងមានមនុស្សដែលចាកចេញពីទីផ្សារការងារចំនួន ១.០៤៥លាននាក់ ដែលជាចំនួនធំជាងកាលពីពេលមុន ដោយសារតែការកើនឡើងនៃអាយុដែលកំពុងជះឥទ្ធិពលដល់ការងារ។ ការប៉ាន់ប្រមាណនៃតម្រូវការបន្ថែមបានបង្ហាញថាមានការប្រឈមកាន់តែខ្លាំង។ ចំនួនការងារដែលនឹងត្រូវបានបង្កើតឡើងដោយសេដ្ឋកិច្ចកម្ពុជានឹងអាស្រ័យលើអត្រាកំណើនផលិតកម្មនិងអត្រានៃកំណើនផលិតភាព ដែលពីមុនពឹងផ្អែកយ៉ាងធំធេងលើបរិមាណនិងប្រភេទនៃការវិនិយោគផ្ទាល់ពីខាងក្នុងនិងបរទេស ជាពិសេសលើទិដ្ឋភាពអន្តរជាតិនៃពាណិជ្ជកម្មអន្តរជាតិ បន្ទាប់មកអាចបណ្តាលមកពីការរីកចម្រើននៃបច្ចេកវិទ្យា អ្នកមានការងារធ្វើដែលទទួលការអប់រំ និងការបណ្តុះបណ្តាល កាន់តែប្រសើរ ស្ថាប័នការងារ និងការឆ្លងកាត់រចនាសម្ព័ន្ធផលិតកម្មទៅជាក្រុមបច្ចេកវិទ្យាខ្ពស់។

ទំហំរយៈពេលដែលគ្របដណ្តប់ដោយលំហាត់បង្ហាញថា វិធីសាស្រ្តគួរឱ្យចាប់អារម្មណ៍ និងត្រឹមត្រូវបំផុតគឺការបង្កើតសេណារីយ៉ូ។ ការប៉ានស្មានជាទូទៅត្រូវបានកំណត់ចំពោះសំណុំនៃតម្លៃដែលការព្យាករណ៍គឺជាការប៉ាន់ស្មានដែលមានភ្ជាប់ប្រូបាប៊ីលីតេ។ សេណារីយ៉ូត្រូវបានបង្កើតឡើងដោយពិចារណាលើស៊េរី នៃតម្លៃជំនួសនៃគោលការណ៍ដែលពាក់ព័ន្ធ ហើយក្នុងករណីនេះគឺផលិតកម្មនិងផលិតភាព។ ក្នុងការធ្វើដូច្នេះយើងអាចធ្វើការពិភាក្សាអំពីលទ្ធផលសេដ្ឋកិច្ចសង្គមនៃផ្លូវអភិវឌ្ឍន៍ជំនួស ដើម្បីកំណត់គោលដៅគោលនយោបាយ រៀបចំ និងអនុវត្តគោលនយោបាយដែលសមស្របបំផុតដើម្បីឈានដល់គោលដៅទាំងនោះ។

ជម្រើសតម្លៃអថេរនៃសេណារីយ៉ូ (អត្រានៃការលូតលាស់នៃផលិតកម្មនិងការងារ-អេឡាស្ទិកនៃប្រាក់ចំណូល) ផ្អែកលើការវិភាគនៃតម្លៃនិងនិន្នាការពីអតីតកាល និងការចង្អុលបង្ហាញពីវិទ្យាស្ថានជាតិនានា។

ការវិភាគអំពីគុណតម្លៃពីអតីតកាល អនុញ្ញាតឱ្យយើងធ្វើការវាយតម្លៃថា៖

- ចាប់ផ្តើមពីឆ្នាំ២០១២ សេដ្ឋកិច្ចកម្ពុជាបានឈានចូលដំណាក់កាលមួយនៃការធ្លាក់ចុះយ៉ាងរហ័សនៃការងារកសិកម្មក្នុងវិស័យកសិកម្ម។ ផលិតភាពពលកម្មនៅក្នុងវិស័យឧស្សាហកម្មនៅទ្រឹងដោយសារពឹងផ្អែកខ្លាំងលើផលិតកម្មដែលមានកម្លាំងពលកម្មច្រើនដូចជាវាយនភ័ណ្ឌកាត់ដេរនិងសំណង់។
- បន្ទាប់មកគេអាចសន្មត់បានថាមានការធ្លាក់ចុះនៃការងារក្នុងវិស័យកសិកម្ម ដែលពេលបច្ចុប្បន្នកត្តាកំណត់សំខាន់គឺការកើនឡើងនូវផលិតភាពដោយការធ្វើទំនើបកម្មយ៉ាងឆាប់រហ័សនៃប្រព័ន្ធផលិតកម្ម ហើយវាយនភ័ណ្ឌកាត់ដេរនិងសំណង់នឹងត្រូវបានគាំទ្រដោយវិស័យបច្ចេកវិទ្យាខ្ពស់។

បន្ទាប់មកគេសង្កេតឃើញថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អត្រាកំណើនផលិតផលក្នុងស្រុកសរុប មានប្រមាណ ៧% ហើយនេះជាអត្រាកំណើនដែលបានព្យាករណ៍សម្រាប់ ៥ឆ្នាំខាងមុខរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយផ្អែកលើការពិចារណាពីមុនយើងពិចារណាលើតម្លៃជំនួស ៣ នៃកំណើនផលិតផលក្នុងស្រុកសរុប (៦% ៧% និង៨%) និងតម្លៃជំនួស ៣ អេឡាស្ទិកនៃប្រាក់ចំណូលការងារ (០.២% ០.២៥% និង ០.៣%)។ អត្រាលទ្ធផលការងារទាំង៩ ត្រូវបានរាប់បញ្ចូលរវាងអត្រាអប្បបរមា១.២% [អត្រាកំណើនទាបរបស់តម្លៃបន្ថែមសរុប (GVA) (៦%) និងអេឡាស្ទិកទាប (០.២%)] និងអត្រាអតិបរមា ២.៤% [អត្រាកំណើនខ្ពស់របស់តម្លៃបន្ថែមសរុប (៨%) និងអេឡាស្ទិកខ្ពស់ (០.៣%)]។ នៅក្នុងសេណារីយ៉ូកម្រិតមធ្យម [អត្រាកំណើនមធ្យមរបស់តម្លៃបន្ថែមសរុប (៧%) និងអេឡាស្ទិក (០.២៥%)] អត្រាកំណើនការងារគឺ១.៧៥%។ ការកើនឡើងដំបូងនៃកម្រិតការងារដែលត្រូវគ្នានៃសេណារីយ៉ូទាំងបីនេះគឺ ជាអប្បបរមាស្មើនឹង ១០៥,០០០នាក់ ជាអតិបរមា ២១០,០០០នាក់ ហើយជាមួយនឹងសេណារីយ៉ូកម្រិតមធ្យម ១៥៣,០០០នាក់។

យើងអាចរំពឹងថា ទិន្នន័យដែលទទួលបានជាមួយនឹងសេណារីយ៉ូកម្រិតមធ្យមឆ្លុះបញ្ចាំងពីអត្រាកំណើនជាមធ្យមដែលបានកំណត់ដោយតម្លៃបន្ថែមសរុប ការងារ និងផលិតភាពក្នុងរយៈពេលដប់ឆ្នាំកន្លងមក ខណៈសេណារីយ៉ូពីរផ្សេងទៀតមានតម្លៃរៀងៗខ្លួនទាបជាង (អប្បបរមា) និងខ្ពស់ជាង ( អតិបរមា)។ ពិសេសជាងនេះទៅទៀត ការងារសរុបត្រូវបានគេរំពឹងថានឹងកើនឡើងជាមធ្យម ១៦៦,០០០នាក់ ក្នុងមួយឆ្នាំនៅក្នុងសេណារីយ៉ូកម្រិតមធ្យម ១១១,០០០នាក់ នៅក្នុងសេណារីយ៉ូអប្បបរមា និង ២៣៥,០០០នាក់ នៅក្នុងសេណារីយ៉ូអតិបរមា។

ដោយពិចារណាលើភាពប្រទាក់គ្នានៃកំណើនការងារទាំងនេះ ជាមួយនឹងការវិវត្តន៍នៃចំនួនប្រជាជនក្នុងវ័យការងារ យើងបានសន្និដ្ឋានថា កំណើនតម្រូវការការងារទាក់ទងនឹងបរិមាណមិនអាចលើសពីសេណារីយ៉ូកម្រិតមធ្យម មានន័យថា អត្រានៃកំណើនផលិតផលក្នុងស្រុកសរុបលើសពី ៧% នឹងតម្រូវឱ្យមានអេឡាស្ទិកនៃប្រាក់ចំណូលការងារទាបជាង ០,២៥% ឬអត្រាខ្ពស់នៃការផ្លាស់ប្តូរបច្ចេកវិទ្យា។

ការព្យាករណ៍នៃតម្រូវការបន្ថែមតាមវិស័យនៅក្នុងក្របខ័ណ្ឌនៃសេណារីយ៉ូកម្រិតមធ្យមបង្ហាញថា ចំនួនអ្នកមានការងារធ្វើក្នុងវិស័យកសិកម្មនឹងធ្លាក់ចុះជាមធ្យម ១៧៨,០០០នាក់ក្នុងមួយឆ្នាំ ដែលឧស្សាហកម្មកើនឡើង ១៨៣,០០០នាក់ និងចំនួនសេវាកម្ម ១៧៨,០០០នាក់។ នេះជាផ្លាស់ប្តូររចនាសម្ព័ន្ធការងារតាមវិស័យគួរឱ្យកត់សម្គាល់ ដោយវិស័យកសិកម្មធ្លាក់ចុះដល់ ១៤% ឧស្សាហកម្មកើនឡើងដល់ ៣៩.៦% និងសេវាកម្មកើនដល់ ៤៦.៤%។ របាយការណ៍នេះគូសបញ្ជាក់ថា ការពិតតម្រូវការបន្ថែមនៃវិស័យកសិកម្មគឺ អវិជ្ជមាន មិនមានន័យថាកសិកម្មនឹងមិនស្រូបយកយុវជនទេ។ តាមពិតតម្រូវការអវិជ្ជមានរបស់វិស័យនេះ នឹងមានតុល្យភាពរវាងពលករវ័យចំណាស់ដែលនឹងចាកចេញ និងពលករវ័យក្មេងដែលនឹងទៅធ្វើការក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ដែលភាគច្រើនផ្តោតលើវិស័យសំណង់ វិស័យកាត់ដេរ និងទេសចរណ៍។ វិស័យនេះ (ដែលនឹងបន្តស្រូបយកកម្មករដែលមានកម្រិតអប់រំទាប)។ ផលប៉ះពាល់គឺថាវិស័យកសិកម្មនឹងមិនត្រឹមតែត្រូវការការបណ្តុះបណ្តាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាមទារឱ្យមានការបណ្តុះបណ្តាលកាន់តែច្រើននិងកាន់តែប្រសើរថែមទៀតផង ព្រោះការធ្លាក់ចុះចំនួនកម្មករនឹងអាចធ្វើទៅបាន លុះត្រាតែយុវជនដែលនឹងចាប់ផ្តើមធ្វើការក្នុងវិស័យនេះ មានលទ្ធភាពទទួលយកបានបច្ចេកវិទ្យាល្អប្រសើរជាងមុន ហើយមានចំណេះដឹងដើម្បីប្រើប្រាស់បច្ចេកទេសទាំងនោះ។

ដើម្បីវិភាគរចនាសម្ព័ន្ធអប់រំនៃតម្រូវការ យើងពិចារណាលើចំនួនការងារសរុបដែលជាតម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរដែលមានបរិមាណជាមធ្យមដល់ ២៧០,០០០នាក់ក្នុងមួយឆ្នាំ។ ក្នុងករណីនេះអ្វីដែលរបាយការណ៍

ផ្តល់ជូនគឺជាការព្យាករណ៍នៅក្នុងក្របខ័ណ្ឌ នៃសេណារីយ៉ូកម្រិតមធ្យមដោយផ្អែកលើនិន្នាការអតីតកាល។ របាយការណ៍នេះសន្មត់ថា ចំណែកនៃអ្នកចូលធ្វើការងារតាមជំនាន់ អ្នកដែលមានការអប់រំទាបជាង ការអប់រំជាកាតព្វកិច្ចនឹងថយចុះជាលំដាប់ក្នុងអត្រា ១.៥% ក្នុងមួយឆ្នាំ។ ហើយប្រជាជនដែលមានការអប់រំជាកាតព្វកិច្ចជាអតិបរមានឹងថយចុះជាលំដាប់ក្នុងអត្រា ០.៥% ខណៈអ្នកដែលមានវិញ្ញាបនបត្រនៃការអប់រំជាន់ខ្ពស់ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងអ្នកដែលមានសញ្ញាប័ត្រពីសកលវិទ្យាល័យ (រួមទាំងគ្រឹះស្ថាន TVET) នឹងកើនឡើងចំនួន ១% ក្នុងមួយឆ្នាំ។ នៅក្រោមការសន្មត់ទាំងនេះ ៣៤% នៃអ្នកចូលធ្វើការងារតាមជំនាន់ គឺជាអ្នកដែលមានការអប់រំទាបជាងកម្រិតអប់រំជាកាតព្វកិច្ច និង ២៣% កម្រិតអប់រំអនុវិទ្យាល័យ ហើយយ៉ាងហោចណាស់ ២៣% ទៀតកម្រិតវិទ្យាល័យ។ ដោយសារកម្រិតអប់រំជាមធ្យមនៃការចាកចេញតាមជំនាន់នឹងទាបជាងគួរឱ្យកត់សម្គាល់ កម្រិតអប់រំរបស់អ្នកមានការងារនឹងកើនឡើងក្នុងរយៈពេលនៃសេណារីយ៉ូ ប៉ុន្តែការកើនឡើងនឹងមិនគួរឱ្យកត់សម្គាល់ទេ។ ចំណែកអ្នកដែលមានការអប់រំទាបជាងការអប់រំជាកាតព្វកិច្ចនឹងនៅតែខ្ពស់រហូតដល់ ៥៩% ប៉ុន្តែចំណែកអ្នកដែលមានការងារធ្វើដែលមានការអប់រំយ៉ាងហោចណាស់កម្រិតមធ្យមសិក្សា រំពឹងថានឹងកើនឡើងពី ៨.២% ទៅ ១២.៤%។

**ផ្នែកផ្គត់ផ្គង់៖** នៅក្នុងពេលវេលាណាមួយ ការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងបរិមាណ គឺជាផលបូកនៃអ្នកមានការងារនិងអ្នកគ្មានការងារធ្វើ។ ពលរដ្ឋក្នុងវ័យការងារ (WAP) តំណាងឱ្យដែនកំណត់ខាងលើនៃការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងបរិមាណ។ នៅក្នុងឆ្នាំ២០១៧ ពលរដ្ឋក្នុងវ័យការងាររបស់ប្រទេសកម្ពុជាមានចំនួនប្រមាណ ១០.៤១៦លាននាក់ និងការផ្គត់ផ្គង់កម្លាំងពលកម្មមានចំនួន ៨.៧៧៩លាននាក់។ ដូច្នេះ ៨៤.៣% នៃប្រជាជនក្នុងវ័យធ្វើការកំពុងធ្វើការ ឬមានឆន្ទៈធ្វើការ។ ដោយសារអត្រានៃភាពអត់ការងារធ្វើស្ថិតនៅក្រោមអត្រា ១% អត្រាសកម្មភាពខ្ពស់បែបនេះបង្ហាញពីស្ថានភាពសេដ្ឋកិច្ចសង្គម ដែលមានតែយុវជនមួយចំនួនតូចប៉ុណ្ណោះដែលអាចមានលទ្ធភាពទៅរៀននៅវិទ្យាល័យនិងសកលវិទ្យាល័យ ហើយដែលប្រជាជនភាគច្រើនរស់នៅតាមជនបទ តំបន់ដែលស្ថិតនៃការស្ទង់មតិ មានការពិបាកខ្លាំងណាស់ (បើអាចធ្វើបាន) ដើម្បីបែងចែករវាងអ្នកមានការងារ អ្នកគ្មានការងារ និងអ្នកគ្មានការងារធ្វើដោយបិទបាំង។

ការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងលំហូរត្រូវបានផ្តល់ឱ្យដោយចំនួនមនុស្ស ដែលបានចូលទៅក្នុងកម្លាំងពលកម្មក្នុងចន្លោះពេលណាមួយ។ ក្នុងករណីនេះដែនកំណត់ខាងលើត្រូវបានតំណាងដោយចំនួនមនុស្សវ័យក្មេងដែលចូលជាពលរដ្ឋក្នុងវ័យការងារ។ ក្នុងការប្រៀបធៀបជាមួយអ្វីដែលយើងទើបតែបាននិយាយសម្រាប់ការផ្គត់ផ្គង់កម្លាំងពលកម្មទាក់ទងនឹងបរិមាណ យើងអាចចាំបានថារវាងឆ្នាំ២០០៧ និងឆ្នាំ២០១៧ មានចំនួនមនុស្ស ២.៦៤២លាននាក់ចូលទៅក្នុងកម្លាំងពលកម្ម ហើយចំនួនពលរដ្ឋក្នុងវ័យការងារមានដល់ទៅ ៣.២៣៣លាននាក់ ដែលត្រូវនឹងអត្រា ៨២.៣% នៃសកម្មភាពទាក់ទងនឹងលំហូរ។

**ការព្យាករណ៍ការផ្គត់ផ្គង់ពលកម្ម៖** យោងទៅតាមការប៉ាន់ស្មានចំនួនប្រជាជនរបស់អង្គការសហប្រជាជាតិ រវាងឆ្នាំ២០១៧ និងឆ្នាំ២០២៧ នឹងមានពលរដ្ឋក្នុងវ័យការងារចំនួន ៣.២លាននាក់។ សន្មត់ថាទំនោរចូលទៅក្នុងទីផ្សារការងារនៅតែថេរ យើងអាចប៉ាន់ស្មានថានឹងមានចំនួនមនុស្ស ២.៦៣៤លាននាក់ ចូលទៅក្នុងទីផ្សារកម្លាំងពលកម្ម។

ដើម្បីរក្សាចេនាសម្ព័ន្ធនៃជាតុចូលទៅក្នុងកម្លាំងពលកម្មតាមកម្រិតអប់រំ យើងធ្វើការបង្ហាញពីការព្យាករណ៍ពីរនៃការចាកចេញពីប្រព័ន្ធអប់រំនិងប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើការសន្មត់ដូចខាងក្រោម៖ ១) អត្រាជាក់លាក់នៃការរស់រានមានជីវិតនៅតែថេរនៅកម្រិតនៃឆ្នាំសិក្សា ២០១៦-២០១៧។ ២) ជាក់ស្តែងអត្រានៃការរស់រានមានជីវិតនឹងកាន់តែប្រសើរឡើងជាលំដាប់។

ដូចដែលត្រូវបានគេរំពឹងថា កម្រិតអប់រំនៃអ្នកបញ្ចប់ការសិក្សាមានភាពប្រសើរឡើងបន្ថែមទៀតនៅក្នុងសេណារីយ៉ូទីពីរ ជាងនៅក្នុងសេណារីយ៉ូដំបូង ខណៈដែលក្នុងឆ្នាំ២០១៧ និស្សិត ៦០% ដែលចេញពីប្រព័ន្ធសាលារៀនមិនទាន់បញ្ចប់ការអប់រំជាកាតព្វកិច្ច ហើយ ៤០% មានការអប់រំជាកាតព្វកិច្ចតិច ដោយប៉ាន់ស្មានអត្រា ៥០% និង ៥០% នៅក្នុងសេណារីយ៉ូទីមួយ ៤០% និង ៦០% នៅក្នុងសេណារីយ៉ូទីពីរ។ គួរឱ្យចាប់អារម្មណ៍នៅចុងបញ្ចប់នៃរយៈពេល និស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យអាចឈានដល់អត្រា ២០%។

ការប្រៀបធៀបរវាងការចាកចេញពីដំណាក់កាលបណ្តុះបណ្តាលនៃជីវិត (សេណារីយ៉ូទីពីរ) និងតម្រូវការទីផ្សារការងារ (សេណារីយ៉ូកម្រិតមធ្យម) តាមកម្រិតអប់រំសម្រាប់អំឡុងឆ្នាំ២០១៧-២០២៧ បង្ហាញថា ការចាកចេញពីប្រព័ន្ធសាលា គឺសមស្របនឹងតម្រូវការនៃទីផ្សារការងារ ដោយចំនួនតែមួយគត់ដែលលើស គឺអ្នកដែលមានកម្រិតនៃការអប់រំទាបបំផុតដែលជាទូទៅត្រូវបានកំណត់ដោយទំនោរទាប ដើម្បីចូលក្នុងទីផ្សារការងារ។

**តម្រូវការជំនាញនិងតម្រូវការបណ្តុះបណ្តាលឆ្នាំ២០១៧-២០២២៖** ដើម្បីបំពេញនូវតម្រូវការរបស់លក្ខខណ្ឌការងារ យើងបានធ្វើការព្យាករណ៍តម្រូវការកម្លាំងពលកម្មតាមមុខរបរសម្រាប់រយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៧-២០២២ និងតម្រូវការបណ្តុះបណ្តាល។ ហើយធ្វើការប្រៀបធៀបជាមួយនឹងសកម្មភាពបណ្តុះបណ្តាលរបស់ TVET នៅឆ្នាំចុងក្រោយដែលមានព័ត៌មានស្ថិតិ។

**ផ្នែកតម្រូវការ៖** កំណើនការងារសរុបដែលត្រូវបានប៉ាន់ប្រមាណមានចំនួន ៧៩៥,០០០នាក់ គឺជាលទ្ធផលនៃការធ្លាក់ចុះចំនួនការងារក្នុងវិស័យកសិកម្ម ៨០៨,០០០នាក់ និងការកើនឡើងក្នុងវិស័យឧស្សាហកម្ម ៨៥០,០០០នាក់ និងសេវាកម្ម ៧៥៣,០០០នាក់។ នៅពេលដែលតម្រូវការជំនួស និងការផ្ទេរពីកសិកម្មទៅវិស័យសំខាន់ពីរផ្សេងទៀតត្រូវបានគេយកមកពិចារណានោះ គឺការចូលក្នុងទីផ្សារការងារក្នុងវិស័យកសិកម្មត្រូវបានប៉ាន់ប្រមាណស្មើនឹង ៤០,០០០នាក់ និងឧស្សាហកម្មរហូតដល់ ១៩៦,០០០នាក់ (១១៣,០០០នាក់ ចូលដំបូង និងការផ្ទេរពីកសិកម្ម ៨៣,០០០នាក់) និងក្នុងវិស័យសេវាកម្ម ១៨៨,០០០នាក់ (១០៩,០០០នាក់ ចូលដំបូង និងការផ្ទេរពីកសិកម្ម ៧៩,០០០នាក់)។

ការវិភាគតម្រូវការការងារតាមមុខរបរសំខាន់ៗអនុញ្ញាតឱ្យបង្ហាញរូបភាពជាមូលដ្ឋាននៃតម្រូវការជំនាញ និងតម្រូវការបណ្តុះបណ្តាល។ ក្នុងរបាយការណ៍យើងបានប៉ាន់ប្រមាណថាក្នុងចំណោមមនុស្ស ៤៩០,០០០នាក់ជាមធ្យមប្រចាំឆ្នាំដែលចូលធ្វើការងារនៅក្នុងវិស័យធំៗចំនួន៣ ដែលប្រមាណ ៣/៤ នឹងស្ថិតនៅក្នុងក្រុមអាជីពធំៗចំនួន៣ ដោយសិប្បកម្មនិងកម្មករ ដែលពាក់ព័ន្ធដើរតួយ៉ាងសំខាន់ (៥៧%) បន្ទាប់មកគឺកម្មករសេវាកម្មនិងអ្នកលក់ (១៤%) និងកម្មករគាំទ្រស្មៀន (១៣%)។ តួនាទីតូចតាចប៉ុន្តែមានលក្ខណៈគុណភាព និងត្រូវបានបំពេញដោយប្រតិបត្តិកររោងចក្រ និងម៉ាស៊ីន អ្នកជំនាញ និងអ្នកបច្ចេកទេស។

ការប្រើប្រាស់រួមបញ្ចូលគ្នានៃប្រភពផ្សេងៗគ្នារួមទាំងសន្ទស្សន៍ការងាររបស់ភ្នាក់ងារមុខរបរជាតិ អាចឱ្យយើងផ្តល់នូវការប៉ាន់ស្មានបរិមាណនៃតម្រូវការទាក់ទងនឹងលំហូរសម្រាប់មុខរបរតែមួយ និងការចង្អុលបង្ហាញពីមុខរបរដែលមានលក្ខណៈដោយកង្វះការផ្គត់ផ្គង់។ ការស្រាវជ្រាវបានចង្អុលបង្ហាញពីតួនាទីសំខាន់ដែលនឹងត្រូវបានបំពេញដោយមុខរបរតែមួយនៃវិស័យសំណង់ វិស័យកាត់ដេរ កន្លែងស្នាក់នៅនិងភោជនីយដ្ឋាន និងដោយវិស័យពាណិជ្ជកម្មលក់រាយ ប៉ុន្តែក៏មានមុខរបរសំខាន់ៗដែលទាមទារឱ្យមានការអប់រំកម្រិតវិទ្យាល័យ និងសកលវិទ្យាល័យ។ សូចនាករទាំងនេះមានសារៈសំខាន់សម្រាប់តម្រូវការអប់រំ និងបណ្តុះបណ្តាលដោយក្រសួងពាក់ព័ន្ធ ជាពិសេសដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ចំពោះផ្នែកផ្គត់ផ្គង់វិញការវិភាគនៃវគ្គបណ្តុះបណ្តាល TVET នៅកម្រិតវិញ្ញាបនបត្រ និងកម្រិតសាកលវិទ្យាល័យ បង្ហាញថាចំណែកនៃការផ្គត់ផ្គង់កម្លាំងពលកម្ម ដែលបានគ្របដណ្តប់ដោយវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ គឺមានលក្ខណៈគុណភាពដែលបរិមាណមានកំណត់ ដូច្នេះគួរតែពង្រីកការបណ្តុះបណ្តាលវិជ្ជាជីវៈភ្លាមៗនៅក្នុងទិសដៅចង្អុលបង្ហាញនៅក្នុងរបាយការណ៍។

# ផ្នែកទី១៖

# ការវិភាគពីសាវតា

# ជំពូក១៖

# ក្របខ័ណ្ឌនៃការវិភាគ

# គម្រូលំហូរនៃផ្សារកោរទារ

## ១.១ សេចក្តីផ្តើម

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

**សេវាកម្ម៖** កំណើនសរុបនៃផ្នែកសេវាកម្មឆ្នាំ២០០០ ដល់ឆ្នាំ២០១៧ មានត្រឹមតែខ្ពស់ជាង GDP បន្តិចប៉ុណ្ណោះ (២៧២%)។ រហូតមកដល់ឆ្នាំ២០០៩ កម្រិតពេលវេលានៃអត្រាកំណើនសេវាកម្មឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីតម្លៃដុលបន្ថែមជាមួយកំពូលពីរនៅឆ្នាំ២០០៤ និងឆ្នាំ២០០៥ ហើយការធ្លាក់ចុះយ៉ាងខ្លាំងដែលចាប់ផ្តើមពីឆ្នាំ២០០៧ និងអប្បបរមា ២.៣% ក្នុងឆ្នាំ២០០៩ (រូបភាព១៦)។ ទោះយ៉ាងណាវិស័យសេវាកម្មមិនអាចស្ទុះងើបឡើងវិញលឿនដូចវិស័យឧស្សាហកម្មទេ ហើយពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៧ បានចុះបញ្ជីអត្រាកំណើនទាបជាងមធ្យមដោយមានតម្លៃប្រមាណ ៧% ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ។

**រូបភាពទី១៦. សេវាកម្ម តម្លៃបន្ថែមដុល អត្រាកំណើនពីឆ្នាំ២០០០/០១ ដល់ឆ្នាំ២០១៦/១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

### ៣.១.៣ ចំណែកផលិតកម្មនៃវិស័យសំខាន់ៗ

អត្រាខុសគ្នានៃកំណើនដែលបានចុះបញ្ជីដោយវិស័យសេដ្ឋកិច្ចសំខាន់ៗ បានជះឥទ្ធិពលលើចំណែកផលិតកម្មរបស់ពួកគេ។ ក្នុងឆ្នាំ២០០០ វិស័យសេវាកម្ម គឺសំខាន់បំផុតហើយបានរក្សាជំហរនេះរហូតមកដល់បច្ចុប្បន្ន។ លើសពីនេះទៅទៀត ចាប់តាំងពីផលិតកម្មរបស់ខ្លួនបានកើនឡើងបន្តិចជាងតម្លៃបន្ថែម ចំណែករបស់វិស័យនេះ (គិតជាប្រាក់រៀលបច្ចុប្បន្ន) បានកើនឡើងពី ៣៩.១% ដល់ ៤២.២%។ ក្នុងឆ្នាំ២០០០ កសិកម្ម គឺជាវិស័យសំខាន់ទី២ ដែលមានចំណែក ៣៧.៨%។ ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១១ ចំណែកផលិតកម្មរបស់វាធ្លាក់ចុះលើកដំបូង ហើយបន្ទាប់មកបានថយចុះស្ទើរតែដល់តម្លៃឆ្នាំ២០០០។ ទោះយ៉ាងណានៅក្នុងឆ្នាំបន្តបន្ទាប់ទម្ងន់ដែលទាក់ទងនឹងកសិកម្មបានធ្លាក់ចុះយ៉ាងខ្លាំងដល់តម្លៃបច្ចុប្បន្ន ២៤.៩%។ ចំណែកនៃឧស្សាហកម្មបង្ហាញពីនិន្នាការដែលឆ្លុះបញ្ចាំង ពីវិស័យកសិកម្មដែលចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១១ វាបានកើនឡើងដំបូងបន្ទាប់មកត្រឡប់ទៅចំនួនដើមវិញ ហើយបន្ទាប់មកវាកើនឡើងជាលំដាប់រហូតដល់តម្លៃបច្ចុប្បន្ន ៣២.៩%។ ឧស្សាហកម្មបានក្លាយជាវិស័យសំខាន់ទី២ ក្នុងឆ្នាំ២០១៥។

សរុបសេចក្តីមកក្នុងរយៈពេល ១៧ឆ្នាំ ដែលគ្របដណ្តប់ដោយទិន្នន័យ៖

- សេវាកម្មតែងតែជាវិស័យសេដ្ឋកិច្ចសំខាន់បំផុត ហើយចំណែកនៃតម្លៃបច្ចុប្បន្នបានកើនឡើងបន្តិច។
- កសិកម្មដែលជាវិស័យលេចធ្លោរហូតដល់ចុងសតវត្សរ៍មុន តែឥឡូវចំណែកផលិតកម្មរបស់វាតិចជាងមួយភាគបួននៃចំនួនសរុប។
- ឧស្សាហកម្មដែលធ្លាប់ជាវិស័យមិនសូវសំខាន់ទេ ប៉ុន្តែចាប់ផ្តើមពីឆ្នាំ២០០៩ វិស័យនេះបាននឹងកំពុងធ្វើឱ្យប្រសើរឡើងឥតឈប់ឈរ និងវ៉ាលើសវិស័យកសិកម្មនៅឆ្នាំ២០១៥ ហើយបន្ទាប់មកឈានទៅរកវិស័យសេវាកម្ម។

**រូបភាពទី១៧. តម្លៃបន្ថែមដុលនៅថ្លៃបច្ចុប្បន្ន និងការបែងចែក%តាមវិស័យសេដ្ឋកិច្ចចម្បងចាប់ពីឆ្នាំ២០០០-២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

## ៣.២ មែកធាងនៃសេដ្ឋកិច្ច (The Branches)

### ៣.២.១ កសិកម្ម

មែកធាងសំខាន់ៗនៃវិស័យកសិកម្មនៅកម្ពុជា គឺទាក់ទងនឹងផលដំណាំ ជលផល បសុសត្វ និងបសុបក្សី ព្រៃឈើ និងការកាប់ឈើ (តារាង១៧)។ ក្នុងរយៈពេលដែលបានពិចារណា, ដំណាំបានចុះបញ្ជីអត្រាកំណើនខ្ពស់បំផុត (៥.៤%) បន្ទាប់មកគឺបសុសត្វ និងបសុបក្សី (៣%) និងជលផល (២.៩%)។ កម្រិតផលិតកម្មព្រៃឈើ និងការកាប់ឈើបានថយចុះ ០.១២%។ ដូចដែលយើងបានចង្អុលបង្ហាញរួចមកហើយអត្រាកំណើនជាមធ្យមនៃផលិតកម្មនៃវិស័យនេះបានធ្លាក់ចុះពី ៥.៣% ទៅ ២.៥% បន្ទាប់ពីមានវិបត្តិឆ្នាំ២០០៩។ ទំនោរនេះត្រូវបានចែករំលែកដោយមែកធាងទាំងអស់៖ ដំណាំ (ពី ៧.៩% ទៅ ២.៦%) បសុសត្វ និងបសុបក្សី (ពី ៥.១% ទៅ ០.៧%) ជលផល (ពី ៣.២% ទៅ ២.៦) ព្រៃឈើ និងការកាប់ឈើ (ពី ០.៨% ទៅ –១.៣ %)។

**តារាងទី១៧. កសិកម្ម តម្លៃបន្ថែម អត្រាកំណើនជាមធ្យមប្រចាំឆ្នាំនៃមែកធាងសេដ្ឋកិច្ចសំខាន់ៗចាប់ពីឆ្នាំ២០០០-២០០៩ ឆ្នាំ២០០៩-២០១៧ និងពីឆ្នាំ២០០០-២០១៧**

| | Crops | Livestock & poultry | Fisheries | Forestry & Logging | Total |
|---|---|---|---|---|---|
| 2000-09 | 7.9 | 5.1 | 3.2 | 0.8 | 5.3 |
| 2009-17 | 2.6 | 0.7 | 2.6 | -1.3 | 2.1 |
| 2000-17 | **5.4** | **3.0** | **2.9** | **-0.2** | **3.8** |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

ប្រៀបធៀបរចនាសម្ព័ន្ធផលិតកម្មនៅឆ្នាំ២០០០ និងឆ្នាំ២០១៧ ក្នុងតម្លៃបច្ចុប្បន្នយើងអាចសង្កេតឃើញថាសាខាតែមួយគត់ដើម្បីពង្រីកចំណែករបស់ខ្លួន គឺដំណាំ (ពី ៤៤.៨ ដល់ ៥៨.៥%)៖ ក្នុងពេលតែមួយការនេសាទដែលជាចំណែកសំខាន់បំផុតទី២ បានធ្លាក់ចុះពី ៣០ % ទៅ ២៣.៥%; បសុសត្វនិងបសុបក្សីពី ១៥.៥% មក ១១.២% ព្រៃឈើ និងការកាប់ឈើពី ៩.៨ ដល់ ៦.៨%។

**រូបភាពទី១៨. វិស័យកសិកម្ម សមាសភាព%នៃផលិតកម្មតាមមែកធាងសេដ្ឋកិច្ច (តម្លៃបច្ចុប្បន្ន) ចាប់ពីឆ្នាំ២០០០-២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

## ៣.២.២ ឧស្សាហកម្ម

កម្មន្តសាល គឺជាផ្នែករងនៃឧស្សាហកម្មដ៏សំខាន់បំផុត។ ទោះជាយ៉ាងណាអត្រាកំណើនរបស់ខ្លួន (១០.៣%) ទាបជាមធ្យមជាងឧស្សាហកម្ម និងទាបជាងរ៉ែ (១៩.៩%) អនុផ្នែកឧស្សាហកម្មដែលរីកចម្រើនលឿនបំផុត វិស័យសំណង់ (១១.៩%) អគ្គិសនី ឧស្ម័ន និងទឹក ( ១០.៩%) (តារាង១៨)។

លើសពីនេះទៅទៀត វាមានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងរយៈពេលឆ្នាំ២០០០-២០០៩ និងរយៈពេលឆ្នាំ២០០៩-២០១៧។ ការធ្វើអាជីវកម្មរ៉ែមិនត្រឹមតែជាវិស័យដែលមានការរីកចម្រើនលឿនបំផុតប៉ុណ្ណោះទេ ប៉ុន្តែអត្រានៃកំណើនរបស់វាខ្ពស់ជាងនៅក្នុងរយៈពេលទី២ (២១.៦% ទល់នឹង ១៨.៤%) ហើយអត្រានៃកំណើនផលិតកម្មក៏ខ្ពស់ជាងនៅក្នុងរយៈពេលទី២ដែរ (១១.៥% ធៀបនឹង ៩.២%) ខណៈពេលដែលសំណង់ និងជាពិសេសអគ្គិសនីខណៈពេលដែលនៅសេសសល់ជាមធ្យមនៃផលិតផលក្នុងស្រុកមានកម្រិតទាបគួរឱ្យកត់សម្គាល់។

**តារាងទី១៨. ឧស្សាហកម្ម តម្លៃបន្ថែម អត្រាកំណើនប្រចាំឆ្នាំជាមធ្យមនៃវិស័យរងសំខាន់ និងវិស័យសរុបចាប់ពីឆ្នាំ២០០០-២០០៩, ឆ្នាំ២០០៩-២០១៧ និងឆ្នាំ២០០០-២០១៧**

| | Mining | Manufacturing | Electricity, Gas & Water | Construction | Total |
|---|---|---|---|---|---|
| 2000-09 | 18.4 | 9.2 | 13.5 | 12.1 | 10.1 |
| 2009-17 | 21.6 | 11.5 | 8.0 | 11.5 | 11.2 |
| 2000-17 | **19.9** | **10.3** | **10.9** | **11.9** | **10.6** |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

ជាផលវិបាករបស់សំណុំនៃនិន្នាការស្មុគស្មាញទាំងនេះ ចំណែក%នៃការផលិតលើតម្លៃបន្ថែមនៃឧស្សាហកម្មបានបាត់បង់ច្រើនជាង ២០% ដោយបានធ្លាក់ចុះពី ៧៣.២% មក ៥២.៥% ខណៈចំណែកនៃសំណង់បានកើនឡើងពី ២៣.៨% ទៅ ៤០.៣% ហើយការជីកយករ៉ែបានកើនឡើងពី ១.១% ទៅ ៥.៤%(រូបភាពទី ១៩)។

**រូបភាពទី១៩. តម្លៃឧស្សាហកម្មបន្ថែម សមាសភាព៖ដោយអនុផ្នែកសំខាន់ (តម្លៃបច្ចុប្បន្ន) ឆ្នាំ២០០០-២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

## ៣.២.៣ កម្មន្តសាល

វិស័យកម្មន្តសាលរួមមានមែកធាងខុសៗគ្នាជាច្រើនដែលបានចុះបញ្ជីឌីណាមិកខុសគ្នាពីមុន និងក្រោយពេលមានវិបត្តិហិរញ្ញវត្ថុ (តារាង១៩)។

នៅក្នុងរយៈពេលដំបូងមែកធាងទាំងបីដែលបានលេចធ្លោនូវកំណើនលើសពីមធ្យម នៃវិស័យវាយនភ័ណ្ឌ (១៣.៨%) ការផលិតមិនមែនលោហធាតុ (១៣.៦%) ផលិតផលដែក និងលោហៈជាមូលដ្ឋាន (១៣%)។ នៅចុងម្ខាងទៀត យើងមានឈើ (-០.៦%) ជ័រកៅស៊ូ (០.៥%) និងអាហារ (៣%) ក្នុងរយៈពេល ៨ឆ្នាំបន្ទាប់។

**តារាងទី១៩. កម្មន្តសាល តម្លៃបន្ថែម អត្រាកំណើនប្រចាំឆ្នាំជាមធ្យមនៃមែកធាងសេដ្ឋកិច្ចធំៗ និងវិស័យសរុប ឆ្នាំ២០០០-២០០៩, ឆ្នាំ២០០៩-២០១៧ និងឆ្នាំ២០០០-២០១៧**

| | Food, Beverages & Tobacco | Textile, Wearing Apparel & Footwear | Wood, Paper & Publishing | Rubber Manufac-turing | Non-Metallic Manufac-turing | Basic Metal and Metal Products | Other manufac-turing | Total |
|---|---|---|---|---|---|---|---|---|
| 2000-09 | 3.0 | 13.8 | -0.6 | 0.5 | 13.6 | 13.0 | 6.6 | 10.4 |
| 2009-17 | 6.6 | 10.6 | 4.6 | 9.7 | 7.6 | 8.9 | 7.9 | 9.7 |
| 2000-17 | 4.7 | 12.3 | 1.8 | 4.8 | 10.8 | 11.1 | 7.2 | 10.1 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

នៅក្នុងរយៈពេលបន្ទាប់ អត្រានៃកំណើនកម្មន្តសាលបានធ្លាក់ចុះបន្តិច ហើយនេះជាការពិតសម្រាប់មែកធាងសេដ្ឋកិច្ចទាំងបីដែលបានដំណើរការល្អបំផុតក្នុងរយៈពេលមុនៗ។ ទោះយ៉ាងណាវិស័យវាយនភ័ណ្ឌបានបន្តកំណើនក្នុងអត្រាខ្ពស់ជាងមធ្យមភាគ (១០.៦%) ខណៈពេលដែលអត្រាកំណើននៃផលិតកម្មមិនមែនលោហៈ និងលោហៈធាតុធ្លាក់ចុះជារៀងរាល់ឆ្នាំក្រោម ៧.៦% និង ៨.៩%។ ក្នុងពេលជាមួយគ្នានេះការកែលម្អធំៗ ត្រូវបានចុះបញ្ជីដោយឈើ និងអាហារ ហើយជាពិសេសកៅស៊ូ។ ជាលទ្ធផលវិស័យវាយនភ័ណ្ឌដែលជាមែកធាងសេដ្ឋកិច្ចដ៏លេចធ្លោរួចទៅហើយក្នុងឆ្នាំ២០០០ បានបង្កើនចំណែករបស់ខ្លួនពី ៥៧.៥% ទៅ ៦៥.៧% ខណៈវិស័យសំខាន់ផ្សេងទៀតម្ហូបអាហារបានចុះបញ្ជីធ្លាក់ចុះពីជិត ២០% មកតិចជាង ១៥% ខណៈដែលវិស័យទាំងអស់ និងវិស័យផ្សេងទៀតបានចុះឈ្មោះមានការផ្លាស់ប្តូរតិចតួចប៉ុណ្ណោះ។

**រូបភាពទី២០. កម្មន្តសាល ដែលជាចំណែកមែកធាងសេដ្ឋកិច្ចសំខាន់ៗក្នុងឆ្នាំ២០០០ និងឆ្នាំ២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

### ៣.២.៤ វិស័យសេវាកម្ម

វិស័យសេវាកម្ម គឺជាវិស័យដែលមានលក្ខណៈប្លែកជាងគេដែលគ្របដណ្តប់លើសកម្មភាពសាធារណៈ និងឯកជន ដោយសកម្មភាពឯកជនរាប់ចាប់ពីវិស័យទេសចរណ៍រហូតដល់ពាណិជ្ជកម្ម ពីការដឹកជញ្ជូនរហូតដល់ហិរញ្ញវត្ថុ និង អចលនទ្រព្យ (តារាងទី២០)។

**តារាងទី២០. សេវាកម្ម តម្លៃបន្ថែម អត្រាកំណើនប្រចាំឆ្នាំជាមធ្យមនៃមែកធាងសេដ្ឋកិច្ចធំៗ និងវិស័យសរុបចាប់ពី ឆ្នាំ២០០០-២០០៩, ឆ្នាំ២០០៩-២០១៧ និងឆ្នាំ២០០០-២០១៧**

| | Trade | Hotel and Restaurant | Transportation and communication | Finance | Public Administration | Real Estate and Business services | Other services | Total |
|---|---|---|---|---|---|---|---|---|
| 2000-09 | 6.0 | 11.8 | 7.8 | 12.8 | -0.7 | 10.8 | 14.2 | 9.2 |
| 2009-17 | 6.9 | 7.6 | 7.5 | 11.1 | 5.1 | 6.6 | 5.7 | 6.8 |
| 2000-17 | 6.5 | 9.8 | 7.7 | 12.0 | 2.1 | 8.8 | 10.2 | 8.1 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

ហិរញ្ញវត្ថុ គឺជាមែកធាងសេដ្ឋកិច្ចដែលបានកត់ត្រាថាមានកំណើនខ្ពស់បំផុត (១២%) បន្ទាប់មកមានសេវាកម្មផ្សេងទៀត (១០.២%) សណ្ឋាគារ និងភោជនីយដ្ឋាន (៩.៨%) អចលនទ្រព្យ (៨.៨%) អត្រាកំណើនទាបជាងមធ្យមភាគត្រូវបានកត់ត្រាដោយការដឹកជញ្ជូនមាន (៧.៧%) និងពាណិជ្ជកម្ម (៦.៥%)។

**រូបភាពទី២០. សេវាកម្ម តម្លៃបន្ថែម សមាសភាព%ដោយមែកធាងសេដ្ឋកិច្ចសំខាន់ៗ (តម្លៃបច្ចុប្បន្ន) ឆ្នាំ២០០០ និង ឆ្នាំ២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

ប្រៀបធៀបរយៈពេលមុនពេលមានវិបត្តិ និងរយៈពេលបន្ទាប់យើងបានកត់ត្រាថា កំណើនរដ្ឋបាលសាធារណៈ (ពី -០.៧% ទៅ ៥.១% ដែលបង្ហាញពីការកើនឡើងនៃប្រាក់ឈ្នួល)។ ពាណិជ្ជកម្មក៏បានកត់ត្រាថាបានកើនឡើងតិចតួចពី ៦% ទៅ ៦.៩%។ អត្រាកំណើននៃសាខាទាំងអស់បានធ្លាក់ចុះ ហើយបាតុភូតនេះគឺពាក់ព័ន្ធ ជាពិសេសសម្រាប់សេវាកម្ម និងអចលនទ្រព្យផ្សេងទៀត (ពី ១៤.២% មក ៥.៧% និងពី ១០.៨% មក ៦.៦%) ប៉ុន្តែនិន្នាការអវិជ្ជមានត្រូវបានកត់ត្រាផងដែរដោយសណ្ឋាគារ និងភោជនីយដ្ឋាន (ពី ១១.៨% មក ៧.៦%) ការដឹកជញ្ជូន (ពី ៧.៨% មក ៧.៥%) និងហិរញ្ញវត្ថុ (ពី ១២.៨% មក ១១.១%)។

ក្នុងរយៈពេលដែលបានពិចារណា ចំណែកផលិតកម្មនៃមែកធាងសេដ្ឋកិច្ចចំនួនពីរបានធ្លាក់ចុះដែលពាណិជ្ជកម្មមាន ២៨.៩% ជាសាខាដែលពាក់ព័ន្ធបំផុតក្នុងឆ្នាំ២០០០ ហើយបានបាត់បង់ច្រើនជាង ៥% និងរដ្ឋបាលសាធារណៈធ្លាក់ចុះពី ៧.២% មក ៣.៣%។ ចំណែកផលិតកម្មនៃមែកធាងសេដ្ឋកិច្ចទាំងអស់ផ្សេងទៀតបានកើនឡើង ហើយជាពិសេសការដឹកជញ្ជូនពី ១៧.៨% ទៅ ២០.៤%។ អចលនទ្រព្យពី ១៦.៣% ទៅ ១៧.៦%, សណ្ឋាគារពី ១០% ទៅ ១១.៥% និងហិរញ្ញវត្ថុពី ៣.៣% ទៅ ៤.៩%។

## ៣.៣ ការចូលរួមចំណែកនៃវិស័យសំខាន់ៗក្នុងការបង្កើនតម្លៃបន្ថែម

រូបភាពទី២២ បង្ហាញពីការចូលរួមចំណែកនៃវិស័យសេដ្ឋកិច្ចសំខាន់ៗទាំងបីចំពោះកំណើននៃតម្លៃបន្ថែមនៅមុនពេលមានវិបត្តិសេដ្ឋកិច្ច នៅក្រោយវិបត្តិ និងនៅឆ្នាំ២០១៦-១៧ ដែលជាឆ្នាំចុងក្រោយដែលការប៉ាន់ស្មានអាចធ្វើទៅបាន។

**រូបភាពទី២២. ការចូលរួមចំណែកក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗទាំងបីដល់កំណើន នៃតម្លៃបន្ថែមក្នុងឆ្នាំ២០០០-២០០៩, ឆ្នាំ២០០៩-២០១៧ និងពីឆ្នាំ២០១៦-២០១៧**




*ប្រភព៖ Authors’ Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

**ជាតុពាក់ព័ន្ធបំផុតដែលលេចចេញមករួមមាន៖**

- ការថយចុះជាបណ្ដើរៗនៃការរួមចំណែកដែលនាំមកដោយវិស័យកសិកម្ម ក្នុងរយៈពេល ៩ឆ្នាំដំបូងនៃសតវត្សរ៍នេះមានចំនួនច្រើនជាង ២០%នៃកំណើនរបស់តម្លៃបន្ថែមដែលបានជោគជ័យក្នុងរយៈពេល ៨ឆ្នាំមានកំណើន ៧.៣% និងចុងក្រោយ ៥.២%។
- តួនាទីកាន់តែកើនឡើងនៃវិស័យឧស្សាហកម្មដែលចូលរួមចំណែកប្រហែល ៣៣%ក្នុងរយៈពេល ៩ឆ្នាំដំបូង ហើយកើនឡើងដល់ ៥២.១%។
- សេវាកម្មដើរតួនាទីសំខាន់ដែលតែងតែចូលរួមចំណែកខ្ពស់ជាង ៤០%។

## ៣.៤ ការរួមចំណែកនៃមែកធាងសេដ្ឋកិច្ច

ដោយផ្អែកលើការសិក្សាដល់កម្រិតនៃមែកជាងសេដ្ឋកិច្ចទាំង២១ យើងបានធ្វើការគណនាពីការរួមចំណែករបស់ពួកគេចំពោះកំណើននៃតម្លៃបន្ថែម សម្រាប់រយៈពេលពីរដង គឺឆ្នាំ២០០០-២០០៩ និងឆ្នាំ២០០៩-២០១៧ ហើយវាមានភាពស្រដៀងគ្នា ប៉ុន្តែក៏មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ (តារាងទី២១)។

**តារាងទី២១. ការចូលរួមចំណែករបស់មែកជាងសេដ្ឋកិច្ចដើម្បីកំណើនសេដ្ឋកិច្ចក្នុងរយៈពេលពីរឆ្នាំ២០០០-២០០៩ និងឆ្នាំ២០០៩-២០១៧**

| | | 2000-09 | | | 2009-17 | |
|---|---|---|---|---|---|---|
| | | % comp. | Cum. Values | | % comp. | Cum. Values |
| 1 | Textile, Wearing Apparel & Footwear | 19.6 | 19.6 | Textile, Wearing Apparel & Footwear | 31.3 | 31.3 |
| 2 | Other services | 15.0 | 34.7 | Construction | 10.8 | 42.1 |
| 3 | Crops | 14.2 | 48.9 | Trade | 9.3 | 51.4 |
| 4 | Construction | 9.5 | 58.4 | Other services | 7.6 | 59.0 |
| 5 | Real Estate and Business services | 8.8 | 67.2 | Transportation and communication | 7.4 | 66.4 |
| 6 | Hotel and Restaurant | 6.6 | 73.8 | Real Estate and Business services | 6.9 | 73.3 |
| 7 | Trade | 6.5 | 80.3 | Hotel and Restaurant | 5.4 | 78.8 |
| 8 | Transportation and communication | 6.1 | 86.5 | Crops | 4.9 | 83.7 |
| 9 | Fisheries | 3.3 | 89.8 | Mining | 3.2 | 86.8 |
| 10 | Livestock & poultry | 3.0 | 92.8 | Finance | 2.9 | 89.7 |
| 11 | Finance | 2.6 | 95.4 | Fisheries | 2.3 | 92.0 |
| 12 | Other manufacturing | 1.0 | 96.4 | Food, Beverages & Tobacco | 2.2 | 94.3 |
| 13 | Electricity, Gas & Water | 0.9 | 97.2 | Other manufacturing | 1.8 | 96.1 |
| 14 | Mining | 0.9 | 98.1 | Public Administration | 1.0 | 97.1 |
| 15 | Food, Beverages & Tobacco | 0.8 | 98.9 | Non-Metallic Manufacturing | 0.9 | 98.0 |
| 16 | Non-Metallic Manufacturing | 0.8 | 99.6 | Electricity, Gas & Water | 0.7 | 98.8 |
| 17 | Basic Metal and Metal Products | 0.3 | 99.9 | Rubber Manufacturing | 0.5 | 99.2 |
| 18 | Forestry & Logging | 0.2 | 100.1 | Basic Metal and Metal Products | 0.4 | 99.6 |
| 19 | Rubber Manufacturing | 0.0 | 100.1 | Livestock & poultry | 0.3 | 100.0 |
| 20 | Wood, Paper & Publishing | 0.0 | 100.1 | Wood, Paper & Publishing | 0.3 | 100.3 |
| 21 | Public Administration | -0.1 | 100.0 | Forestry & Logging | -0.3 | 100.0 |

*ប្រភព៖ Authors' Calculation. National Institute of Statistics, National Accounts of Cambodia 2000-2017*

នៅក្នុងអំឡុងពេលទាំងពីរ វិស័យសំខាន់បំផុតទាំង៥ ក្ដោបយកបីភាគបួននៃពីកំណើនសេដ្ឋកិច្ច។ ទោះយ៉ាងណាវិស័យទាំង៥ មិនដូចគ្នាទេ៖ នៅក្នុងរយៈពេលទាំងពីរនេះយើងរកឃើញថា វាយនភ័ណ្ឌ សំណង់ សេវាកម្មផ្សេងៗ និងអចលនទ្រព្យ ប៉ុន្តែនៅក្នុងរយៈពេលទីពីរពាណិជ្ជកម្មជំនួសដោយដំណាំ។

ការផ្លាស់ប្តូរដែលពាក់ព័ន្ធបំផុត គឺការកើនឡើងនៃភាពពាក់ព័ន្ធនៃវិស័យវាយនភ័ណ្ឌដែលក្នុងរយៈពេលដំបូង គឺ ១៩.៦% នៃកំណើនសេដ្ឋកិច្ច និងទីពីរ ៣១.៣%។

ជាទូទៅការប្រៀបធៀបរវាងការចូលរួមចំណែករបស់មែកធាងសេដ្ឋកិច្ចទាំង២១ ក្នុងរយៈពេលពីរបង្ហាញថា ការកើនឡើងពាក់ព័ន្ធត្រូវបានកត់ត្រាផងដែរ ដោយពាណិជ្ជកម្ម រ៉ែ ម្ហូបអាហារ សំណង់ និងការដឹកជញ្ជូន ខណៈដែល មែកធាងសេដ្ឋកិច្ចនៃវិស័យកសិកម្មទាំងអស់បានកត់ត្រាថាមានផលអវិជ្ជមាន ដំណាំក៏ដូចជាអចលនទ្រព្យ និង សណ្ឋាគារដែរ ។

**រូបភាពទី២៣. ការផ្លាស់ប្តូរដែលរួមចំណែកពីមែកធាងសេដ្ឋកិច្ចចំនួន២១ ក្នុងចន្លោះឆ្នាំ២០០០-២០០៩ និង ឆ្នាំ២០០៩-២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), National Accounts of Cambodia 2000-2017*

# ផ្នែកទី៤៖

# ការវិវត្តន៍នៃពលរដ្ឋក្នុងវិស័យការងារ WAP កម្លាំងពលកម្ម និងការងារ

## ៤.១ ពលរដ្ឋក្នុងវ័យការងារ (WAP) កម្លាំងពលកម្ម និងការងារ

តារាងទី២២. ចំនួនប្រជាជនដែលគ្រប់អាយុធ្វើការ កម្លាំងពលកម្ម និងការងារ (តម្លៃគិតជាខ្ទង់ពាន់) ឆ្នាំចាប់ពី ២០០៧-២០១៧

| | Tot. Pop in thousand | WAP in thousand | LF in thousand | Empl in thousand |
|---|---|---|---|---|
| 2007 | 13,230 | 8,232 | 6,888 | 6,837 |
| 2008 | 13,389 | 8,379 | 6,854 | 6,829 |
| 2009 | 13,967 | 8,865 | 7,480 | 7,470 |
| 2010 | 13,958 | 8,853 | 7,702 | 7,689 |
| 2011 | 14,155 | 9,038 | 7,907 | 7,891 |
| 2012 | 14,376 | 9,167 | 7,718 | 7,706 |
| 2013 | 14,678 | 9,604 | 7,974 | 7,950 |
| 2014 | 15,184 | 10,001 | 8,259 | 8,241 |
| 2015 | 15,405 | 10,113 | 8,359 | 8,353 |
| 2016 | 15,626 | 10,265 | 8,624 | 8,612 |
| 2017 | 15,848 | 10,416 | 8,779 | 8,770 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

ទោះបីជាមានវិបត្តិក្នុងឆ្នាំ២០០៩ ការផ្តល់ការងារសរុបបានកើនឡើងក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ២.៨ (ដែលមានចំនួនលើសពីការផ្គត់ផ្គង់កម្លាំងពលកម្មបន្តិច) ដែលត្រូវនឹងការកើនឡើងប្រចាំឆ្នាំចំនួន ១៩៣,០០០ការងារ (តារាង២៣)។ តម្លៃសម្រាប់រយៈពេល ៥ឆ្នាំចុងក្រោយដែលយើងនឹងផ្តោតលើការវិភាគរបស់យើង គឺខ្ពស់ជាងនេះបន្តិច។ ពិសេសជាងនេះទៅទៀត កំណើនការងារប្រចាំឆ្នាំមានចំនួនស្មើនឹង ២១៣,០០០ ការងារ។

**តារាងទី២៣. ចំនួនប្រជាជនដែលគ្រប់អាយុធ្វើការ កម្លាំងពលកម្ម និងការងារ តម្លៃដាច់ខាត និងបម្រែបម្រួលជា% ឆ្នាំ២០០៧-២០១៧ និងឆ្នាំ២០១២-២០១៧**

| | Tot. Pop | WAP | LF | Empl |
|---|---|---|---|---|
| | 2007-2017 | | | |
| Total change in thousand | 2,618 | 2,184 | 1,891 | 1,934 |
| Aver. early change in thousand | 262 | 218 | 189 | 193 |
| Total % change | 19.8 | 26.5 | 27.5 | 28.3 |
| Average yearly % change | 2.0 | 2.7 | 2.7 | 2.8 |
| | 2012-17 | | | |
| Total change in thousand | 1,472 | 1,249 | 1,061 | 1,064 |
| Aver. early change in thousand | 294 | 250 | 212 | 213 |
| Total % change | 10.2 | 13.6 | 13.7 | 13.8 |
| Average yearly % change | 2.0 | 2.7 | 2.7 | 2.8 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

ក្នុងរយៈពេល ១០ឆ្នាំមុន រចនាសម្ព័ន្ធការងារតាមវិស័យសំខាន់ៗមានការប្រែប្រួលគួរឱ្យកត់សម្គាល់ (តារាង២៤)។

**តារាងទី២៤. ការងារសរុប (អាយុ១៥ ដល់៦៤) តាមវិស័យសេដ្ឋកិច្ចសំខាន់ៗ តម្លៃដាច់ខាត និងសមាសភាពជា% ចាប់ពីឆ្នាំ២០០៧-២០១៧**

| | Agriculture | Industry | Services | Agriculture | Industry | Services |
|---|---|---|---|---|---|---|
| | Absolute vales in thousand | | | % composition | | |
| 2007 | 3,946 | 1,019 | 1,871 | 57.7 | 14.9 | 27.4 |
| 2008 | 3,797 | 1,080 | 1,952 | 55.6 | 15.8 | 28.6 |
| 2009 | 4,304 | 1,184 | 1,981 | 57.6 | 15.9 | 26.5 |
| 2010 | 4,165 | 1,249 | 2,274 | 54.2 | 16.2 | 29.6 |
| 2011 | 4,402 | 1,332 | 2,157 | 55.8 | 16.9 | 27.3 |
| 2012 | 3,931 | 1,433 | 2,343 | 51.0 | 18.6 | 30.4 |
| 2013 | 3,870 | 1,579 | 2,501 | 48.7 | 19.9 | 31.5 |
| 2014 | 3,733 | 2,003 | 2,505 | 45.3 | 24.3 | 30.4 |
| 2015 | 3,470 | 2,132 | 2,751 | 41.5 | 25.5 | 32.9 |
| 2016 | 3,135 | 2,291 | 3,187 | 36.4 | 26.6 | 37.0 |
| 2017 | 3,245 | 2,298 | 3,227 | 37.0 | 26.2 | 36.8 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

នៅឆ្នាំ២០០៧ អ្នកធ្វើការនៅក្នុងវិស័យកសិកម្មមានចំនួន ៥៨% សេវាកម្មមានចំនួន ២៧% និងឧស្សាហកម្មមាន ១៥%។ ក្នុងរយៈពេល ៥ឆ្នាំបន្តមកទៀត ការងារបានកើនឡើងជិត ៩០០,០០០នាក់ ប៉ុន្តែកំណើននេះត្រូវបានប្រមូលផ្តុំនៅក្នុងសេវាកម្ម (៤៧២,០០០នាក់) និងឧស្សាហកម្ម (៤១៣,០០០នាក់) ខណៈពេលដែលកម្រិតការងារនៅក្នុងកសិកម្មនៅតែមានស្ថេរភាព។ ចំណែកវិស័យកសិកម្មនៅតែមានលើសពី ៥០% ជាមួយសេវាកម្ម និងឧស្សាហកម្ម ៣០% និង ១៩%។ ការធ្លាក់ចុះនៃការងារកសិកម្មកាន់តែមានការពាក់ព័ន្ធកាន់តែច្រើនឡើងៗ ដែលចាប់ផ្តើមពីឆ្នាំ២០១១ ដូច្នេះ នៅឆ្នាំបន្តបន្ទាប់ទៀតចំនួនការងារនៅក្នុងវិស័យកសិកម្មបានធ្លាក់ចុះជាមធ្យមត្រឹម ១៩៣,០០០នាក់ ដែលជាការបាត់បង់មួយទោះយ៉ាងណាភាគច្រើនត្រូវបានបំពេញដោយការកើនឡើងនៃសេវាកម្ម និងឧស្សាហកម្មដែលមានចំនួន ១៧៨,០០០នាក់ និង ១៦១,០០០នាក់ ការងារក្នុងមួយឆ្នាំៗ (តារាង២៥)។

**តារាងទី២៥. ការងារសរុប (អាយុ១៥ ដល់៦៤) តាមវិស័យសេដ្ឋកិច្ចសំខាន់ៗ បម្រែបម្រួលតម្លៃដាច់ខាត និងបម្រែបម្រួលជា%ក្នុងរយៈពេលចាប់ពីឆ្នាំ២០០៧-២០១៧**

| | Agriculture | Industry | Services | Total |
|---|---|---|---|---|
| | 2007-17 | | | |
| Total change in thousand | -701 | 1,279 | 1,356 | 1,934 |
| Yearly change in thousand | -70 | 128 | 136 | 193 |
| Percentage change | -17.8 | 125.4 | 72.5 | 28.3 |
| Yearly % change | -1.8 | 12.5 | 7.3 | 2.8 |
| | 2011-17 | | | |
| Total change in thousand | -1,157 | 966 | 1,070 | -19 |
| Yearly change in thousand | -193 | 161 | 178 | -3 |
| Percentage change | -29.4 | 67.4 | 45.7 | 13.8 |
| Yearly % change | -5.9 | 13.5 | 9.1 | 2.8 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

ជាលទ្ធផលនៅក្នុងឆ្នាំ២០១៧ ការងារកសិកម្មមានចំនួនខ្ពស់ ៣៧% ដូចនៅក្នុងវិស័យសេវាកម្មដែរហើយឧស្សាហកម្មមាន ២៦%។

**រូបភាពទី២៤. %ចំណែកការងារនៃវិស័យសេដ្ឋកិច្ចចាប់ពីឆ្នាំ២០០៧-២០១៧**




*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

ការផ្លាស់ប្តូរធំៗ បានកើតឡើងទាក់ទងនឹងរចនាសម្ព័ន្ធការងារតាមស្ថានភាព (តារាងទី២៦)។ ក្នុងឆ្នាំ២០០៧ ប្រភេទការងារច្រើនបំផុត គឺអ្នកប្រកបរបរផ្ទាល់ខ្លួនដែលមានចំនួន ៣៨% បន្ទាប់មកគឺមេគ្រួសារមិនទទួលបានប្រាក់ឈ្នួលមាន (៣៦%) និងនិយោជិកមានប្រាក់ឈ្នួលដែលតំណាងឱ្យតែ ២៦% ប៉ុណ្ណោះ។ បន្ទាប់ពី ៥ឆ្នាំ %នៃអ្នកប្រកបរបរផ្ទាល់ខ្លួនបានឡើងដល់ ៥៥% ហើយក្រុមគ្រួសារបានធ្លាក់ចុះដល់ ៩% ហើយនិយោជិកដែលមានប្រាក់ខែបានកើនឡើងដល់ ៣៦%។ ទីបំផុតក្នុងរយៈពេល ៥ឆ្នាំខាងមុខ %នៃនិយោជិកដែលទទួលបានប្រាក់ខែបានកើនឡើងដល់ ៥១% នៃអ្នកប្រកបរបរផ្ទាល់ខ្លួនបានធ្លាក់ចុះមកនៅត្រឹម ៤៥% ខណៈពេលដែលមេគ្រួសារមាន ៤%។

**តារាងទី២៦. ការងារសរុប (១៥-៦៤) តាមស្ថានភាព តម្លៃដាច់ខាត (គិតជាពាន់) ក្នុងឆ្នាំ២០០៧, ឆ្នាំ២០១២ និង ២០១៧; ការផ្លាស់ប្តូរដាច់ខាតរវាងឆ្នាំ២០០៧-២០១២ និងឆ្នាំ២០១២-២០១៧**

| | Employer | Paid employee | Own account worker/self-employed | Unpaid family worker | Total |
|---|---|---|---|---|---|
| 2007 | 4 | 1,885 | 2,791 | 2,628 | 7,308 |
| 2012 | 3 | 2,759 | 4,249 | 694 | 7,705 |
| 2017 | 11 | 4472 | 3903 | 380 | 8,766 |
| | 2007-17 | | | | |
| Total change | 7 | 2,587 | 1,112 | -2,248 | -2,248 |
| Aver. early change | 1 | 259 | 111 | -225 | -225 |
| Total % change | 174 | 137 | 40 | -86 | -86 |
| Average yearly % change | 17 | 14 | 4 | -9 | -9 |
| | 2012-17 | | | | |
| Total change | 8 | 1,713 | -346 | -314 | -314 |
| Aver. early change | 2 | 343 | -69 | -63 | -63 |
| Total % change | 289 | 62 | -8 | -45 | -45 |
| Average yearly % change | 58 | 12 | -2 | -9 | -9 |

*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

រូបភាពទី២៥. ការងារសរុបតាមស្ថានភាព សមាសភាព%នៅឆ្នាំ២០០៧, ឆ្នាំ២០១២ និងឆ្នាំ២០១៧




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

**មុខរបរ៖** សូចនាករគួរឱ្យចាប់អារម្មណ៍ផ្សេងទៀតស្តីពីរបៀបដែលរចនាសម្ព័ន្ធការងាររបស់ប្រទេសកម្ពុជាមានការវិវត្តន៍កើតឡើងពីរចនាសម្ព័ន្ធតាមមុខរបរ (តារាង២៧)។

**តារាងទី២៧. ការងារសរុប (១៥-៦៤) តាមមុខរបរ តម្លៃដាច់ខាតនៅក្នុងសមាសភាពគិតជាពាន់ និង% ឆ្នាំ២០០៧, ឆ្នាំ២០១២ និងឆ្នាំ២០១៧**

| | 2007 | 2012 | 2017 | 2007 | 2012 | 2017 |
|---|---|---|---|---|---|---|
| | Absolute values | | | Percenatge composition | | |
| Armed forces occupations | **31** | **57** | **78** | ***0.5*** | ***0.7*** | ***0.9*** |
| Manager | **58** | **68** | **65** | ***0.9*** | ***0.9*** | ***0.7*** |
| Professionals | **206** | **227** | **303** | ***3.0*** | ***2.9*** | ***3.5*** |
| Technicians and associate professionals | **136** | **69** | **127** | ***2.0*** | ***0.9*** | ***1.4*** |
| Clerical support workers | **133** | **231** | **424** | ***1.9*** | ***3.0*** | ***4.8*** |
| Service and sales workers | **822** | **1,300** | **1573** | ***12.0*** | ***16.9*** | ***17.9*** |
| Skilled agricultural, forestry and fishery workers | **3,506** | **3,064** | **2670** | ***51.3*** | ***39.8*** | ***30.5*** |
| Craft and related worker | **641** | **1,273** | **2101** | ***9.4*** | ***16.5*** | ***24.0*** |
| Plant and machine operators and assemblers | **575** | **279** | **361** | ***8.4*** | ***3.6*** | ***4.1*** |
| Elementary occupations | **718** | **1,137** | **1063** | ***10.5*** | ***14.8*** | ***12.1*** |
| Total | **6,828** | **7,705** | **8766** | ***100.0*** | ***100.0*** | ***100.0*** |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

ក្នុងឆ្នាំ២០០៧ ជាងពាក់កណ្តាលនៃការងារត្រូវបានចាត់ថ្នាក់ជាកម្មករជំនាញកសិកម្ម បន្ទាប់ពី ១០ឆ្នាំមកបានធ្លាក់ចុះដល់ ៣១%។ ទន្ទឹមនឹងនេះ %នៃសិប្បកម្មដែលមានទំងន់តិចជាង ១០% បានកើនឡើងទ្វេដងហើយគិតមកទល់ពេលនេះមាន ២៤% គឺជាក្រុមមុខរបរធំជាងគេទី២។ មុខរបរទីពីរដែលបានពង្រីកខ្លួនគួរឱ្យកត់សម្គាល់ គឺបុគ្គលិកផ្នែកលក់ និងបុគ្គលិកសេវាកម្មដែលបានកើនឡើងពី ១២% ទៅ ១៨%។ ទិន្នន័យទាំងនេះបញ្ជាក់ពីការធ្លាក់ចុះនៃការថយចុះនៃកសិកម្ម និងការពង្រីកឧស្សាហកម្ម និងសេវាកម្ម។ ទោះយ៉ាងណាទិន្នន័យស្តីពីមុខរបរក៏បញ្ជាក់ពីវត្តមាន (សូម្បី តែការលូតលាស់) របស់កម្មករគ្មានជំនាញដែលនឹងមានទម្ងន់ទាបបំផុតដែលទាមទារឱ្យមានការអប់រំខ្ពស់។ គួរកត់សម្គាល់ថាទម្ងន់រួមរបស់អ្នកគ្រប់គ្រង អ្នកជំនាញ និងអ្នកបច្ចេកទេសបានធ្លាក់ចុះបន្តិចហើយនៅតែទាបជាង ៦%។

ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះបើយើងពិចារណាពីការវិវត្តន៍នៃបរិមាណនៃមុខរបរ នោះមានមុខរបរ ៣ ដែលមាននិន្នាការអវិជ្ជមាន គឺអ្នកគ្រប់គ្រងមុខរបរការងារបឋម និងជាពិសេសកម្មករជំនាញកសិកម្ម។ ការផ្លាស់ប្តូរវិជ្ជមានដែលពាក់ព័ន្ធបំផុតត្រូវបានកត់ត្រាតាមលំដាប់លំដោយ ដែលសិប្បកម្មនិងមុខរបរដែលពាក់ព័ន្ធ (៥៤%) សេវាកម្មនិងកម្មករផ្នែកលក់ (១៨%) និងបុគ្គលិកផ្នែកគាំទ្រការងារ ឬស្មៀន (១៣%)។ ការចូលរួមចំណែកគួរឱ្យចាប់អារម្មណ៍ផ្សេងទៀតបានមកពីប្រតិបត្តិកររោងចក្រ និងម៉ាស៊ីន អ្នកជំនាញ និងអ្នកបច្ចេកទេស (តារាង២៨)។

**តារាងទី២៨. ការងារសរុបតាមមុខរបរគិតជាខ្ទង់ពាន់ ការផ្លាស់ប្តូរសរុប និងជាមធ្យមប្រចាំឆ្នាំក្នុងឆ្នាំ២០០៧-២០១៧ និងឆ្នាំ២០១២-២០១៧**

| | 2007-17 | | 2012-17 | |
|---|---|---|---|---|
| | Total change | Yearly change | Total change | Yearly change |
| Armed forces occupations | 47 | 5 | 21 | 4 |
| Manager | 7 | 1 | -3 | -1 |
| Professionals | 97 | 10 | 76 | 15 |
| Technicians and associate professionals | -9 | -1 | 58 | 12 |
| Clerical support workers | 291 | 29 | 193 | 39 |
| Service and sales workers | 751 | 75 | 273 | 55 |
| Skilled agricultural, forestry and fishery workers | -836 | -84 | -394 | -79 |
| Craft and related worker | 1,460 | 146 | 828 | 166 |
| Plant and machine operators and assemblers | -214 | -21 | 82 | 16 |
| Elementary occupations | 345 | 34 | -74 | -15 |
| Balance | 1,938 | 194 | 1,061 | 212 |
| Positive values | 2,997 | 300 | 1,531 | 306 |
| Negative values | -1,059 | -106 | -471 | -94 |

*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

**ការអប់រំ៖** ទិន្នន័យស្តីពីការអប់រំបញ្ជាក់ថា ការងារនៅប្រទេសកម្ពុជានៅ តែទទួលរងពីការខ្វះខាតការសិក្សាយ៉ាងធ្ងន់ធ្ងរ ហើយរួមបញ្ចូលទាំងការអប់រំបណ្តុះបណ្តាលបច្ចេកទេសផងដែរ។ នៅឆ្នាំ២០០៥ សមាជិកនៃកម្លាំងពលកម្មជិត ៨២% មិនបានបញ្ចប់ការអប់រំជាកាតព្វកិច្ចទេ (Compulsory Education) មានតែ ៤.៦% ប៉ុណ្ណោះដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និង ២.១% នៃសញ្ញាប័ត្រសាកលវិទ្យាល័យ។ លើសពីនេះទៅទៀត ១៨% មានការអប់រំក្រៅប្រព័ន្ធ (តារាង២៩)។

បន្ទាប់ពីរយៈពេល១០ឆ្នាំ ស្ថានការណ៍បានប្រសើរឡើងពិតមែន ប៉ុន្តែកម្រិតអប់រំនៃកម្លាំងពលកម្មនៅទាបនៅឡើយ គឺ ៧០% មិនបានបញ្ចប់ការអប់រំជាកាតព្វកិច្ច (ថ្នាក់ទី៩) ទេ ហើយអ្នកដែលមានការអប់រំខ្ពស់គឺ ៨% និង ៧% មានសញ្ញាបត្រក្រោយមធ្យមសិក្សា។

ទិន្នន័យទាំងនេះបញ្ជាក់ពីទិន្នន័យស្តីពីការផលិតកម្មនៃប្រព័ន្ធ TVET និងសាកលវិទ្យាល័យដែលយើងបានវិភាគពីមុន ហើយយើងនឹងធ្វើការស៊ើបអង្កេតបន្ថែមទៀតនៅក្នុងជំពូកបន្ទាប់។

**តារាងទី២៩. ការងារសរុប (១៥-៦៤) តាមកម្រិតអប់រំ តម្លៃដាច់ខាតនៅក្នុងសមាសភាព (គិតជាពាន់) និង% ឆ្នាំ២០០៧, ឆ្នាំ២០១២ និងឆ្នាំ២០១៧**

| | 2007 | 2012 | 2017 | 2007 | 2012 | 2017 |
|---|---|---|---|---|---|---|
| | Absolute values | | | Percenatge composition | | |
| None or only some education | 1,266 | 1,080 | 1,050 | 18.4 | 14.0 | 12.0 |
| Primary school not completed | 2,644 | 2,674 | 2,779 | 38.4 | 34.6 | 31.7 |
| Primary school completed | 1,722 | 2,160 | 2,281 | 25.0 | 28.0 | 26.0 |
| Lower secondary completed | 771 | 1,107 | 1,361 | 11.2 | 14.3 | 15.5 |
| Upper secondary completed | 319 | 478 | 722 | 4.6 | 6.2 | 8.2 |
| Post secondary education | 143 | 217 | 575 | 2.1 | 2.8 | 6.6 |
| Total | 6,888 | 7,718 | 8,766 | 100.0 | 100.0 | 100.0 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

ជាតុវិជ្ជមានត្រូវបានតំណាងដោយការពិតដែលថា ក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយនេះ ៣៤% នៃការងារបន្ថែមបានដល់អ្នកដែលមានការអប់រំក្រោយមធ្យមសិក្សា។ ក្នុងអំឡុងពេលតែមួយបានកត់ត្រាថាក៏មានការកើនឡើងនៃចំនួនអ្នកមានការងារធ្វើដែលមានការអប់រំទាបជាងបឋមសិក្សា ឬក៏បឋមសិក្សាផងដែរ។

**តារាងទី៣០. ការងារសរុបទៅតាមកម្រិតនៃការអប់រំ (គិតជាពាន់) បម្រែបម្រួលសរុប និងប្រចាំឆ្នាំក្នុងឆ្នាំ២០០៧-២០១៧ និងឆ្នាំ២០១២-២០១៧**

| | 2007-17 | | 2012-17 | |
|---|---|---|---|---|
| | Total change | Yearly change | Total change | Yearly change |
| None or only some education | -216 | -22 | -30 | -6 |
| Primary school not completed | 135 | 14 | 105 | 21 |
| Primary school completed | 559 | 56 | 121 | 24 |
| Lower secondary completed | 590 | 59 | 254 | 51 |
| Upper secondary completed | 403 | 40 | 244 | 49 |
| Post secondary education | 432 | 43 | 358 | 72 |
| Total | 1,878 | 188 | 1,048 | 210 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

**រូបភាពទី២៦. អត្រាមានការងារធ្វើ កំណើន%នៃក្រុមដែលមានការងារទៅតាមកម្រិតនៃការអប់រំខុសៗគ្នាចាប់ពីឆ្នាំ២០១២-១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

**អត្រាការងារសរុប និងតាមក្រុមអាយុ៖** %នៃប្រជាជនដែលធ្វើការមិនត្រឹមតែខ្ពស់នៅឡើយទេទោះបីជាវិស័យកសិកម្មមានការធ្លាក់ចុះក៏ដោយ ក៏មានការកើនឡើងបន្តិចដែរ (ពី ៨៣.៧% ទៅ ៨៤.៣%) (រូបភាព២៧)។

**រូបភាពទី២៧. អត្រានៃការងារ និងដោយក្រុមអាយុសំខាន់ (អាយុ១៥-៦៤) ឆ្នាំ២០០៧ និងឆ្នាំ២០១៧**




| | 15-19 | 20-24 | 25-34 | 35-44 | 45-54 | 55-64 | 15-64 |
|---|---|---|---|---|---|---|---|
| Diff | -10.8 | 0.6 | 4.3 | 3.2 | 1.5 | -0.7 | 0.6 |
| 2007 | 70.8 | 84.4 | 88.9 | 90.5 | 87.5 | 76.6 | 83.7 |
| 2017 | 60.0 | 85.0 | 93.2 | 93.6 | 89.0 | 75.9 | 84.3 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

ទោះជាយ៉ាងណាចំនួនអ្នកមានការងារធ្វើ ត្រូវបានគេប្រមូលផ្តុំកាន់តែច្រើននៅក្នុងក្រុមអាយុវ័យកណ្តាលជាលទ្ធផលយើងសង្កេតឃើញការធ្លាក់ចុះនៃអត្រាសកម្មភាពរបស់ក្រុមអាយុដំបូង និងចុងក្រោយហើយការធ្លាក់ចុះនេះទប់ទល់ដោយការកើនឡើងនៃអត្រារបស់ក្រុមអាយុកណ្តាល។

## ៤.២ តួនាទីស្ត្រីក្នុងទីផ្សារការងារ

**ការងារសរុប និងការងារតាមវិស័យ៖** ក្នុងអំឡុងឆ្នាំ២០០៧-១៧ %នៃស្ត្រីដែលមានការងារធ្វើបានធ្លាក់ចុះបន្តិចដោយសារតែការធ្លាក់ចុះនៃការងារនៅក្នុងវិស័យកសិកម្មដែលពួកគេនៅតែមាន។ %នៃស្ត្រីនៅក្នុងសេវាកម្មបានកើនឡើងបន្តិចខណៈពេលដែលឧស្សាហកម្មបានធ្លាក់ចុះបន្តិច។ នៅឆ្នាំ២០០៧ ស្ត្រី ៥៩% ធ្វើការក្នុងវិស័យកសិកម្ម ១៤% ក្នុងឧស្សាហកម្ម និង ២៦% នៅក្នុងវិស័យសេវាកម្ម។ បន្ទាប់ពីដប់ឆ្នាំ ស្ថានការណ៍បានផ្លាស់ប្តូរយ៉ាងខ្លាំងបន្ទាប់ពីការបែងចែកការងារក្នុងវិស័យសរុប៖ ក្នុងឆ្នាំ២០០៧ ស្ត្រី ៣៩% ធ្វើការក្នុងវិស័យកសិកម្ម ២៥% នៅក្នុងឧស្សាហកម្ម និង ៣៦% នៅក្នុងសេវាកម្ម (រូបភាព ២៨)។

**រូបភាពទី២៨. %នៃស្ត្រីលើការងារសរុប និងវិស័យសេដ្ឋកិច្ចចម្បងឆ្នាំ២០០៧ និងឆ្នាំ២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

**ស្ថានភាពការងារ៖** ការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងរចនាសម្ព័ន្ធនៃស្ថានភាពការងារដែលយើងបានផ្តល់យោបល់រួចហើយសម្រាប់ចំនួនសរុបត្រូវបានចែករំលែកតាមរបៀបដែលកាន់តែច្បាស់ដោយសមាសធាតុស្ត្រី។ ក្នុងឆ្នាំ២០០៧ ស្ថានភាពលេចធ្លោរបស់ស្ត្រី គឺជាមេគ្រួសារដែលមិនបានទទួលប្រាក់ឈ្នួលដែលមានចំនួន ៤៧.៦% បន្ទាប់មកគឺអ្នកប្រកបរបរផ្ទាល់ខ្លួនដែលមាន ៣៩.១% និងចុងក្រោយដោយនិយោជិតដែលមានប្រាក់ឈ្នួល ២១.៨%។ នៅឆ្នាំ ២០១៧ ចំណាត់ថ្នាក់ត្រូវបានបញ្ច្រាស់មកវិញជាមួយនិយោជិតដែលទទួលបានប្រាក់ឈ្នួល ៥៦.៦% អ្នកប្រកបរបរផ្ទាល់ខ្លួនមានចំនួន ៣៩.១% មេគ្រួសារដែលមិនមានប្រាក់ឈ្នួលបានធ្លាក់ចុះដល់ ៤%។ លើសពីនេះទៅទៀត ក្នុងឆ្នាំ២០០៧ មានតែ ៤១.៥% នៃនិយោជិតដែលទទួលបានប្រាក់ឈ្នួល ព្រោះនៅឆ្នាំ២០១៧ %បានកើនឡើងដល់ ៥៦.៧% ហើយ %នៃស្ត្រីដែលត្រូវបានចាត់ចូលជាអ្នកប្រកបរបរផ្ទាល់ខ្លួនបានកើនឡើងពី ៣៩.៣% ទៅ ៤៥% (រូបភាព ២៩)។

**រូបភាពទី២៩. ស្ត្រីដែលមានការងារធ្វើទៅតាមស្ថានភាពការងារឆ្នាំ២០០៧ និងឆ្នាំ២១០៧ និងភាពខុសគ្នា**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

**មុខរបរ៖** មុខរបរឆ្លុះបញ្ចាំងទាំងការផ្លាស់ប្តូររចនាសម្ព័ន្ធតាមវិស័យ ស្ថានភាព ដូចដែលយើងនឹងឃើញតាមរយៈការទទួលបានការអប់រំ។ ក្នុងឆ្នាំ២០០៧ មានតែមុខរបរ ៣ ប៉ុណ្ណោះដែលមានចំណែកពីរខ្ទង់ គឺកម្មករជំនាញកសិកម្ម (៥២.៧%) បុគ្គលិកផ្នែកសេវាកម្ម និងលក់ (១៧%) និងមុខរបរបឋម (តារាង ៣១)។ គិតជារួមពួកគេមានចំនួន ៨០% នៃការងារសរុប។ ក្រោយរយៈពេល ១០ឆ្នាំ កម្មករជំនាញកសិកម្មនៅតែជាមុខរបរសំខាន់ ប៉ុន្តែចំណែករបរនេះធ្លាក់ចុះដល់ ៣២.៥% ខណៈដែលចំណែកនៃបុគ្គលិកផ្នែកលក់មានដល់ទៅ ២៣.៥% ហើយសំខាន់ជាងនេះទៀតនោះ គឺសិប្បកម្ម និងការងារដែលពាក់ព័ន្ធគឺមានរហូតដល់ ២៣.១% ខណៈការអប់រំបឋមក៏មានផងដែរនៅតែស្ថិតក្នុងប្រភេទពីរខ្ទង់។ មុខរបរទាំងបួននេះមានរហូតដល់ឥឡូវនេះគឺ ៩០.២%។

**តារាងទី៣១. ទិន្នន័យស្ត្រីក្នុងការងារសរុបតាមមុខរបរ តម្លៃដាច់ខាតនៅក្នុងសមាសភាព (គិតជាពាន់) និង %ចាប់ពីឆ្នាំ២០០៧, ឆ្នាំ២០១៧ និងខុសគ្នា**

| | 2007 | 2017 | Diff. | 2007 | 2017 | Diff. |
|---|---|---|---|---|---|---|
| | Absolute values | | | % composition | | |
| Armed forces occupations | 1 | 3 | 2 | 0.0 | 0.1 | 0.0 |
| Manager | 17 | 16 | -1 | 0.5 | 0.4 | -0.1 |
| Professionals | 84 | 155 | 71 | 2.5 | 3.6 | 1.1 |
| Technicians and associate professionals | 37 | 46 | 9 | 1.1 | 1.1 | -0.0 |
| Clerical support workers | 52 | 176 | 124 | 1.5 | 4.1 | 2.6 |
| Service and sales workers | 570 | 1008 | 438 | 17.0 | 23.5 | 6.5 |
| Skilled agricultural, forestry and fishery workers | 1,766 | 1391 | -375 | 52.7 | 32.5 | -20.2 |
| Craft and related worker | 230 | 989 | 759 | 6.9 | 23.1 | 16.2 |
| Plant and machine operators and assemblers | 251 | 22 | -229 | 7.5 | 0.5 | -7.0 |
| Elementary occupations | 346 | 477 | 131 | 10.3 | 11.1 | 0.8 |
| | 3,353 | 4,283 | 930 | 100.0 | 100.0 | 0.0 |

*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

ជាការកត់សម្គាល់គឺការកើនឡើងនូវចំណែករបស់ស្មៀន និងបុគ្គលិកជំនួយការ ពី ១.៥% ទៅ ៤.១% និងអ្នកជំនាញពី ២.៥ ទៅ ៣.៦% ។ នៅផ្នែកអវិជ្ជមាន កម្មករគ្មានជំនាញដែល %នៅតែខ្ពស់។

**រូបភាពទី៣០. %ស្ត្រីក្នុងមុខរបរនីមួយៗឆ្នាំ២០០៧ និងឆ្នាំ២០១៧**




*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

ក្នុងឆ្នាំ២០០៧ ស្ត្រីភាគច្រើនមានតែនៅក្នុងមុខរបរសំខាន់ៗពីរ (កម្មករសេវាកម្ម និងអ្នកលក់ និងកម្មករកសិកម្ម) ដែលគួរឱ្យចាប់អារម្មណ៍ជាងនេះនៅឆ្នាំ២០១៧ ស្ត្រីក៏ជាអ្នកជំនាញផងដែរ។ នៅឆ្នាំ២០១៧ វត្តមានរបស់ស្ត្រីលើសពី ៤០% ត្រូវបានកត់ត្រាថាជាបុគ្គលិកស្មៀន ខណៈដែលស្ត្រីមានមុខរបរផ្នែកបច្ចេកទេសបានកើនឡើងពី ២៦.៩% ដល់ ៣៦.២%។ ទោះជាយ៉ាងណាក៏ដោយអ្នកគ្រប់គ្រងតិចជាង ១ភាគ៤ គឺជាស្ត្រី (រូបភាព៣០)។

**ការអប់រំ៖** ក្នុងបរិបទដែលទទួលបានការអប់រំកម្រិតទាបរបស់ស្ត្រីក្នុងកម្លាំងពលកម្មនៅតែទាបជាងបុរស។ តាមការសង្កេតឃើញថា នៅឆ្នាំ២០០៧ ស្ទើរតែ ៩៦% នៃស្ត្រីកម្ពុជានៅក្នុងកម្លាំងពលកម្មមានការអប់រំជាកាតព្វកិច្ចជាអតិបរមា ហើយបន្ទាប់ពី១០ឆ្នាំ %នៅតែខ្ពស់ដល់៨៧.៥% ដែលតម្លៃដែលត្រូវគ្នាសម្រាប់បុរស គឺ ៩០.២% និង ៨៣% (តារាង៣២)។

### តារាងទី៣២. ការងារតាមភេទ និងកម្រិតនៃការអប់រំ ឆ្នាំ២០០៧ និងឆ្នាំ២០១៧ និងភាពខុសគ្នា

| | Women | Men | Diff | Women | Men | Diff |
|---|---|---|---|---|---|---|
| None or only some education | 25.2 | 11.8 | **13.5** | 14.7 | 9.4 | **5.3** |
| Primary school not completed | 40.7 | 36.1 | **4.6** | 34.9 | 28.6 | **6.3** |
| Primary school completed | 21.4 | 28.5 | **-7.1** | 24.5 | 27.4 | **-2.9** |
| Lower secondary completed | 8.4 | 13.9 | **-5.5** | 13.4 | 17.6 | **-4.2** |
| Uppe rsecondary completed | 2.7 | 6.5 | **-3.8** | 7 | 9.5 | **-2.5** |
| Post secondary education | 1.3 | 2.8 | **-1.4** | 5.5 | 7.6 | **-2.1** |
| *Compulsory education or less* | 96.0 | 90.7 | ***5.3*** | 87.5 | 82.9 | ***4.6*** |

*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

ការចង្អុលបង្ហាញវិជ្ជមានមួយចំនួនអាចត្រូវបានចេញដោយប្រៀបធៀបការបែងចែក %នៃសមាជិកវ័យក្មេងនៃកម្លាំងពលកម្មដែលមានអាយុពី ១៥-២៤ឆ្នាំជាមធ្យម។ ទិន្នន័យដែលមិនមានសម្រាប់ស្ត្រី និងបុរសដាច់ដោយឡែកបង្ហាញថា យុវជនកំពុងទទួលបានការអប់រំខ្ពស់ជាងឪពុកម្តាយរបស់ពួកគេ ប៉ុន្តែពួកគេក៏បង្ហាញផងដែរថា សមិទ្ធផលទាំងនោះនៅតែទាប (រូបភាព ៣១)។ នៅតែមានយុវជន ៧៣.១% មានការអប់រំជាអតិបរមាធៀបនឹងអត្រាមធ្យម ៨៥.២% សម្រាប់កម្លាំងពលកម្មសរុប ទោះបីជាបានផ្តល់ជាការពិចារណាថាតម្លៃអាចត្រូវបានកែលម្អនៅឆ្នាំបន្ទាប់ក៏ដោយ។

### រូបភាពទី៣១. ការងារសម្រាប់ក្រុមដែលមានអាយុពី ១៥-២៤ឆ្នាំ និងការបែងចែកតាមកម្រិតនៃការអប់រំដែលទទួលបានឆ្នាំ២០១៧




*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

**ការចូលរួមក្នុងទីផ្សារការងារ៖** %នៃស្ត្រីដែលមានការងារធ្វើ គឺទាបជាងបុរស (តាមតារាងទី៣៣)។ ទោះយ៉ាងណាក្នុងរយៈពេលដប់ឆ្នាំក្រោមការពិចារណាអត្រានៃការងាររបស់បុរសបានធ្លាក់ចុះ (ពី ៨៩.៦% មក ៨៨.៨%) ហើយស្ត្រីបានកើនឡើង (ពី ៧៨.៣% ទៅ ៨០.១%) ដូច្នេះ ឌីផេរ៉ង់ស្យែលឥឡូវធ្លាក់ចុះដល់ចំណុច ៨.៧ % (ពី ១១.២)។

### តារាងទី៣៣. អត្រាមានការងារសរុបតាមភេទប្រុស ស្រី និងភាពខុសគ្នាតាមភេទក្នុងឆ្នាំ២០០៧ និងឆ្នាំ២០១៧

| | Men | Women | *Diff.* |
|---|---|---|---|
| 2007 | 89.6 | 78.3 | ***-11.2*** |
| 2017 | 88.8 | 80.1 | ***-8.7*** |

*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

ចំពោះអត្រាការងារជាក់លាក់ទៅតាមអាយុ អត្រាទាំងអស់បានកើនឡើង ប៉ុន្តែក្នុងចំណោមក្រុមអាយុ ១៥-១៩ឆ្នាំ ខណៈពេលដែលអាយុ ២០-២៤ឆ្នាំ នៅតែមានស្ថេរភាពគួរឱ្យកត់សម្គាល់ (-0.១%) (រូបភាព ៣២)។

**រូបភាពទី៣២. អត្រាការងាររបស់ស្ត្រីតាមក្រុមអាយុក្នុងឆ្នាំ២០០៧ និងឆ្នាំ២០១៧ និងភាពខុសគ្នា**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

ចុងបញ្ចប់ភាពខុសគ្នានៃភេទបានកើនឡើងតាមអាយុដែលបង្ហាញថា ស្ត្រីវ័យក្មេងមានទំនោរខ្ពស់ជាងមុនក្នុងទីផ្សារការងារផងដែរក្រៅពីវិស័យកសិកម្ម (រូបភាព៣៣)។

**រូបភាពទី៣៣. អត្រាការងារជាក់លាក់របស់បុរស និងស្ត្រីតាមក្រុមអាយុ និងភាពខុសគ្នាតាមភេទក្នុងឆ្នាំ២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

# ផ្នែកទី៥៖

# សេណារីយ៉ូទីផ្សារការងារ

# ឆ្នាំ២០១៧-២០២៧

# ផ្នែកទី៥.១៖
# សេណារីយ៉ូនៃតម្រូវការពលកម្មក្នុងលក្ខខណ្ឌលំហូរ ឆ្នាំ ២០១៧-២០២៧

## ៥.១ តម្រូវការកម្លាំងពលកម្មក្នុងលក្ខខណ្ឌលំហូរឆ្នាំ២០១៧-២០២៧

ដូចដែលយើងបានពិភាក្សារួចមកហើយ តម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរកំណត់ចំនួនមនុស្សដែលចូលធ្វើការជាលើកដំបូងក្នុងចន្លោះពេលមួយ។ តម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរ គឺជាផលបូកនៃសមាសធាតុពីរ គឺតម្រូវការបន្ថែម និងតម្រូវការជំនួស។ ទី១ កំណត់ពីចំនួនការងារបន្ថែមដែលបង្កើតឡើងដោយប្រព័ន្ធសេដ្ឋកិច្ច[5] ទី២ ចំនួនយុវជនដែលអាចរកការងារធ្វើដែលជាលទ្ធផលនៃការចាកចេញពីមនុស្សដែលមានការងារធ្វើពីមុន[6]។

គោលដៅរបស់យើង គឺដើម្បីផ្តល់សេណារីយ៉ូនៃតម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរតាមកម្រិតនៃការអប់រំសម្រាប់ឆ្នាំ២០១៧-២០២៧។ មុនពេលវិភាគ និងដើម្បីយល់កាន់តែច្បាស់ពីគោលដៅនៃលំហាត់នេះ យើងប៉ាន់ស្មានតម្រូវការកម្លាំងពលកម្មទាក់ទងនឹងលំហូរសម្រាប់រយៈពេលឆ្នាំ២០០៧-២០១៧។

ការវិភាគនេះតម្រូវឱ្យមានទិន្នន័យស្តីពីការងារតាមក្រុមអាយុប្រាំឆ្នាំ និងកម្រិតអប់រំ។ ព័ត៌មាននេះមិនអាចរកបានដោយផ្ទាល់ទេ។ សម្រាប់ឆ្នាំ២០០៧-២០១៧ តាមរបាយការណ៍ CSES ចេញស្ថិតិដូចខាងក្រោម៖

- កម្លាំងពលកម្មសរុបតាមកម្រិតអប់រំ
- អត្រាសកម្មភាពសម្រាប់ក្រុមអាយុដូចខាងក្រោម៖ ១៥-១៩, ២០-២៤, ២៥-៣៤, ៣៥-៤៤, ៤៥-៥៤, ៥៥-៦៤
- សមាសភាព %នៃកម្លាំងពលកម្មរបស់ក្រុមអាយុនីមួយៗតាមកម្រិតនៃការអប់រំ។

ការវិភាគទិន្នន័យដែលបោះពុម្ពផ្សាយដោយ CSES បានបង្ហាញពីវត្តមាននៃភាពបត់បែនមួយចំនួនក៏ដូចជាភាពមិនស៊ីគ្នា។ ដើម្បីប៉ាន់ប្រមាណស្ថិតិចាំបាច់ការសន្មត់ជាបន្តបន្ទាប់ត្រូវបានធ្វើឡើង ខណៈដែលទិន្នន័យអង្គការ UNDESA ស្តីពីចំនួនប្រជាជនដែលមានអាយុធ្វើការតាមក្រុមអាយុត្រូវបានប្រើ ដើម្បីបំពេញចន្លោះប្រហោង ដែលមាននៅក្នុងទិន្នន័យប្រជាសាស្ត្រ CSES។

**ការសន្មត់សំខាន់ៗបានប្រើប្រាស់ ដើម្បីប៉ាន់ប្រមាណទិន្នន័យដែលចាំបាច់សម្រាប់សេណារីយ៉ូ៖**

- យោងតាមរបាយការណ៍របស់ CSES កម្ពុជារងផលប៉ះពាល់ដោយចំនួនអ្នកគ្មានការងារធ្វើ។ លើសពីនេះទៅទៀត មិនមានព័ត៌មានត្រូវបានផ្តល់នៅលើកម្រិតអប់រំរបស់ពួកគេ យើងបានសន្មត់ថាសម្រាប់ភាពសាមញ្ញ ហើយប្រាកដជាមិនបាត់បង់ភាពទូទៅដើម្បីសន្មត់ថា អ្នកគ្មានការងារធ្វើទាំងអស់ជាមនុស្សដែលគ្មានការអប់រំ។ នេះបានអនុញ្ញាតឱ្យផ្លាស់ប្តូរទិន្នន័យនៃកម្លាំងពលកម្មលើទិន្នន័យនៃភាពអត់ការងារធ្វើ។
- រហូតដល់ឆ្នាំ២០១៦ CSES មិនបានផ្តល់ឱ្យដូចអ្វីដែលយើងបានលើកឡើងរួចមកហើយទេ ទំហំនៃកម្លាំងពលកម្មតាមក្រុមអាយុ ប៉ុន្តែមានតែអត្រានៃសកម្មភាពតាមក្រុមអាយុ និងចំនួន %នៃក្រុមអាយុនីមួយៗតាមកម្រិតអប់រំ។ ដើម្បីប៉ាន់ស្មានចំនួនអ្នកមានការងារធ្វើក្នុងក្រុមអាយុនីមួយៗតាមកម្រិតអប់រំ យើងបានប្រើប្រាស់រចនាសម្ព័ន្ធរបស់ WAP ដោយក្រុមអាយុ ៥ឆ្នាំដែលផ្តល់ដោយ UNDESA សម្រាប់ឆ្នាំ២០០៥, ២០១០, ឆ្នាំ២០១៥ និងឆ្នាំ២០២០។

- សម្មតិកម្មទាំងនេះបានអនុញ្ញាតឱ្យប៉ាន់ស្មានទិន្នន័យដែលបានរាយការណ៍នៅលើតារាងទី៣៤ នោះគឺជាកម្រិតការងារតាមក្រុមអាយុ និងកម្រិតអប់រំនៅឆ្នាំ២០០៧, ឆ្នាំ២០១២ និងឆ្នាំ២០១៧។

[5] The additional jobs are in fact the difference between jobs created and jobs destroyed in a given time interval.
[6] The main reason of definitive exits from employment are: death, retirement, migration to another country.

តារាងទី៣៤. ការងារតាមកម្រិតនៃការអប់រំ និងក្រុមអាយុ ឆ្នាំ២០០៧ ឆ្នាំ២០១២ និងឆ្នាំ២០១៧

| | None or only some education | Primary school not completed | Primary school completed | Lower secondary completed | Upper secondary completed | Post secondary education | Total |
|---|---|---|---|---|---|---|---|
| | 2007 (in thousand) | | | | | | |
| 15-19 | 211 | 442 | 288 | 129 | 53 | 24 | 1,147 |
| 20-24 | 67 | 470 | 523 | 171 | 13 | 1 | 1,245 |
| 25-34 | 211 | 530 | 479 | 245 | 103 | 63 | 1,631 |
| 35-44 | 274 | 526 | 325 | 156 | 93 | 43 | 1,417 |
| 45-54 | 206 | 379 | 193 | 96 | 57 | 18 | 949 |
| 55-64 | 135 | 221 | 83 | 40 | 12 | 7 | 498 |
| Total | 1,100 | 2,559 | 1,885 | 835 | 330 | 156 | 6,887 |
| | 2012 (in thousand) | | | | | | |
| 15-19 | 146 | 363 | 293 | 150 | 65 | 29 | 1,046 |
| 20-24 | 61 | 295 | 504 | 272 | 43 | 1 | 1,175 |
| 25-34 | 171 | 586 | 802 | 426 | 263 | 42 | 2,290 |
| 35-44 | 183 | 466 | 409 | 212 | 109 | 85 | 1,462 |
| 45-54 | 185 | 427 | 292 | 136 | 79 | 28 | 1,147 |
| 55-64 | 136 | 283 | 101 | 56 | 13 | 10 | 600 |
| | 881 | 2,419 | 2,400 | 1,251 | 573 | 196 | 7,720 |
| | 2017 (in thousand) | | | | | | |
| 15-19 | 28 | 241 | 390 | 234 | 53 | 7 | 953 |
| 20-24 | 70 | 319 | 429 | 309 | 218 | 140 | 1,485 |
| 25-34 | 245 | 698 | 685 | 409 | 254 | 299 | 2,590 |
| 35-44 | 262 | 567 | 380 | 192 | 105 | 82 | 1,588 |
| 45-54 | 278 | 585 | 278 | 152 | 72 | 34 | 1,399 |
| 55-64 | 167 | 369 | 120 | 63 | 19 | 13 | 751 |
| | 1,050 | 2,779 | 2,281 | 1,361 | 722 | 575 | 8,768 |

*ប្រភព៖ Authors´ Calculation. CSES, UNDESA*

## ៥.១.១ រចនាសម្ព័ន្ធការងារ

### ការប្រែប្រួលរចនាសម្ព័ន្ធមួយចំនួនក្នុងរចនាសម្ព័ន្ធការងាររវាងឆ្នាំ២០០៧ និងឆ្នាំ២០១៧

ទិន្នន័យបានបង្ហាញភ្លាមៗថា កម្រិតការអប់រំរបស់អ្នកមានការងារបានកើនឡើងជាលំដាប់។ បើប្រៀបធៀបស្ថានភាពក្នុងឆ្នាំ២០០៧ និងឆ្នាំ២០១៧ (តារាង៣៥ និងរូបភាពទី៣៤) យើងអាចឃើញថាទម្ងន់នៃក្រុមអប់រំ ៣ ដំបូងបានធ្លាក់ចុះហើយ ៣ ចុងក្រោយបានកើនឡើង។

តារាងទី៣៥. ការងារតាមកម្រិតនៃការអប់រំ (គិតជាខ្ទង់ពាន់) និង%ឆ្នាំ២០០៧ ឆ្នាំ២០១២ និងឆ្នាំ២០១៧

| | 2007 | 2012 | 2017 | 2007 | 2012 | 2017 |
|---|---|---|---|---|---|---|
| | Absolute values in thousand | | | % composition | | |
| None or only some education | 1,100 | 881 | 1,050 | 16.0 | 11.4 | 12.0 |
| Primary school not completed | 2,559 | 2,419 | 2,779 | 37.3 | 31.3 | 31.7 |
| Primary school completed | 1,885 | 2,400 | 2,281 | 27.5 | 31.1 | 26.0 |
| Lower secondary completed | 835 | 1,251 | 1,361 | 12.2 | 16.2 | 15.5 |
| Upper secondary completed | 330 | 573 | 722 | 4.8 | 7.4 | 8.2 |
| Post secondary education | 156 | 196 | 575 | 2.3 | 2.5 | 6.6 |
| Labour force | 6,865 | 7,720 | 8,766 | 100.0 | 100.0 | 100.0 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

ជាលទ្ធផល %នៃការងារដែលមានការអប់រំតិចជាងមធ្យមសិក្សាបឋមភូមិបានធ្លាក់ចុះពី ៨១.៨% មក ៦៩.៧% ខណៈពេលដែល %នៃអ្នកដែលមានការអប់រំបឋមភូមិ និងឧត្តមសិក្សាបានកើនឡើងរៀងៗខ្លួនពី ១១.២% ទៅ ១៥.៥% និងពី ៧.១ ដល់ ១៤.៨% ។

**រូបភាពទី៣៤. ការងារតាមកម្រិតនៃការអប់រំ (គិតជាខ្ទង់ពាន់) និង %ឆ្នាំ២០០៧ ឆ្នាំ២០១២ និងឆ្នាំ២០១៧**




*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

ការផ្លាស់ប្តូររចនាសម្ព័ន្ធដែលពាក់ព័ន្ធមួយទៀត ដែលបានកើតឡើងក្នុងរយៈពេលត្រូវបានពិចារណា គឺការកើនឡើងជាលំដាប់នៃអាយុជាមធ្យមរបស់អ្នកមានការងារធ្វើពី ៣២.៧ឆ្នាំទៅ ៣៤.១ឆ្នាំ។ បាតុភូតនេះកាន់តែលេចធ្លោនៅពេលយើងពិចារណាលើទម្ងន់ដែលទាក់ទងនៃក្រុមអាយុទាំងបី៖ ចំណែកនៃយុវជនបានធ្លាក់ចុះពី ៣៤.៧% ទៅ ២៧.៨% នៃអ្នកធ្វើការនៅក្នុងក្រុមអាយុវ័យកណ្តាល (២៥-៤៤) បានកើនឡើងពី ៤៤.៣% ដល់ ៤៨.៦% និងក្រុមដែលមានវ័យច្រើនជាងគេ (៤៥-៦៤) ពី ២១% ទៅ ២៤.៥% (តារាង៣៦ និងរូបភាព៣៥)។

**តារាងទី៣៦. ចំនួនអ្នកមានការងារធ្វើតាមក្រុមអាយុ តម្លៃដាច់ខាត និងសមាសភាព % អាយុជាមធ្យម និង %នៃក្រុមអាយុ ១៥-២៤ ឆ្នាំ២០០៧, ឆ្នាំ២០១២, និងឆ្នាំ២០១៧**

| | 2007 | 2012 | 2017 | 2007 | 2012 | 2017 |
|---|---|---|---|---|---|---|
| | Absolute values in thousand | | | % composition | | |
| 15-19 | 1,147 | 1,046 | 953 | 16.7 | 13.6 | 10.9 |
| 20-24 | 1,245 | 1,175 | 1,485 | 18.1 | 15.2 | 16.9 |
| 25-34 | 1,631 | 2,290 | 2,590 | 23.7 | 29.7 | 29.5 |
| 35-44 | 1,417 | 1,462 | 1,588 | 20.6 | 18.9 | 18.1 |
| 45-54 | 949 | 1,147 | 1,399 | 13.8 | 14.9 | 16.0 |
| 55-64 | 498 | 600 | 751 | 7.2 | 7.8 | 8.6 |
| Total | 6,887 | 7,720 | 8,766 | 100.0 | 100.0 | 100.0 |
| | Aver. Age | | | % 15-24 | | |
| | 32.7 | 33.5 | 34.1 | 34.7 | 28.8 | 27.8 |

*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

រូបភាពទី៣៥. ចំនួនការងារតាមក្រុមអាយុសំខាន់ៗ និងសមាសភាព %តាមឆ្នាំ២០០៧, ឆ្នាំ២០១២ និងឆ្នាំ២០១៧




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

## តម្រូវការបន្ថែម តម្រូវការជំនួស និងតម្រូវការពលកម្មក្នុងលក្ខខណ្ឌលំហូរឆ្នាំ២០០៧-២០១៧

ការផ្លាស់ប្តូរដែលយើងទើបតែបានសង្កេតឃើញ គឺជាលទ្ធផលនៃភាពខុសគ្នានៃបរិមាណ និងគុណភាពរវាងនិយោជិតដែលបានចាកចេញពីតំបន់ការងារក្នុងអំឡុងឆ្នាំ២០០៧-២០១៧ និងអ្នកដែលបានចូលធ្វើការក្នុងពេលតែមួយ។

យើងសង្កេតមើលថាចន្លោះឆ្នាំ២០០៧ និងឆ្នាំ២០១៧ ទីផ្សារការងារនៅកម្ពុជាបានស្រូបយកយុវជនចំនួន ២.៦៥៩លាននាក់ ហើយ ៧១.៩% (១.៩លាននាក់) នៃការចូលរួមគឺដោយសារតែការបង្កើតការងារបន្ថែម ហើយនៅសល់ ២៨.១% ទៅនឹងការចាកចេញយ៉ាងច្បាស់លាស់របស់កម្មករវ័យចំណាស់ (តារាង៣៧)។ ការចូលរួមចំណែកទាបនៃតម្រូវការជំនួសត្រូវបានកំណត់ឱ្យមានកម្រិតទាបសម្រាប់អ្នកធ្វើការដែលមានវ័យមធ្យម។

**តារាងទី៣៧. Employment; Generational entries by determinants (thousand); 2007-2017**

| | 2007-17 | | |
|---|---|---|---|
| | Total value in thousand | Yearly average in thousand | % composition |
| Additional demand | **1,901** | 190 | *71.9* |
| Replacement demand | **741** | 74 | *28.1* |
| Labour demand in terms of flow | **2,642** | 264 | *100.0* |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

ការចូលរួមក្នុងការងារបានកើតឡើងចំពោះអ្នកដែលមានវ័យក្មេង ហើយភាគច្រើនពួកគេស្ថិតក្នុងក្រុមអាយុពី ១៥-១៩ (៩២.៣%) និងមួយទៀតចន្លោះពី ២០ ទៅ ២៤ឆ្នាំ ហើយប្រកចេញពីរភាគបីត្រូវបានប្រមូលផ្តុំនៅក្នុងក្រុមអាយុ ៥៥-៦៤ និង ២៦% នៅក្នុងចន្លោះអាយុដែលបានលើកឡើងពីមុន (រូបភាព៣៦)។

**រូបភាពទី៣៦. ការងារ តាមវ័យជំនាន់ដែលចូលក្នុងការងារ និងចេញពីការងារទៅតាមក្រុមអាយុ (គិតជាខ្ទង់ពាន់) ចាប់ពីឆ្នាំ២០០៧-២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

លំហូរទៅតាមកម្រិតអប់រំ គឺមានភាពស្មុគស្មាញក្នុងការប៉ាន់ស្មានខណៈដែលពួកគេជាប្រធានបទ ដើម្បីអាចរាប់បានទ្វេដង (អ្នកដែល "ចូលក្នុងវិស័យការងារ" មួយចំនួនមានសញ្ញាបត្រខ្ពស់ជាងនេះ ហើយដោយសារតែអ្នកមានវ័យចូលធ្វើការមិនមានការងារធ្វើ ប៉ុន្តែអ្នកដែលមានការងារធ្វើរួចហើយបានទទួលសញ្ញាបត្រខ្ពស់ជាងមុន។ រូបភាពទី៣៧ បានបង្ហាញពីអ្នកដែលមានវ័យចូល និងចេញពីការងារ (គឺជាអ្នកដែលចូល និងចេញពីការងារមានការរាប់ទ្វេដងដោយសារតែមនុស្សដែលមានការងារធ្វើរួចហើយទទួលបានសញ្ញាបត្រ) ទៅតាមកម្រិតនៃការអប់រំ និងតារាងទី៣៨ ក៏បានបង្ហាញពីសមាសភាពជា%។

**រូបភាពទី៣៧. ការងារ វ័យអ្នកដែលចូលក្នុងវិស័យការងារ ចេញពីវិស័យការងារ និងតុល្យភាព (គិតជាខ្ទង់ពាន់) ឆ្នាំ២០០៧-២០១៧**




*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

**តារាងទី៣៨. ការងារ វ័យអ្នកដែលចូលក្នុងវិស័យការងារ ចេញពីវិស័យការងារ និងតុល្យភាពក្នុងឆ្នាំ២០០៧-២០១៧ និងសមាសភាពជា%ទៅតាមកម្រិតនៃការអប់រំ**

| | None or only some education | Primary school not completed | Primary school completed | Lower secondary completed | Upper secondary completed | Post secondary education | Total |
|---|---|---|---|---|---|---|---|
| | Percentage composition | | | | | | |
| Entries | 4.9 | 20.7 | 25.7 | 20.5 | 14.5 | 13.8 | **100.0** |
| Exits | 15.9 | 34.2 | 32.8 | 10.0 | 5.5 | 1.6 | **100.0** |
| Balance | -2.6 | 11.6 | 20.9 | 27.6 | 20.5 | 22.0 | **100.0** |

*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

ការប្រៀបធៀបរវាងទិន្នន័យទាំងនេះ និងទិន្នន័យតាមក្រុមអាយុបានបង្ហាញថាការរាប់ទ្វេដងមានប្រហែល ៥៤៥,០០០នាក់។ សន្មត់ថាសម្រាប់ភាពសាមញ្ញ ប៉ុន្តែប្រហែលជាសុទិដ្ឋិនិយមថាពួកគេត្រូវនឹងជាអ្នកដែលមានការអប់រំតិចជាងមធ្យមសិក្សាបឋមភូមិ ដែលយើងទទួលបានពីការប៉ាន់ស្មាននៃវ័យដែលចូល និងចេញពីវិស័យការងារទៅតាមកម្រិតអប់រំដែលបានរាយការណ៍នៅក្នុងតារាងទី៣៩ ។

**តារាងទី៣៩. ចំនួនការងារដុលសម្រាប់អ្នកដែលមានវ័យចូល និងចេញពីវិស័យការងារ និងតុល្យភាពទៅតាមកម្រិតនៃការអប់រំ ឆ្នាំ២០០៧-២០១៧**

| | Less than compulsory | Lower secondary completed | Upper secondary completed | Post secondary education | Total |
|---|---|---|---|---|---|
| | Absolute values in thousand | | | | |
| Entries | 1,089 | 653 | 461 | 440 | **2,642** |
| Exits | -521 | -128 | -71 | -21 | **-741** |
| Balance | 567 | 524 | 391 | 419 | **1,901** |
| | Percentge composition | | | | |
| Entries | 41.2 | 24.7 | 17.5 | 16.6 | **100.0** |
| Exits | 70.3 | 17.3 | 9.5 | 2.9 | **100.0** |
| Balance | 29.8 | 27.6 | 20.5 | 22.0 | **100.0** |

*ប្រភព៖ Authors' Calculation.  National Institute of Statistics (2019), CSES*

ទិន្នន័យទាំងនេះបង្ហាញថាប្រហែល ២ភាគ៣ នៃប្រជាជនដែលបានរកការងារធ្វើមានការអប់រំជាកាតព្វកិច្ច ឬតិចជាងនេះ គឺ១៧.៥% មានកម្រិតមធ្យមសិក្សាទុតិយភូមិ និងមានតែ ១៦.៦% ប៉ុណ្ណោះដែលមានសញ្ញាបត្រពីសាកលវិទ្យាល័យ។ ពួកគេក៏ពន្យល់ពីមូលហេតុ និងកម្រិតនៃការអប់រំរបស់និយោជិតបានកើនឡើង។ វាគ្រប់គ្រាន់ដើម្បីសង្កេតមើលថាប្រជាជនជាង ៧០% នៃអ្នកដែលចេញពីវិស័យការងារមានការអប់រំតិចជាងការអប់រំកាតព្វកិច្ច ខណៈពេលនេះមានតែ ៤១% នៃអ្នកដែលចូលវ័យធ្វើការប៉ុណ្ណោះ ហើយនៅពេលដំណាលគ្នាចំនួន%នៃអ្នកដែលមានវ័យចូលធ្វើការ ពួកគេមានកម្រិតការអប់រំខ្ពស់តែងតែធំជាង %ដែលត្រូវគ្នា និងអ្នកដែលមានវ័យចេញពីវិស័យការងារទាំងនោះ។

## ៥.១.២ សេណារីយ៉ូនៃតម្រូវការពលកម្ម

### សេណារីយ៉ូនៃតម្រូវការកម្លាំងពលកម្មក្នុងលក្ខខណ្ឌលំហូរសម្រាប់អំឡុងពេលឆ្នាំ២០១៧-២០២៧

ដើម្បីកសាងសេណារីយ៉ូតម្រូវការកម្លាំងពលកម្មក្នុងរយៈពេល ១០ឆ្នាំ ក្រោយបន្ទាប់ពីឆ្នាំ២០១៧ ដែលជាឆ្នាំមុនដែលព័ត៌មានស្តីពីទីផ្សារការងារ ហើយយើងត្រូវរៀបចំគម្រោងជំនួសតម្រូវការ និងបង្កើតសេណារីយ៉ូតម្រូវការបន្ថែម។

**តម្រូវការជំនួស** ( Replacement demand )

តម្រូវការជំនួសអាចត្រូវបានប៉ាន់ប្រមាណដោយប្រើប្រូបាប៊ីលីតេ ដែលក្រុមអាយុខុសគ្នានឹងត្រូវចាកចេញពីទីផ្សារការងារនៅចន្លោះឆ្នាំ២០១៧ និងឆ្នាំ២០២៧។ យើងអាចសន្មត់ដោយសុវត្ថិភាពថា ប្រជាជនទាំងអស់ក្នុងក្រុមអាយុ ៥៥-៦៤ នឹងចាកចេញពីទីផ្សារការងារ។ បន្ទាប់មកយើងអាចសន្មត់ថាអត្រានៃការចាកចេញសម្រាប់ក្រុមអាយុផ្សេងទៀតដែលបានប៉ាន់ស្មានសម្រាប់រយៈពេលមុននឹងមានដែរ។ តារាងទី៤២ បង្ហាញសម្រាប់ក្រុមអាយុពាក់ព័ន្ធនីមួយៗ អំពីប្រូបាប៊ីលីតេ នៃការចាកចេញពីទីផ្សារការងារក្នុងអំឡុងពេល ១០ឆ្នាំ (ឆ្នាំ២០១៧-២០២៧) ចំនួនអ្នកធ្វើការនៅឆ្នាំចាប់ផ្តើម និងចំនួនប៉ាន់ស្មាននៃការចាកចេញពីទីផ្សារការងារ។

យើងអាចសង្កេតឃើញភ្លាមៗថា ចំនួននៃការចាកចេញពីទីផ្សារការងារដែលបានប៉ាន់ស្មាន (១,០៤៥លាន) គឺមានចំនួនច្រើនជាងចំនួនមុន។ នេះដោយសារតែដំណើរការវ័យចំណាស់ដែលកំពុងជះឥទ្ធិពលដល់ប្រជាជនកម្ពុជា ជាពិសេសជាងនេះទៅទៀត គឺប្រជាជនដែលមានអាយុធ្វើការហើយនឹងមានការងារធ្វើ (តារាង៤០)។

**តារាងទី៤០. ចំនួនអ្នកមានការងារធ្វើតាមក្រុមអាយុ ប្រូបាប៊ីលីតេចំពោះអ្នកចេញពីទីផ្សារការងារសម្រាប់ក្រុមនីមួយៗក្នុងឆ្នាំ២០១៧ និងបានប៉ាន់ប្រមាណចំនួនអ្នកចេញពីទីផ្សារការងារសម្រាប់អំឡុងឆ្នាំ២០១៧-២០២៧ (គិតជាខ្ទង់ពាន់)**

| | Prob. to exit the LM | Employed 25-64 in 2017 | Exits 2017-27 |
|---|---|---|---|
| 25-34 | -1.8 | 2,590 | -46 |
| 35-44 | -0.7 | 1,588 | -12 |
| 45-54 | -16.9 | 1,399 | -237 |
| 55-64 | -100.0 | 751 | -751 |
| Total | -16.5 | 6,328 | -1,045 |

*ប្រភព៖ Authors' Calculation. National Institute of Statistics (2019), CSES*

### តម្រូវការបន្ថែម

ចំនួនការងារដែលនឹងត្រូវបានបង្កើតឡើងដោយសេដ្ឋកិច្ចកម្ពុជា នឹងអាស្រ័យលើអត្រាកំណើនផលិតកម្ម និងអត្រានៃកំណើនផលិតភាពដែលពីមុនពឹងផ្អែកយ៉ាងធំធេងលើបរិមាណ និងប្រភេទនៃការវិនិយោគផ្ទាល់ក្នុងស្រុក និងបរទេស ព្រមទាំងលើពាណិជ្ជកម្មអន្តរជាតិ ដែលក្រោយមកទៀតនឹងបណ្តាលមកពីបច្ចេកវិទ្យាល្អប្រសើរជាងមុន ការអប់រំកាន់តែប្រសើរ មានការងារកាន់តែប្រសើរ អង្គការការងារកាន់តែប្រសើរ និងការឆ្លងកាត់រចនាសម្ព័ន្ធផលិតកម្មទៅជាក្រុមបច្ចេកវិទ្យាខ្ពស់ជាងមុន។

រយៈពេលដែលយើងនឹងពិចារណាបង្ហាញថា វិធីសាស្រ្តគួរឱ្យចាប់អារម្មណ៍ និងត្រឹមត្រូវបំផុតគឺការកសាងសេណារីយ៉ូ។ ខណៈពេលដែលការព្យាករណ៍ជាទូទៅត្រូវបានកំណត់ត្រឹមតែតម្លៃ និងការព្យាករណ៍ គឺជាការប៉ាន់ប្រមាណដែលមានភ្ជាប់ប្រូបាប៊ីលីតេ និងសេណារីយ៉ូត្រូវបានបង្កើតឡើងដោយពិចារណាលើស៊េរីតម្លៃជំនួសនៃអថេរគោលការណ៍

ពាក់ព័ន្ធក្នុងករណីផលិតកម្ម និងផលិតភាព។ ដើម្បីធ្វើដូច្នេះពួកគេអនុញ្ញាតឱ្យពិភាក្សាអំពីផលវិបត្តិសេដ្ឋកិច្ចសង្គមដែលជាជម្រើសនៃផ្លូវអភិវឌ្ឍន៍។

ដើម្បីជ្រើសរើសតម្លៃទាំងនេះ ដើម្បីពិចារណាដែលមានសារៈសំខាន់ពីរ៖ ទីមួយការវិវត្តន៍របស់ពួកគេនៅក្នុងរយៈពេលពីមុន និងការចង្អុលបង្ហាញទីពីរដែលផ្តល់ដោយវិទ្យាស្ថានជាតិ និងអន្តរជាតិ។

តារាងទី៤១ បង្ហាញពីទិន្នន័យដែលបានបន្ថែមដុលគឺការងារ និងផលិតភាពតាមវិស័យក្នុងអំឡុងឆ្នាំ២០០៧-២០១៧។ ជាតុសំខាន់ៗដែលលេចចេញមក គឺផលិតកម្មនៅកម្ពុជាមានការកើនឡើងជាក់ស្តែង ៨២% និងការងារ ២៨.៣%។ នេះបង្ហាញពីភាពបត់បែននៃប្រាក់ចំណូលការងារ ០.៣៤% ដែលបង្ហាញថាការកើនឡើង ១% នៃផលិតកម្មនាពេលបច្ចុប្បន្ននឹងបង្កើតឱ្យមានការងារបន្ថែមប្រមាណ ៣ ម៉ឺននាក់។

**តារាងទី៤១. ផលិតកម្ម (គិតជាពាន់លានរៀល) ការងារ (គិតជាខ្ទង់ពាន់) និងផលិតភាពតាមវិស័យ (គិតជាដុល្លារ) តម្លៃប្រចាំឆ្នាំ (ឆ្នាំ២០០៧-២០១៧) បម្រែបម្រួលជាច់ខាត និងបម្រែបម្រួលជា%**

| | Gross value added | | | | Employment | | | | Productivity | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Agriculture | Industry | Services | Total | Agriculture | Industry | Services | Total | Agriculture | Industry | Services | Total |
| 2007 | 7,174 | 7,564 | 10,289 | 25,027 | 3,946 | 1,019 | 1,871 | 6,837 | 454 | 1,855 | 1,375 | 915 |
| **Agriculture, forestry and fishery** | **40,000** | Agricultre engineer, Soil and plant specialist, Agriculture food scientist, Agronomist, Horticulture technician, Hydraiulics technician, Wildlife and forestry management and conservation, Fisheries bilogist, Fisheries manager, | |
| **Plant and machine operators and assemblers** | **27,000** | Industrial and production engineers, Mechanical engineers; Steam engine and boiler operators, Mechanical machinery assemblers, Machinery mechanics and repairers, Heavy truck and lorry drivers. | |
| **Technicians and professionals** | **41,000** | | |
| *Health sector* | | Radiographers, Medical and pathology laboratory technician, Dental assistant, Midwifes | |
| *Tourism* | | Translators and interpreters; Accountants and marketing professionals. | |
| *IT sector* | | ICT user support technicians, System analysts and IT architects, Software and system developers, ICT operations technicians, Database and network professionals, Information technology trainers, Computer network and systems technicians | |

*ប្រភព៖ Authors' estimates based on data from National Institute of Statistics (2019), CSES and NEA, Cambodia Job Outlook, 2018*

## ៦.៣ ផ្នែកផ្គត់ផ្គង់៖ ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)

ដោយបានផ្តល់នូវការប៉ាន់ស្មានខ្លះៗនៃជំនាញដែលនឹងត្រូវបានស្នើសុំដោយទីផ្សារការងារ ឥឡូវនេះសូមធ្វើការវិភាគលើការផលិតនៃប្រព័ន្ធបណ្តាញ TVET និងនិន្នាការរបស់ TVET ដើម្បីវាយតម្លៃភាពជាប់ទាក់ទងនឹងតម្រូវការការងារ និងទិសដៅដែលវាគួរតែវិវត្តន៍ដោយចាប់ផ្តើមពីវគ្គសិក្សាវិញ្ញាបនបត្រ ហើយបន្ទាប់មកផ្លាស់ទៅឧត្តមសិក្សា។

### ៦.៣.១ ការចុះឈ្មោះចូលរៀន និងវគ្គបណ្តុះបណ្តាល (C១, C២ និង C៣)

ការចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលរយៈពេលវែងបានកើនឡើងជាលំដាប់ពីសិស្សចំនួន ៤០០នាក់ ក្នុងឆ្នាំសិក្សា ២០១២-១៣ ដល់ ៣,៦៣០នាក់ ក្នុងឆ្នាំសិក្សា ២០១៨-២០១៩។

**តារាងទី៥៨. ការចុះឈ្មោះចូលរៀនក្នុងវគ្គបណ្តុះបណ្តាលវិញ្ញាបនបត្រតាមភេទចាប់ពីឆ្នាំសិក្សា ២០១២-២០១៣ ដល់ឆ្នាំសិក្សា ២០១៨-២០១៩**

| | Enrolment | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | C1 | | | C2 | | | C3 | | | Total | | |
| | Males | Females | Total | Males | Females | Total | Males | Females | Total | Males | Females | Total |
| 2018-19 | 1,727 | 607 | 2,334 | 675 | 149 | 824 | 395 | 77 | 472 | 2,797 | 833 | 3,630 |
| 2017-18 | 1,703 | 623 | 2,326 | 484 | 85 | 569 | 262 | 58 | 320 | 2,449 | 766 | 3,215 |
| 2016-17 | 1,416 | 531 | 1,947 | 387 | 66 | 453 | 232 | 42 | 274 | 2,035 | 639 | 2,674 |
| 2015-16 | 1,120 | 358 | 1,478 | 268 | 41 | 309 | 180 | 23 | 203 | 1,568 | 422 | 1,990 |
| 2014-15 | 580 | 171 | 751 | 116 | 22 | 138 | 143 | 20 | 163 | 839 | 213 | 1,052 |
| 2013-14 | 270 | 94 | 364 | 100 | 20 | 120 | 82 | 21 | 103 | 452 | 135 | 587 |
| 2012-13 | 123 | 23 | 146 | 152 | 27 | 179 | 64 | 20 | 84 | 339 | 70 | 409 |

*ប្រភព៖ TVETMIS, MLVT*

ការចុះឈ្មោះចូលរៀននៅ C១ តែងតែមានចំនួនភាគច្រើននៃការចុះឈ្មោះសរុបនៅក្នុងវគ្គសិក្សាវិញ្ញាបនបត្រដែលមានអត្រាស្មើតែ ៧៥% ក្នុងឆ្នាំសិក្សា ២០១៥-២០១៦។ ចាប់តាំងពីពេលនោះមកវាមានការថយចុះជាលំដាប់ ហើយនៅក្នុងឆ្នាំសិក្សា ២០១៨-២០១៩ ការចុះឈ្មោះចូលរៀននៅ C១ មានចំនួន ៦៤.៣% នៃការចុះឈ្មោះចូលរៀនសរុបដែលមានចំនួន ២២.៧% ក្នុង C២ និងនៅក្នុង C៣ មានតែ ១៣%ប៉ុណ្ណោះ។

**តារាងទី៥៩. ការចុះឈ្មោះចូលរៀនតាមភេទ និងសមាសភាពជា%តាមកម្រិតចាប់ពីឆ្នាំសិក្សា ២០១២-២០១៣ ដល់ឆ្នាំសិក្សា ២០១៨-២០១៩**

| | C1 | | | C2 | | | C3 | | |
|---|---|---|---|---|---|---|---|---|---|
| | Males | Females | Total | Males | Females | Total | Males | Females | Total |
| 2018-19 | 61.7 | 72.9 | 64.3 | 24.1 | 17.9 | 22.7 | 14.1 | 9.2 | 13.0 |
| 2017-18 | 69.5 | 81.3 | 72.3 | 19.8 | 11.1 | 17.7 | 10.7 | 7.6 | 10.0 |
| 2016-17 | 69.6 | 83.1 | 72.8 | 19.0 | 10.3 | 16.9 | 11.4 | 6.6 | 10.2 |
| 2015-16 | 71.4 | 84.8 | 74.3 | 17.1 | 9.7 | 15.5 | 11.5 | 5.5 | 10.2 |
| 2014-15 | 69.1 | 80.3 | 71.4 | 13.8 | 10.3 | 13.1 | 17.0 | 9.4 | 15.5 |
| 2013-14 | 59.7 | 69.6 | 62.0 | 22.1 | 14.8 | 20.4 | 18.1 | 15.6 | 17.5 |
| 2012-13 | 36.3 | 32.9 | 35.7 | 44.8 | 38.6 | 43.8 | 18.9 | 28.6 | 20.5 |

*ប្រភព៖ TVETMIS, MLVT*

វគ្គមានរបស់ស្ត្រីតែងតែមានការធ្លាក់ចុះ ១ភាគ៤ ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានចំនួនប្រមាណជា២៣%។ លើសពីនេះទៅទៀត វាធ្លាក់ចុះពី C១ ទៅ C២ ដល់ C៣។ នៅក្នុងឆ្នាំសិក្សាចុងក្រោយវាមាន ២៦% នៅក្នុង C១ ក្នុង C២ មាន ១៨.១% និងនៅក្នុង C៣ មាន១៦.៣%។

**តារាងទី៦០. ការចុះឈ្មោះចូលរៀនក្នុងវគ្គវិញ្ញាបនបត្រ %នៃស្ត្រីចាប់ពីឆ្នាំសិក្សា ២០១២-២០១៣ ដល់ឆ្នាំសិក្សា ២០១៨-២០១៩**

| | C1 | C2 | C3 | Total |
|---|---|---|---|---|
| 2018-19 | 26.0 | 18.1 | 16.3 | **22.9** |
| 2017-18 | 26.8 | 14.9 | 18.1 | **23.8** |
| 2016-17 | 27.3 | 14.6 | 15.3 | **23.9** |
| 2015-16 | 24.2 | 13.3 | 11.3 | **21.2** |
| 2014-15 | 22.8 | 15.9 | 12.3 | **20.2** |
| 2013-14 | 25.8 | 16.7 | 20.4 | **23.0** |
| 2012-13 | 15.8 | 15.1 | 23.8 | **17.1** |

*ប្រភព៖ TVETMIS, MLVT*

នៅក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ប្រព័ន្ធ TVET បានផ្តល់ជូន ១៧៣វគ្គ នៅក្នុងមុខវិជ្ជាចំនួន១៣។ វគ្គសិក្សាត្រូវបានគេផ្តោតអារម្មណ៍នៅកម្រិត C១ និងនៅក្នុងតំបន់មួយចំនួន។ តាមពិត ១០៧វគ្គ (៦១.៨%) ត្រូវបានធ្វើឡើងនៅកម្រិត C១, ៣៨វគ្គ (២២%) នៅកម្រិត C២, និង ២៨វគ្គ (១៦.២%) នៅកម្រិត C៣។ លើសពីនេះទៅទៀតច្រើនជាង ៣/៤ ទាក់ទងទៅនឹងមុខវិជ្ជាចំនួន ៤ គឺ ៣១.៨% ផ្នែកអគ្គិសនី ២០.២% បច្ចេកវិទ្យាព័ត៌មាន ១៥% រថយន្ត និង ១១.៦% វគ្គវិស្វករ។ ប្រហែល ៥៣% ទាក់ទងនឹងវិស័យសំណង់ ២៣% ព័ត៌មានវិទ្យា និងច្រើនជាង ២០% ជាងលោហៈ និងរថយន្ត។ មានតែ ១ វគ្គប៉ុណ្ណោះដែលត្រូវបានផ្តោតលើវិស័យទេសចរណ៍ ហើយមានតែមួយមុខគត់សម្រាប់កសិកម្ម (តារាង៦១)។

**តារាងទី៦១. វគ្គបណ្តុះបណ្តាល TVET តាមជំនាញឆ្នាំសិក្សា ២០១៧-២០១៨**

| | | Courses | | | | |
|---|---|---|---|---|---|---|
| | | C1 | C2 | C3 | Total | |
| 1 | Electricity | 29 | 15 | 11 | **55** | ***31.8*** |
| 2 | Information Technology | 22 | 8 | 5 | **35** | ***20.2*** |
| 3 | Automobile | 16 | 7 | 3 | **26** | ***15.0*** |
| 4 | Civil Engineering | 12 | 4 | 4 | **20** | ***11.6*** |
| 5 | Air Conditioning | 12 | | | **12** | ***6.9*** |
| 6 | Welding | 5 | | | **5** | ***2.9*** |
| 7 | Mechanical | 4 | 3 | 2 | **9** | ***5.2*** |
| 8 | Graphic Design | 3 | | 1 | **4** | ***2.3*** |
| 9 | Electronic | 3 | | | **3** | ***1.7*** |
| 10 | Tourism And Hospitality | 1 | | | **1** | ***0.6*** |
| 11 | Metal Engineering | | 1 | | **1** | ***0.6*** |
| 12 | Business Information Technology | | | 1 | **1** | ***0.6*** |
| 13 | Veterinary Science | | | 1 | **1** | ***0.6*** |
| | Total | 107 | 38 | 28 | **173** | ***100.0*** |
| | | ***61.8*** | ***22.0*** | ***16.2*** | ***100.0*** | |

*ប្រភព៖ TVETMIS, MLVT*

ទិន្នន័យស្តីពីការចុះឈ្មោះតាមវគ្គសិក្សាដែលមានលក្ខណៈកាន់តែច្បាស់លក្ខណៈដូចគ្នា (ការផ្តោតទៅលើកម្រិត C១ ហើយក្នុង ៤ មុខវិជ្ជា) បានលេចចេញនូវការវិភាគពីចំនួនវគ្គសិក្សា (តារាង៦២)។ ការចុះឈ្មោះចូលរៀនសរុបមានចំនួនជិត ៣,៨០០នាក់។ ៧២.៦% នៃពួកគេបានចូលរួមវគ្គ C១ វគ្គ C២ មាន១៧.៨% ហើយមានតែ ៩.៥% ក្នុងវគ្គ C៣ ប៉ុណ្ណោះ។ ច្រើនជាង ៨០% នៃការចុះឈ្មោះត្រូវបានគេប្រមូលផ្តុំនៅក្នុង ៤ ជំនាញ គឺអគ្គិសនី ២៧.២% បច្ចេកវិទ្យាព័ត៌មាន ២៦,៩% វិស្វកម្មសំណង់ស៊ីវិល ១២,៩% និងយានយន្ត ១៤,៦%។

ទីបំផុតនិស្សិតប្រមាណ ៤៩% បានចុះឈ្មោះចូលរៀននៅក្នុងវិស័យដែលទាក់ទងនឹងវិស័យសំណង់ ៣១% ទាក់ទងនឹងព័ត៌មានវិទ្យា និងជិត ២០% ចូលរៀនជំនាញលោហៈ និងរថយន្ត។ វគ្គសិក្សាផ្តោតលើវិស័យទេសចរណ៍ត្រូវបានចូលរួមដោយនិស្សិតដែលមានតែ ៩នាក់ និងផ្នែកពេទ្យសត្វមានតែ ៦នាក់ប៉ុណ្ណោះ។

**តារាងទី៦២. ការចុះឈ្មោះចូលរៀនវគ្គវិញ្ញាបនបត្រក្នុងឆ្នាំសិក្សា ២០១៧-២០១៨**

| | | Enrolled | | | | |
|---|---|---|---|---|---|---|
| | | C1 | C2 | C3 | Total | |
| 1 | Electricity | 803 | 183 | 125 | 1111 | 29.5 |
| 2 | Information Technology | 793 | 101 | 39 | 933 | 24.8 |
| 3 | Automobile | 430 | 77 | 24 | 531 | 14.1 |
| 4 | Civil Engineering | 381 | 125 | 56 | 562 | 14.9 |
| 5 | Air Conditioning | 179 | | | 179 | 4.8 |
| 6 | Welding | 87 | | | 87 | 2.3 |
| 7 | Mechanical | 116 | 31 | 15 | 162 | 4.3 |
| 8 | Graphic Design | 108 | | 9 | 117 | 3.1 |
| 9 | Electronic | 24 | | | 24 | 0.6 |
| 10 | Tourism And Hospitality | 9 | | | 9 | 0.2 |
| 11 | Metal Engineering | 9 | 9 | | 18 | 0.5 |
| 12 | Business Information Technology | 11 | | 11 | 22 | 0.6 |
| 13 | Veterinary Science | 3 | | 3 | 6 | 0.2 |
| | Total | 2953 | 526 | 282 | 3761 | 100.0 |
| | | 78.5 | 14.0 | 7.5 | 100.0 | |

*ប្រភព៖ TVETMIS, MLVT*

វគ្គមានរបស់ស្ត្រីគឺតិចតួច ដូចនេះពួកគេតំណាងឱ្យតែ ៨.២% នៃការចុះឈ្មោះចូលរៀនសរុប។ លើសពីនេះទៅទៀត វគ្គមានរបស់ពួកគេត្រូវបានប្រមូលផ្តុំជា២វគ្គ គឺអគ្គិសនី និងបច្ចេកវិទ្យាព័ត៌មាន។ អត្រាទី១ មានចំនួន ៥០.២% នៃស្ត្រីសរុបដែលចុះឈ្មោះចូលរៀន និងទី២ មានចំនួន ២៤.៤%។ ២៥%ទៀតដែលនៅសល់ត្រូវបានពន្យល់ជាចម្បងថាពួកគេចូលរៀនយន្តសាស្ត្រ វិស្វកម្មសំណង់ស៊ីវិល ជួសជុលបរិក្ខារត្រជាក់ និងម៉ាស៊ីនផ្សារ។

**តារាងទី៦៣. ចំនួនស្ត្រីចូលរៀនតាមវគ្គ តម្លៃដាច់ខាត percentage incidence and percentage composition ក្នុងឆ្នាំសិក្សា ២០១៧-២០១៨**

| | Enrolled | | |
|---|---|---|---|
| | Abs. value | % Inc. | % comp. |
| Electricity | 154 | 16.5 | 50.2 |
| Information Technology | 75 | 6.8 | 24.4 |
| Automobile | 22 | 3.9 | 7.2 |
| Civil Engineering | 18 | 3.4 | 5.9 |
| Air Conditioning | 13 | 11.1 | 4.2 |
| Welding | 12 | 6.7 | 3.9 |
| Mechanical | 5 | 5.7 | 1.6 |
| Graphic Design | 4 | 2.5 | 1.3 |
| Electronic | 3 | 12.5 | 1.0 |
| Tourism And Hospitality | 1 | 11.1 | 0.3 |
| Total | 307 | 8.2 | 100.0 |

*ប្រភព៖ TVETMIS, MLVT*

### ៦.៣.២ សិស្សដែលបញ្ចប់ការសិក្សាជំនាញ (C១, C២ និង C៣)

ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ និស្សិតបញ្ចប់ការសិក្សាពីវគ្គសិក្សាផ្លូវការមានចំនួន ២,១៦៨នាក់ តំណាងឱ្យប្រមាណ ២/៣ នៃអ្នកចុះឈ្មោះ។ អត្រាជោគជ័យ គឺខ្ពស់ជាងស្ត្រីបន្តិចបើធៀបនឹងបុរស ហើយមានកម្រិតទាបមិនធម្មតាចំពោះ C២ ។

**តារាងទី៦៤. ចំនួនសិស្សដែលបញ្ចប់វគ្គបណ្តុះបណ្តាលតាមភេទ និងកម្រិត តម្លៃដាច់ខាត និង Incidence លើការចុះឈ្មោះចូលរៀនឆ្នាំសិក្សា ២០១៧-២០១៨**

| | Males | Females | Total | Males | Females | Total |
|---|---|---|---|---|---|---|
| C1 | 1,220 | 440 | 1,660 | *71.6* | *70.6* | *71.4* |
| C2 | 212 | 58 | 270 | *43.8* | *68.2* | *47.5* |
| C3 | 186 | 52 | 238 | *71.0* | *89.7* | *74.4* |
| Total | 1,618 | 550 | 2,168 | *66.1* | *71.8* | *67.4* |

*ប្រភព៖ TVETMIS, MLVT*

## ៦.៤ ឧត្តមសិក្សា

### ៦.៤.១ ការចុះឈ្មោះចូលរៀន

ការចុះឈ្មោះចូលរៀននៅឧត្តមសិក្សារបស់ TVET មានចំនួនជិត ២៨,០០០នាក់។ ទិន្នន័យបានបង្ហាញថា និស្សិត ២/៣ ត្រូវបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រ និង ១/៣ លើកម្មវិធីបរិញ្ញាបត្ររង ហើយការចុះឈ្មោះចូលរៀនមានភាគច្រើនចំពោះក្មេងប្រុស ហើយក្មេងស្រីដែលតំណាងឱ្យក្នុងករណីនេះតិចជាង ១/៤ នៃការចុះឈ្មោះសរុប។ លើសពីនេះទៅទៀត ពួកគេតំណាងឱ្យតែ ១៤% នៃការចុះឈ្មោះចូលរៀនថ្នាក់អនុបណ្ឌិត។

ដើម្បីធ្វើការបកស្រាយទិន្នន័យទាំងនេះ គួរតែត្រូវបានគេចងចាំថាយោងទៅតាមបទបញ្ញត្តិរបស់ប្រទេសកម្ពុជា និស្សិតដែលបានបញ្ចប់ការសិក្សានៅវិទ្យាល័យអាចចុះឈ្មោះចូលរៀននៅបរិញ្ញាបត្ររង ឬក៏បរិញ្ញាបត្រ ប៉ុន្តែកម្មវិធីបរិញ្ញាបត្ររងក៏នឹងទទួលយកសិស្សដែលមិនបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិផងដែរ។ និស្សិតបញ្ចប់កម្មវិធីបរិញ្ញាបត្ររងអាចចុះឈ្មោះចូលរៀនឆ្នាំទី២ ឬទី៣ នៃកម្មវិធីបរិញ្ញាបត្រ។ លើសពីនេះទៀត ទិន្នន័យចុះឈ្មោះចូលរៀនគឺសំដៅទៅលើសកម្មភាពរដ្ឋបាល និងមិនមែនសម្រាប់និស្សិតនោះទេ ដូច្នេះ ទិន្នន័យចុះឈ្មោះចូលរៀនមានចំនួនច្រើនលើសចំនួនសិស្សដែលបានចុះឈ្មោះ។

**តារាងទី៦៥. ចំនួនចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សាក្នុង TVET តាមភេទ និងកម្រិតឆ្នាំសិក្សា ២០១៧-២០១៨**

| | Enrollment | | | |
|---|---|---|---|---|
| | Males | Females | Total | Fem |
| Diploma | 6,731 | 2,128 | 8,859 | **24.0** |
| Bachelor | 13,610 | 4,435 | 18,045 | **24.6** |
| Master | 153 | 25 | 178 | **14.0** |
| Total | 20,494 | 6,588 | 27,082 | **24.3** |
| Diploma | *32.8* | *32.3* | *32.7* | |
| Bachelor | *66.4* | *67.3* | *66.6* | |
| Master | *0.7* | *0.4* | *0.7* | |
| Total | *100.0* | *100.0* | *100.0* | |

*ប្រភព៖ TVETMIS, MLVT*

## ៦.៤.២ សិស្សដែលបញ្ចប់ការសិក្សា

យោងតាមព័ត៌មានដែលអាចរកបាន ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សារបស់ TVET សម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨ គឺស្មើនឹង ១០,៤៨១នាក់ (តារាង៦៥)។ វិស័យសាធារណៈមានចំនួន ៨៤.៥% វិស័យឯកជន ៩.៦% និងអង្គការក្រៅរដ្ឋាភិបាល ៦% (រូបភាព៤០)។ ក្នុងករណីបរិញ្ញាបត្ររង និងបរិញ្ញាបត្រ ចំណែកនៃវិស័យសាធារណៈ គឺប្រហាក់ប្រហែលនឹងចំនួនសរុប។ ទម្ងន់នៃវិស័យឯកជនទំនងជាវិជ្ជមានដែលទាក់ទងទៅនឹងកម្រិតអប់រំ (៤.៤% សម្រាប់បរិញ្ញាបត្ររង ១៣.៨% សម្រាប់បរិញ្ញាបត្រ និង ៤៧.១% សម្រាប់អនុបណ្ឌិត)។ ទម្ងន់របស់ NGOs បង្ហាញពីនិន្នាការផ្ទុយគ្នាដោយថយចុះជាមួយនឹងកម្រិតអប់រំ (១១.៤% សម្រាប់បរិញ្ញាបត្ររង ១.២% សម្រាប់បរិញ្ញាបត្រ)។ បើយើងពិចារណាលើប្រភេទសញ្ញាបត្រ ៤៦.៨% នៃនិស្សិតបញ្ចប់ការសិក្សាទទួលបានសញ្ញាបត្ររង ៥២.៧% បរិញ្ញាបត្រ ហើយមានតែ ០.៥% អនុបណ្ឌិត ឬបណ្ឌិតប៉ុណ្ណោះ។

**រូបភាពទី៤៣. ចំនួននិស្សិតដែលបញ្ចប់ការសិក្សាតាមកម្រិត និងតាមប្រភេទគ្រឹះស្ថានក្នុងឆ្នាំសិក្សា ២០១៧-២០១៨**



| | Associate | Bachelor | Master | Total |
|---|---|---|---|---|
| Public | 84.2 | 85.0 | 52.9 | 84.5 |
| Private | 4.4 | 13.8 | 47.1 | 9.6 |
| NGO | 11.4 | 1.2 | | 6.0 |

| | Public | Private | NGO | Total |
|---|---|---|---|---|
| Associate | 46.7 | 21.7 | 89.4 | 46.8 |
| Bachelor | 53.0 | 75.9 | 10.6 | 52.7 |
| Master | 0.3 | 2.4 | 0.0 | 0.5 |

*ប្រភព៖ TVETMIS, MLVT*

សមាមាត្រនេះមានស្ទើរតែទាំងស្រុងសម្រាប់វិស័យសាធារណៈ ខណៈពេលដែលវិស័យឯកជន ២១.៧% នៃនិស្សិតបញ្ចប់ការសិក្សាទទួលបានសញ្ញាប័ត្ររង ៧៥.៩% បរិញ្ញាបត្រ និង ២,៤% សញ្ញាបត្រខ្ពស់ជាងនេះ។ ទីបំផុតក្នុងករណី NGOs មាន ៨៩.៤% នៃនិស្សិតបញ្ចប់ការសិក្សាទទួលបានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស និង ១០.៦% ទទួលបានបរិញ្ញាបត្រ។

តារាងទី៦៦. ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាតាមភេទ កម្រិតអប់រំ និងប្រភេទគ្រឹះស្ថានចាប់ពីឆ្នាំសិក្សា២០១២-២០១៣ ដល់ឆ្នាំសិក្សា២០១៧-២០១៨

| | Males | | | | Females | | | | Total | | | | Female/Total | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Associate | Bachelor | Master Phd | Total | Associate | Bachelor | Master Phd | Total | Associate | Bachelor | Master Phd | Total | Associate | Bachelor | Master Phd | Total |
| | Public | | | | | | | | | | | | | | | |
| 2017-18 | 3,113 | 2,866 | 25 | 6,004 | 1,020 | 1,830 | 2 | 2,852 | 4,133 | 4,696 | 27 | 8,856 | 24.7 | 39.0 | 7.4 | 32.2 |
| 2016-17 | 2,619 | 4,567 | 17 | 7,203 | 906 | 1,860 | 1 | 2,767 | 3,525 | 6,427 | 18 | 9,970 | 25.7 | 28.9 | 5.6 | 27.8 |
| 2015-16 | 1,444 | 2,102 | | 3,546 | 244 | 709 | | 953 | 1,688 | 2,811 | | 4,499 | 14.5 | 25.2 | | 21.2 |
| 2014-15 | 1,400 | 1,966 | 6 | 3,372 | 250 | 622 | | 872 | 1,650 | 2,588 | 6 | 4,244 | 15.2 | 24.0 | 0.0 | 20.5 |
| 2013-14 | 1,417 | 3,025 | 35 | 4,477 | 413 | 1,119 | 13 | 1,545 | 1,830 | 4,144 | 48 | 6,022 | 22.6 | 27.0 | 27.1 | 25.7 |
| 2012-13 | 2,349 | 2,169 | 86 | 4,604 | 381 | 526 | 11 | 918 | 2,730 | 2,695 | 97 | 5,522 | 14.0 | 19.5 | 11.3 | 16.6 |
| | Public | | | | | | | | | | | | | | | |
| 2017-18 | 149 | 403 | 19 | 571 | 68 | 357 | 5 | 430 | 217 | 760 | 24 | 1,001 | 31.3 | 47.0 | 20.8 | 43.0 |
| 2016-17 | 178 | 721 | 26 | 925 | 128 | 645 | 3 | 776 | 306 | 1,366 | 29 | 1,701 | 41.8 | 47.2 | 10.3 | 45.6 |
| 2015-16 | 283 | 1,034 | | 1,318 | 192 | 934 | | 1,126 | 475 | 1,968 | 1 | 2,444 | 40.4 | 47.5 | | 46.1 |
| 2014-15 | 206 | 724 | 20 | 950 | 92 | 556 | 5 | 653 | 298 | 1,280 | 25 | 1,603 | 30.9 | 43.4 | 20.0 | 40.7 |
| 2013-14 | 260 | 766 | | 1,026 | 106 | 431 | | 537 | 366 | 1,197 | | 1,563 | 29.0 | 36.0 | | 34.4 |
| 2012-13 | 303 | 84 | | 387 | 140 | 37 | | 177 | 443 | 121 | | 564 | 31.6 | 30.6 | | 31.4 |
| | NGO | | | | | | | | | | | | | | | |
| 2017-18 | 311 | 22 | | 333 | 247 | 44 | | 291 | 558 | 66 | | 624 | 44.3 | 66.7 | #DIV/0! | 46.6 |
| 2016-17 | 212 | 43 | | 255 | 136 | 48 | | 184 | 348 | 91 | | 439 | 39.1 | 52.7 | #DIV/0! | 41.9 |
| 2015-16 | 401 | 19 | | 420 | 204 | 27 | | 231 | 605 | 46 | | 651 | 33.7 | 58.7 | | 35.5 |
| 2014-15 | 488 | 22 | | 510 | 129 | 20 | | 149 | 617 | 42 | | 659 | 20.9 | 47.6 | #DIV/0! | 22.6 |
| 2013-14 | 345 | 15 | | 360 | 199 | 30 | | 229 | 544 | 45 | | 589 | 36.6 | 66.7 | | 38.9 |
| 2012-13 | 318 | 7 | | 325 | 128 | 13 | | 141 | 446 | 20 | | 466 | 28.7 | 65.0 | | 30.3 |
| | Total | | | | | | | | | | | | | | | |
| 2017-18 | 3,573 | 3,291 | 44 | 6,908 | 1,335 | 2,231 | 7 | 3,573 | 4,908 | 5,522 | 51 | 10,481 | 27.2 | 40.4 | 13.7 | 34.1 |
| 2016-17 | 3,009 | 5,331 | 43 | 8,383 | 1,170 | 2,553 | 4 | 3,727 | 4,179 | 7,884 | 47 | 12,110 | 28.0 | 32.4 | 8.5 | 30.8 |
| 2015-16 | 2,128 | 3,155 | | 5,284 | 640 | 1,670 | | 2,310 | 2,768 | 4,825 | 1 | 7,594 | 23.1 | 34.6 | | 30.4 |
| 2014-15 | 2,094 | 2,712 | 26 | 4,832 | 471 | 1,198 | 5 | 1,674 | 2,565 | 3,910 | 31 | 6,506 | 18.4 | 30.6 | 16.1 | 25.7 |
| 2013-14 | 2,022 | 3,806 | 35 | 5,863 | 718 | 1,580 | 13 | 2,311 | 2,740 | 5,386 | 48 | 8,174 | 26.2 | 29.3 | | 28.3 |
| 2012-13 | 2,970 | 2,260 | 86 | 5,316 | 649 | 576 | 11 | 1,236 | 3,619 | 2,836 | 97 | 6,552 | 17.9 | 20.3 | | 18.9 |

*ប្រភព៖ TVETMIS, MLVT*

ចំនួននិស្សិតបញ្ចប់ការសិក្សាហាក់ដូចជាបង្ហាញពីនិន្នាការវិជ្ជមាន ប៉ុន្តែការប្រែប្រួលប្រចាំឆ្នាំមានភាពទាក់ទង និងពិបាកពន្យល់ណាស់ជាពិសេសសម្រាប់វិស័យសាធារណៈ បញ្ហានៃការប៉ាន់ស្មានត្រឹមត្រូវគឺកំពុងអាចជាលទ្ធភាព។

វាត្រូវតែបញ្ជាក់យ៉ាងច្បាស់ថាកង្វះទិន្នន័យស្តីពីការចុះឈ្មោះ និងនិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ធ្វើឱ្យមិនអាចផ្តល់នូវការប្រៀបធៀបរវាងតម្រូវការជំនាញ និងការផ្គត់ផ្គង់ជំនាញពីនិស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យបាន។

## ៦.៥ សិស្សបញ្ចប់ពីប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងទីផ្សារការងារ

ចំនួននិស្សិតបញ្ចប់ការសិក្សាពីវគ្គសិក្សាវិញ្ញាបនបត្រ គឺជាការប៉ាន់ស្មានដែលអាចទទួលយកបាននៃការចាកចេញជាទៀងទាត់ពី TVET ខណៈពេលដែលភាពខុសគ្នាជាមួយនឹងចំនួននៃការចុះឈ្មោះតំណាងឱ្យការចាកចេញ ឬបោះបង់ការសិក្សាដែលមានភាពមិនទៀងទាត់។

ក្នុងករណីមានការអប់រំខ្ពស់ ចំនួននិស្សិតបញ្ចប់ការសិក្សាមិនត្រូវគ្នានឹងការចាកចេញពីប្រព័ន្ធ TVET ទេ ព្រោះថា %របស់យុវជន (ភាគច្រើន) ដែលទទួលបានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសនឹងស្ថិតនៅក្នុងប្រព័ន្ធ TVET ដើម្បីទទួលបានបរិញ្ញាបត្រ ហើយនិស្សិតមួយចំនួនទៀតដែលទទួលបានបរិញ្ញាបត្រនឹងបន្តថ្នាក់អនុបណ្ឌិត។ សន្មត់ថាពាក់កណ្តាលនៃអ្នកដែលទទួលបានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសនឹងរៀនបន្ត ហើយនិស្សិតបញ្ចប់ការសិក្សាទាំងអស់នឹងចាកចេញពី TVET យើងអាចប៉ាន់ស្មានពីការចាកចេញពីការអប់រំខ្ពស់របស់ TVET ប្រហែល ៨,០០០នាក់។

ប្រសិនបើយើងបន្ថែមការចាកចេញជាទៀងទាត់ពីវគ្គសិក្សាវិញ្ញាបនបត្រទៅអ្នកដែលមកពីឧត្តមសិក្សា យើងឈានដល់ចំនួនសរុប ១០,០០០នាក់ ដែលតំណាងប្រមាណ ៤% នៃការចាកចេញពីប្រព័ន្ធអប់រំ ហើយដូច្នេះការផ្គត់ផ្គង់កម្លាំងពលកម្មមានសក្តានុពល។

ព័ត៌មានដែលអាចរកបានចង្អុលបង្ហាញយ៉ាងច្បាស់ពីការសន្និដ្ឋាន ដែលមិនអាចជៀសវាងបានថា ប្រទេសកម្ពុជានៅឆ្ងាយពីប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសមត្ថភាពក្នុងការផ្តល់ជំនាញដែលត្រូវការ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ច។ ការបណ្តុះបណ្តាលក្រៅផ្លូវការរយៈពេលខ្លីមិនគ្រប់គ្រាន់ទេ ហើយប្រទេសកម្ពុជាត្រូវការគឺការបង្កើតវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានគុណភាពខ្ពស់រយៈពេលវែង ដើម្បីផលិតអ្នកបច្ចេកទេសមធ្យមទាំងនោះ ដែលតំណាងឱ្យធាតុសំខាន់មិនត្រឹមតែជួយបង្កើនផលិតភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រីកប្រភេទផលិតផលនៅក្នុងចង្កោមដែលមានស្រាប់ និងដើម្បីអនុញ្ញាតឱ្យឈានទៅកាន់បច្ចេកវិទ្យាល្អប្រសើរជាងមុន។ អ្នកបច្ចេកទេសវ័យក្មេងជំនាន់ថ្មីក៏ចាំបាច់ផងដែរដើម្បីជំរុញភាពជាសហគ្រិន និងការបង្កើតផ្នែកពាក់ព័ន្ធនៃក្រុមហ៊ុនជាតិខ្នាតតូច និងមធ្យមដែលជឿនលឿនផ្នែកបច្ចេកវិទ្យា។ ទន្ទឹមនឹងនេះ និយមន័យនៃគោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំត្រូវតែមានភាពស៊ីចង្វាក់គ្នានឹងសម្របសម្រួលជាមួយការរចនាគោលនយោបាយឧស្សាហកម្មដែលចាំបាច់ ដើម្បីចៀសវាងនិស្សិតបញ្ចប់ការសិក្សាខកចិត្តនៃភាពអត់ការងារធ្វើ។

# ជំពូកទី៣៖

# សង្ខេប និង

# ការផ្ដល់យោបល់ពី

# គោលនយោបាយ

# ផ្នែកទី៧ ៖ សង្ខេប និងការផ្តល់យោបល់ពីគោលនយោបាយ

## វិភាគពីសាវតា

**ការរីកចម្រើននៃសេដ្ឋកិច្ច៖** ក្នុងរយៈពេលជាងបីទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានសម្រេចនូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមគួរឱ្យកត់សម្គាល់។ កំណើនសេដ្ឋកិច្ចដែលបណ្តាលមកពីវាយនភ័ណ្ឌ ទេសចរណ៍ សំណង់ និងវិស័យកសិកម្មថ្មីៗ បានធ្វើអោយមានការចាប់អារម្មណ៍។ បើទោះបីជាកំណើននេះមានការធ្លាក់ចុះបន្ទាប់ពីវិបត្តិសេដ្ឋកិច្ចក៏ដោយ ក៏ប៉ុន្តែចាប់តាំងពីឆ្នាំ២០០០ ដល់ ឆ្នាំ២០១៧ ផលិតផលក្នុងស្រុកសរុបពិតប្រាកដបានកើនឡើង ២៥០% ហើយផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ (ដែលគិតត្រឹមពេលនេះមានជិត ១,៥០០ដុល្លារ) បានកើនឡើងទ្វេដងបើប្រៀបធៀបទៅនឹងស្ថានភាពជាក់ស្តែង។

**ផ្នែកសេដ្ឋកិច្ច និងមែកធាងសេដ្ឋកិច្ចផ្សេងៗទៀត៖** ផ្នែកសេដ្ឋកិច្ចសំខាន់ៗ និងមែកធាងសេដ្ឋកិច្ចផ្សេងៗទៀតបានចុះបញ្ជីអត្រាកំណើនខុសគ្នាដែលបានជះឥទ្ធិពលទៅលើកំណើនផលិតកម្មសរុប និងតួនាទីក្នុងកំណើនសេដ្ឋកិច្ច។ បន្ទាប់ពីវិបត្តិឆ្នាំ២០០៩ ផលិតផលក្នុងស្រុកសរុបបានកើនឡើងក្នុងអត្រាជាមធ្យម ៧% ក្នុងរយៈពេលដូចគ្នា ហើយអត្រាកំណើននៃវិស័យកសិកម្មបានធ្លាក់ចុះមកនៅត្រឹម ២.១% សេវាកម្មបានធ្លាក់ចុះ ៥.៣% ខណៈដែលអត្រានៃកំណើនផ្នែកឧស្សាហកម្មកើនដល់ ១១.២%។ ជាលទ្ធផលក្នុងពេលបច្ចុប្បន្ននេះ ចំណែកនៃសេវាកម្មក្នុងតម្លៃបន្ថែមសរុប គឺ ៤២.២% ឧស្សាហកម្ម ៣២.៩% ខណៈពេលដែលវិស័យកសិកម្មធ្លាក់ចុះដល់ ២៤.៩%។

ដើម្បីធ្វើឱ្យកាន់តែមានភាពប្រសើរឡើងចំពោះស្ថានភាពថ្មីៗនេះ យើងសូមគូសបញ្ជាក់អំពីផ្នែកបីដែលធ្វើឱ្យសេដ្ឋកិច្ចមានការកើនឡើងពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៧ គឺវាយនភ័ណ្ឌ (៣១%) សំណង់ (១១%) និងពាណិជ្ជកម្ម (៩%)។ ផ្ទុយទៅវិញ ការចូលរួមចំណែករបស់វិស័យកសិកម្មមានតែ ៧.៣% ប៉ុណ្ណោះ (វាមានចំនួន ២១% នៅទសវត្សរ៍មុនៗ) ហើយសណ្ឋាគារ និងភោជនីយដ្ឋានបានធ្លាក់ចុះពី ៦.% មកនៅត្រឹម ៥.៤%។

**និន្នាការប្រជាសាស្ត្រ៖** ប្រជាជនសរុបមានចំនួន ៤.៤លាននាក់ក្នុងឆ្នាំ១៩៥០ ដោយបច្ចុប្បន្នមានចំនួន ១៥.៥លាននាក់។ ទោះបីជាយ៉ាងណាក៏ដោយ អត្រានៃកំណើននេះមានការថយចុះគួរឱ្យកត់សម្គាល់។ អត្រាសរុបនៃការមានកូននៅតែមានកម្រិតខ្ពស់ជាងកម្រិតនៃការជំនួស (កុមារ ២.៧នាក់ ក្នុងម្តាយម្នាក់) ប៉ុន្តែចំនួនកំណើតត្រូវបានគេព្យាករណ៍ថានឹងធ្លាក់ចុះពីកម្រិតបច្ចុប្បន្ន ៣៦៦,០០០នាក់ មក ៣១៨,០០០នាក់ នៅពាក់កណ្តាលនៃសតវត្សរ៍នេះ។ ចំណែកប្រជាជនដែលមានអាយុធ្វើការបានឈានដល់ ៦៤.៣% ដូច្នេះ នៅប៉ុន្មានឆ្នាំក្រោយប្រទេសកម្ពុជាអាចទទួលបានផលចំណេញពីភាគលាភនៃប្រជាសាស្ត្រ។

**ប្រព័ន្ធអប់រំ៖** បន្ទាប់ពីឆ្នាំ១៩៨០ ប្រទេសកម្ពុជាបានបោះជំហានយ៉ាងធំក្នុងការកសាងប្រព័ន្ធអប់រំជាតិឡើងវិញ។ ការកើនឡើងដ៏ច្រើននៃចំនួនសិស្សត្រូវស្របគ្នាជាមួយនឹងការកើនឡើងនៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងបុគ្គលិក។ ទិន្នន័យបានបង្ហាញថា នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធអប់រំបានចាប់ផ្តើមប្រឈមមុខនឹងបញ្ហាពាក់ព័ន្ធនានា ដែលជះឥទ្ធិពលដល់ភាពទៀងទាត់នៃដំណើរការអប់រំដូចជា ភាពលើសលុបនៃកុមារដែលមានអាយុច្រើន ចំនួននៃការបោះបង់ចោលការសិក្សាភាគច្រើននៅក្នុងកម្រិតបឋម និងអត្រាខ្ពស់ការត្រួតថ្នាក់។ ទោះបីជាមានភាពប្រសើរឡើងនៃការចុះឈ្មោះចូលរៀននៅក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះក៏ដោយ តែនៅក្នុងឆ្នាំសិក្សា ២០១៦-២០១៧ សិស្សម្នាក់ក្នុងចំណោម ៧នាក់នៅតែមានអាយុច្រើនដដែលហើយអត្រាត្រួតថ្នាក់នៅបឋមសិក្សាមានចំនួន ៦.៥% ហើយចំនួនច្រើនជាងបីភាគបួនដែលបានចាកចេញពីប្រព័ន្ធអប់រំ គឺដោយសារ

តែការបោះបង់ការសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួន %នៃការបោះបង់ការសិក្សាបានកើនឡើងតាមលំដាប់ជាមួយនឹងកម្រិតការអប់រំ។

ការប៉ាន់ប្រមាណក៏បានបង្ហាញថា ការចាកចេញពីដំណាក់កាលនៃការបណ្តុះបណ្តាលនាពេលបច្ចុប្បន្នមានប្រហែល ៣១៥,០០០នាក់ ដែលអាចផ្គត់ផ្គង់កម្លាំងពលកម្មលើសពី ២៨០,០០០នាក់ ហើយនៅក្នុងនោះ ៦០% មានការអប់រំតិចជាងថ្នាក់មូលដ្ឋាន (Compulsory) ១៧% មានការអប់រំកម្រិតអនុវិទ្យាល័យ ៦% មានការអប់រំកម្រិតវិទ្យាល័យ និង ១៧% មានការអប់រំកម្រិតមហាវិទ្យាល័យ។

**ទីផ្សារការងារ៖** បើផ្អែកតាមស្ថានភាពដែលប្រឈមទិន្នន័យទីផ្សារការងារ ហើយជាពិសេសភាពអត់ការងារធ្វើបានបង្ហាញថា វាមានការជាប់ទាក់ទងគ្នាស្ទើរតែមិនអាចខ្វះបានរវាងការផ្គត់ផ្គង់កម្លាំងពលកម្ម និងតម្រូវការការងារ។ ទោះយ៉ាងណា ការសន្និដ្ឋានបែបនេះមិនត្រឹមត្រូវទាំងស្រុងនោះទេនៅក្នុងស្ថានភាពដែលចំនួនបីភាគបួននៃកម្លាំងពលកម្មរស់នៅក្នុងតំបន់ជនបទហើយការស្រង់ស្ថិតិមានភាពពិបាក ហេតុនេះការវាស់ស្ទង់ភាពអត់ការងារធ្វើ ឬដើម្បីបែងចែកភាពខុសគ្នារវាងភាពមានការងារ និងភាពអត់ការងារធ្វើដែលបិទបាំងមិនអាចធ្វើទៅបានទេ ខណៈពេលដែលតំបន់ទីប្រជុំជនត្រូវបានកំណត់ថា ភាពអត់ការងារធ្វើមានចំនួនច្រើន។

ទោះយ៉ាងណា ទិន្នន័យទីផ្សារការងារក៏បានបង្ហាញផងដែរអំពីការផ្លាស់ប្តូរជាច្រើន និងការកែលម្អគុណភាពនៃស្ថានភាពការងារ។ នៅក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ កម្រិតការងារបានកើនឡើងក្នុងអត្រាប្រចាំឆ្នាំជាមធ្យម ១៩៣,០០០នាក់ ការងារកសិកម្មបានចាប់ផ្តើមធ្លាក់ចុះក្នុងឆ្នាំ២០១២ ហើយរហូតមកដល់បច្ចុប្បន្ន ផ្នែកនេះបានធ្លាក់ចុះដល់ ៣៧%។ ក្នុងរយៈពេលដូចគ្នាកំណើនការងារឧស្សាហកម្ម និងសេវាកម្មបានកើនឡើងជាបន្តបន្ទាប់ដល់ចំនួន ១៦១,០០០នាក់ និង ១៧៨,០០០នាក់ ហើយវិស័យទាំងពីរនេះបានរួមចំណែកធ្វើអោយការកើនឡើងនៃអត្រាការងារដល់ ២៦.២% និង ៣៦.៨%។

**ទន្ទឹមនឹងគ្នានេះ ការបង្ហាញពីការកែលម្អគុណភាពការងារបានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ជាពិសេស៖**

- %នៃនិយោជិតដែលទទួលបានការដំឡើងប្រាក់ខែពី ២៦% ទៅ ៥១% ខណៈអត្រានៃសមាជិកក្រុមគ្រួសារដែលមិនទទួលបានប្រាក់ឈ្នួលបានធ្លាក់ចុះពី ៣៦% ទៅ ៤%។
- %នៃកម្មករជំនាញផ្នែកកសិកម្មបានថយចុះមកនៅត្រឹម ៣១% ខណៈពេលដែលសិប្បករបានកើនឡើងពី ១០% ទៅ ២៤% ហើយចំនួនអ្នកលក់ និងកម្មករបម្រើសេវាកម្មបានកើនពី ១២% ទៅ ១៨% ។ លើសពីនេះទៅទៀត ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះការរីកចម្រើននៃសិប្បកម្ម និងមុខរបរដែលពាក់ព័ន្ធ ការផ្តល់សេវាកម្ម និងអ្នកលក់ និងការងារការិយាល័យមានការកើនឡើងដោយឡែកពីគ្នាគឺ ៥៤%, ១៨% និង ១៣% នៃកំណើនការងារសរុប ខណៈដែលផ្នែកពាក់ព័ន្ធផ្សេងៗទៀតដូចជា ការដាំដុះ អ្នកបើកបរគ្រឿងយន្ត អ្នកជំនាញ និងអ្នកបច្ចេកទេសបានរួមចំណែកផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ចំនួនអ្នកគ្រប់គ្រង អ្នកជំនាញ និងអ្នកបច្ចេកទេស បានធ្លាក់ចុះបន្តិចត្រឹមតែ ៦% ខណៈដែលកម្មករមិនមានជំនាញមានអត្រាលើសពី ១០%។
- កម្រិតនៃការអប់រំរបស់កម្លាំងពលកម្មមានភាពល្អប្រសើរ ប៉ុន្តែនៅតែទាបដដែលគឺ ៧០% មិនបានបញ្ចប់ការអប់រំថ្នាក់មូលដ្ឋានតិចជាងអនុវិទ្យាល័យ (compulsory) ហើយអ្នកដែលមានការអប់រំខ្ពស់គឺ ៨% និង ៧% មានសញ្ញាបត្រក្រោយមធ្យមសិក្សា។ ទោះយ៉ាងណា វាជាកត្តាវិជ្ជមានមួយដែលក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ៣៤% នៃការងារបន្ថែមបានទទួលយកមនុស្សដែលមានការអប់រំកម្រិតក្រោយមធ្យមសិក្សា ហើយក្នុងរយៈពេលដូចគ្នានេះ ក៏មានការកើនឡើងចំនួននៃការងារសម្រាប់អ្នកដែលមានការអប់រំទាបជាងកម្រិតបឋម ឬបឋមផងដែរ។

## សេណារីយ៉ូ

សេណារីយ៉ូត្រូវបានគេប៉ាន់ស្មានតាមរយៈគំរូលំហូរស្តុកនៃទីផ្សារការងារ ដែលអាចវាយតម្លៃបានថា តើមានមនុស្សប៉ុន្មាននាក់សម្រាប់តម្រូវការទីផ្សារការងារ និងចំនួនប៉ុន្មាននាក់ដែលនឹងត្រូវចាត់ចូលក្នុងកម្លាំងពលកម្ម ដើម្បីវិភាគអំពីភាពជាប់ទាក់ទងនៃបរិមាណនិងគុណភាពរបស់លំហូរទាំងពីរនេះ។

**ការវិភាគលំហូរស្តុកនៃទីផ្សារការងារកម្ពុជាសម្រាប់ឆ្នាំ ២០០៧-២០១៧៖** ការវិភាគបង្ហាញថាក្នុងចន្លោះឆ្នាំ២០០៧ និងឆ្នាំ២០១៧៖

- ជាមធ្យមរៀងរាល់ឆ្នាំយុវជនកម្ពុជា ២៦១,០០០នាក់ បានរកការងារធ្វើជាលើកដំបូង។
- ការបង្កើតការងារបន្ថែមបានរួមចំណែក ៧៩% ហើយបំពេញបន្ថែមអ្នកជំនាន់ថ្មី ២១%។
- ៩២% នៃអ្នកចូលរួមស្ថិតនៅក្នុងក្រុមអាយុ ១៥-១៩ឆ្នាំ និង ៨% ទៀតនៅក្នុងក្រុមអាយុ ២០-២៤ឆ្នាំ។
- ២/៣ នៃអ្នកដែលចាកចេញឈប់ធ្វើការងារស្ថិតនៅក្នុងក្រុមអាយុ ៥៥-៦៤ឆ្នាំ និង ២៦% នៅក្នុងក្រុមអាយុចន្លោះនេះ។
- ការកែលម្អកម្រិតអប់រំដែលយើងបានសង្កេតរួចហើយ មានភាពខុសគ្នារវាងកម្រិតនៃការអប់រំរបស់អ្នកដែលចូលធ្វើការ និងអ្នកដែលឈប់ពីការងារ។

## សេណារីយ៉ូឆ្នាំ២០១៧-២០២៧

**ផ្នែកតម្រូវការ៖** អាយុជាមធ្យមខ្ពស់នៃអ្នកមានការងារធ្វើត្រូវបានប៉ាន់ស្មានថា ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២៧ ការឈប់ធ្វើការងារនឹងមានច្រើនជាងកាលពីមុនគឺ ១,០៤៥លាន។

ចំនួនការងារដែលត្រូវបានបង្កើតឡើងតាមរយៈសេដ្ឋកិច្ចកម្ពុជា (តម្រូវការបន្ថែម) នឹងត្រូវបានកំណត់ដោយអត្រាកំណើនផលិតកម្ម និងផលិតភាព ហើយដំណើរការពីពេលមុនត្រូវពឹងផ្អែកយ៉ាងខ្លាំងលើបរិមាណ និងប្រភេទនៃការវិនិយោគដោយផ្ទាល់ក្នុងស្រុក និងពាណិជ្ជកម្មអន្តរជាតិ បន្ទាប់មកទៀត គឺត្រូវពឹងផ្អែកលើបច្ចេកវិទ្យាដែលល្អប្រសើរជាងមុន កម្មករដែលមានការអប់រំច្រើន និងការបណ្តុះបណ្តាលដែលប្រសើរ ការធ្វើឱ្យមានភាពប្រសើរឡើងនៃស្ថាប័នការងារ និងការឆ្លងកាត់រចនាសម្ព័ន្ធផលិតកម្មដែលប្រកបដោយបច្ចេកវិទ្យាខ្ពស់។

និន្នាការនាពេលកន្លងមក និងសូចនាករនាពេលថ្មីៗរបស់ស្ថាប័នសាធារណៈនៅកម្ពុជា បានស្នើឱ្យមានការអនុម័តអត្រាមធ្យមចំនួនបីនៃកំណើនផលិតផលក្នុងស្រុក (៦% ៧% និង ៨%) និងបង្កើតបានជាមេគុណអេឡាស្ទិក (Elasticity) ប្រាក់ចំណូលការងារចំនួនបី (០.២០%, ០.២៥% និង ០.៣០%)។ បន្ទាប់មកទៀត នៅក្នុងតម្លៃនៃអតីតកាលបានបង្ហាញថា ភាពចាស់ទុំ និងការទាក់ទាញពីការងារសំណង់ និងផលិតកម្មអាចពន្លឿនការចាកចេញពីតំបន់ជនបទនិងមុខរបរកសិកម្ម ខណៈដែលការច្នៃប្រឌិតផ្នែកបច្ចេកវិទ្យាចាំបាច់ត្រូវបានណែនាំនៅក្នុងគ្រប់វិស័យ ដើម្បីជំរុញឱ្យមានការប្រកួតប្រជែងនៃប្រព័ន្ធផលិតកម្មកម្ពុជា។

អត្រាកំណើនការងារទាំង ៩កម្រិត ត្រូវបានរាប់បញ្ចូលរវាងអប្បបរមា ១.២% និងអតិបរមា ២.៤% និង ១.៧៥% នៅក្នុងសេណារីយ៉ូកម្រិតមធ្យមដែលឆ្លើយតបទៅនឹងការកើនឡើងជាមធ្យមនៃការងារស្មើនឹង ១១១,០០០ ការងារ, ២៣៥,០០០ការងារ និង ១៦៦,០០០ការងារ តាមលំដាប់លំដោយ។ ការប្រៀបធៀបជាមួយនឹងកំណើនដែលរំពឹងទុកនៃចំនួនប្រជាជនដែលគ្រប់អាយុធ្វើការបានផ្តល់នូវលទ្ធផលសំខាន់ទីមួយ៖ អត្រានៃការរីកចម្រើន

របស់ GPD លើសពី ៧% នឹងតម្រូវឱ្យមានការប្រែប្រួលនូវមេគុណអេឡាស្ទិក (Elasticity) ប្រាក់ចំណូលការងារទាបជាង ០.២៥ ហេតុនេះទាមទារអត្រាខ្ពស់នៃការផ្លាស់ប្តូរបច្ចេកវិទ្យា។

ដោយផ្តោតលើការវិភាគលើសេណារីយ៉ូកម្រិតមធ្យម របាយការណ៍នេះបានបង្ហាញថា ការងារកសិកម្មត្រូវបានគេរំពឹងថានឹងធ្លាក់ចុះក្នុងអត្រាប្រចាំឆ្នាំ ១៧៨,០០០នាក់ ខណៈពេលដែលការងារឧស្សាហកម្មនឹងកើនឡើង ១៨៣,០០០នាក់ និងសេវាកម្ម ១៧៨,០០០នាក់ ។ កត្តានេះធ្វើឱ្យមានការកត់សម្គាល់នៃភាពផ្លាស់ប្តូររចនាសម្ព័ន្ធការងារតាមវិស័យដោយវិស័យកសិកម្មធ្លាក់ចុះដល់ ១៤% ឧស្សាហកម្មកើនឡើងដល់ ៣៩.៦% និងសេវាកម្មដល់ ៤៦.៤%។ ភាពអវិជ្ជមានបន្ថែមនៃតម្រូវការកសិកម្មមិនបញ្ជាក់ថាកសិកម្មនឹងមិនត្រូវបានរាប់បញ្ចូលនោះទេ។ តាមពិតវាបានបង្ហាញពីការចាកចេញយ៉ាងច្បាស់លាស់របស់មនុស្សវ័យចំណាស់ និងការផ្លាស់មកវិញនូវកម្មករវ័យក្មេងទៅឧស្សាហកម្មនិងសេវាកម្ម ដែលភាគច្រើនសម្រាប់វិស័យសំណង់ វិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដែលនឹងបន្តស្រូបយកកម្មករដែលមានការអប់រំកម្រិតទាប) ដែលធ្វើឱ្យមានតុល្យភាពដោយផ្អែកលើការបញ្ចូលកូនចៅរបស់កសិករសព្វថ្ងៃ។

ការរួមផ្សំនៃតម្រូវការបន្ថែមនៅក្នុងសេណារីយ៉ូកម្រិតមធ្យម និងតម្រូវការនៃការផ្លាស់ប្តូរបានប៉ាន់ប្រមាណថាតម្រូវការការងារអាចស្រូបយកយុវជនប្រហែល ២៧០,០០០នាក់ ក្នុងមួយឆ្នាំ។ បើផ្អែកលើនិន្នាការនាពេលកន្លងមករបាយការណ៍នេះបានបង្ហាញថា ៣៤% នៃកម្លាំងពលកម្មនៅតែមានការអប់រំទាបជាងកម្រិតបឋម ២៣% មានការអប់រំនូវកម្រិតមធ្យមសិក្សា និង ២៣% មានកម្រិតអប់រំថ្នាក់វិទ្យាល័យ។ កម្រិតអប់រំជាមធ្យមសម្រាប់អ្នកដែលឈប់ពីការងារធ្វើនៅតែទាបដែលគួរឱ្យកត់សម្គាល់ ដូច្នេះកម្រិតនៃការអប់រំរបស់អ្នកមានការងារនឹងកើនឡើង ប៉ុន្តែការកើនឡើងនេះមិនគួរឱ្យកត់សម្គាល់នោះទេ។ នៅឆ្នាំ២០២៧ ចំនួនប្រជាជនដែលមានការអប់រំតិចជាងកម្រិតបឋមសិក្សានៅតែមានអត្រាខ្ពស់រហូតដល់ ៥៩% ប៉ុន្តែចំនួននៃអ្នកដែលមានការងារធ្វើហើយមានការអប់រំយ៉ាងហោចណាស់នៅមធ្យមសិក្សាត្រូវគេរំពឹងថានឹងកើនឡើងពី ៨.២% ទៅ ១២.៤%។

**ផ្នែកផ្គត់ផ្គង់៖** ការផ្គត់ផ្គង់កម្លាំងពលកម្មដែលមានលក្ខណៈជាលំហូរត្រូវតែផ្តល់ដោយចំនួនមនុស្សដែលគ្រប់អាយុធ្វើការក្នុងចន្លោះពេលណាមួយ។ យោងតាមការព្យាករណ៍នូវចំនួនប្រជាជនរបស់ UNDESA (UNDESA ២០១៩) នៅចន្លោះឆ្នាំ២០១៧ និងឆ្នាំ២០២៧ ចំនួនមនុស្សដែលគ្រប់អាយុធ្វើការមានចំនួន ៣.២លាននាក់។ របាយការណ៍សន្និដានថា ចំនួនមនុស្សដែលគ្រប់អាយុធ្វើការនឹងនៅថេរ ដែលប៉ាន់ស្មានហក់ចូលក្នុងកម្លាំងទីផ្សារពលកម្មប្រម៉ាណ ២.៦៣៤លាននាក់។

ដើម្បីញែកនូវចំនួនមនុស្សដែលគ្រប់អាយុធ្វើការតាមកម្រិតនៃការអប់រំ របាយការណ៍បានបង្ហាញពីការព្យាករណ៍ពីរដែលកើតចេញពីប្រព័ន្ធអប់រំ និងប្រព័ន្ធ TVET ដោយផ្អែកលើការសន្និដ្ឋានដំបូងថាអត្រាជាក់លាក់នៃការបន្តរៀនសូត្រនៅតែជាបញ្ហា។ នៅកម្រិតនៃឆ្នាំសិក្សា ២០១៦-២០១៧ ហើយការសន្និដ្ឋានទីពីរដែលកាន់តែជាក់ស្តែងជាងនេះទៀតនោះ គឺថាពួកគេនឹងកែលម្អជាបណ្តើរៗ។ ដូចការរំពឹងទុកកម្រិតនៃការចាកចេញពីការអប់រំមានភាពប្រសើរឡើងនៅក្នុងសេណារីយ៉ូទីពីរជាជាងទីមួយ ខណៈពេលនៅក្នុងឆ្នាំ២០១៧ សិស្ស ៦០% ដែលបានបោះបង់ការសិក្សាមិនបានបញ្ចប់កម្រិតមូលដ្ឋាននោះទេ ហើយ ៤០% យ៉ាងហោចណាស់បានទទួលការអប់រំនៅកម្រិតមូលដ្ឋាន ហើយការបែងចែកនេះត្រូវបានគេប៉ាន់ប្រមាណថាមាន ៥០% និង ៥០% នៅក្នុងសេណារីយ៉ូទីមួយ ហើយ ៤០% និង ៦០% នៅក្នុងសេណារីយ៉ូទីពីរ។ អ្វីដែលគួរអោយចាប់អារម្មណ៍ ជាងនេះទៅទៀតនោះ គឺកម្រិតមហាវិទ្យាល័យដែលបានឈានទៅដល់២០% ក្នុងឆ្នាំ២០១៧។

របាយការណ៍ចុងក្រោយបានបង្ហាញថា ការចាកចេញពីដំណាក់កាលបណ្តុះបណ្តាលនៃជីវិត (សេណារីយ៉ូទី២) និងតម្រូវការទីផ្សារការងារ (សេណារីយ៉ូកម្រិតមធ្យម) តាមកម្រិតអប់រំសម្រាប់ឆ្នាំ២០១៧-២០២៧ មានលក្ខណៈសមហេតុសមផល។ ការប៉ាន់ប្រមាណបានបង្ហាញថាការចាកចេញពីសាលា គឺស្របគ្នានឹងតម្រូវការទីផ្សារការងារ ហើយចំនួនតែមួយគត់ដែលលើសគឺក្រុមដែលមានកម្រិតនៃការអប់រំទាបបំផុត ដែលជាទូទៅងាយធ្លាប់ចូលទៅក្នុងទីផ្សារកម្លាំងពលកម្ម។

## តម្រូវការជំនាញ និងតម្រូវការបណ្តុះបណ្តាលឆ្នាំ២០១៧-២០២២

**ផ្នែកតម្រូវការ៖** កំណើនការងារសរុបដែលត្រូវបានប៉ាន់ប្រមាណមានចំនួន ៧៩៥,០០០នាក់ គឺជាលទ្ធផលនៃការធ្លាក់ចុះចំនួនការងារក្នុងវិស័យកសិកម្ម ៨០៨,០០០នាក់ និងការកើនឡើងក្នុងវិស័យឧស្សាហកម្ម ៨៥០,០០០នាក់ និងសេវាកម្ម ៧៥៣,០០០នាក់។ នៅពេលដែលតម្រូវការជំនួស និងការផ្ទេរពីកសិកម្មទៅវិស័យសំខាន់ពីរផ្សេងទៀតត្រូវបានគេយកមកពិចារណានោះ គឺការចូលក្នុងទីផ្សារការងារក្នុងវិស័យកសិកម្មត្រូវបានប៉ាន់ប្រមាណស្មើនឹង ៤០,០០០នាក់ និងឧស្សាហកម្មរហូតដល់ ១៩៦,០០០នាក់ (១១៣,០០០នាក់ ចូលដំបូង និងការផ្ទេរពីកសិកម្ម ៨៣,០០០នាក់) និងក្នុងវិស័យសេវាកម្ម ១៨៨,០០០នាក់ (១០៩,០០០នាក់ ចូលដំបូង និងការផ្ទេរពីកសិកម្ម ៧៩,០០០នាក់)។

ការវិភាគតម្រូវការការងារតាមមុខរបរសំខាន់ៗ អនុញ្ញាតឱ្យបង្ហាញរូបភាពជាមូលដ្ឋាននៃតម្រូវការជំនាញនិងតម្រូវការបណ្តុះបណ្តាល។ ក្នុងរបាយការណ៍យើងបានប៉ាន់ប្រមាណថា ក្នុងចំណោមមនុស្ស ៤៩០,០០០នាក់ ជាមធ្យមប្រចាំឆ្នាំដែលចូលធ្វើការងារនៅក្នុងវិស័យធំៗចំនួន ៣ ដែលប្រមាណ ៣/៤ នឹងស្ថិតនៅក្នុងក្រុមអាជីពធំៗចំនួន ៣ ដោយសិប្បកម្មនិងកម្មករដែលពាក់ព័ន្ធដើរតួយ៉ាងសំខាន់ (៥៧%) បន្ទាប់មក គឺកម្មករសេវាកម្ម និងអ្នកលក់ (១៤%) និងកម្មករគាំទ្រស្មៀន (១៣%)។ តួនាទីតូចតាចប៉ុន្តែមានលក្ខណៈគុណភាពនឹងត្រូវបានបំពេញដោយប្រតិបត្តិកររោងចក្រនិងម៉ាស៊ីន អ្នកជំនាញនិងអ្នកបច្ចេកទេស។

ការប្រើប្រាស់រួមបញ្ចូលគ្នានៃប្រភពផ្សេងៗគ្នារួមទាំងសន្ទស្សន៍ការងាររបស់ភ្នាក់ងារមុខរបរជាតិ អាចឱ្យយើងផ្តល់នូវការប៉ាន់ស្មានបរិមាណនៃតម្រូវការទាក់ទងនឹងលំហូរសម្រាប់មុខរបរតែមួយ និងការចង្អុលបង្ហាញពីមុខរបរដែលមានលក្ខណៈដោយកង្វះការផ្គត់ផ្គង់។ ការស្រាវជ្រាវបានចង្អុលបង្ហាញពីតួនាទីសំខាន់ដែលនឹងត្រូវបានបំពេញដោយមុខរបរតែមួយនៃវិស័យសំណង់ វិស័យកាត់ដេរ កន្លែងស្នាក់នៅ ភោជនីយដ្ឋាន និងដោយវិស័យពាណិជ្ជកម្មលក់រាយ ប៉ុន្តែក៏មានមុខរបរសំខាន់ៗដែលទាមទារឱ្យមានការអប់រំកម្រិតវិទ្យាល័យ និងសាកលវិទ្យាល័យ។ សូចនាករទាំងនេះមានសារៈសំខាន់សម្រាប់តម្រូវការអប់រំ និងការបណ្តុះបណ្តាលដោយក្រសួងពាក់ព័ន្ធ ជាពិសេសដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ចំពោះផ្នែកផ្គត់ផ្គង់វិញ ការវិភាគនៃវគ្គបណ្តុះបណ្តាល TVET នៅកម្រិតវិញ្ញាបនបត្រ និងកម្រិតសាកលវិទ្យាល័យ បង្ហាញថា ចំណែកនៃការផ្គត់ផ្គង់កម្លាំងពលកម្មដែលបានគ្របដណ្តប់ដោយវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ គឺមានលក្ខណៈគុណភាព ដែលបរិមាណមានកំណត់ ដូច្នេះគួរតែពង្រីកការបណ្តុះបណ្តាលវិជ្ជាជីវៈភ្លាមៗនៅក្នុងទិសដៅចង្អុលបង្ហាញក្នុងរបាយការណ៍។

## ការស្នើគោលនយោបាយ

ការរកឃើញដ៏សំខាន់នៃរបាយការណ៍នេះ គឺថាទីផ្សារការងារនៅប្រទេសកម្ពុជាទទួលរងសម្ពាធពីកម្រិតនៃការអប់រំទាបនៃកម្លាំងពលកម្ម។ វាជាបញ្ហាដែលមានលក្ខណៈជាប្រព័ន្ធរចនាសម្ព័ន្ធ ហើយអាចដោះស្រាយបានក្នុងរយៈពេលមធ្យមមួយ តាមរយៈការបង្កើនឱ្យស្រេចបាននូវការអប់រំសម្រាប់សិស្សដែលបានចាកចេញពីដំណាក់កាលបណ្តុះបណ្តាល។

កម្លាំងពលកម្មដែលមានកម្រិតនៃការអប់រំខ្ពស់បំផុត គឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងដំណាក់កាលជាប្រវត្តិសាស្ត្រនេះ មិនមែនដោយសារតម្រូវការដ៏ច្រើននៃកម្លាំងពលកម្មដែលទទួលបានការអប់រំខ្ពស់នៅតាមផ្នែកជាច្រើននៃវិស័យសេវាកម្មនោះទេ ប៉ុន្តែដោយសារវាតំណាងឱ្យតម្រូវការជាបឋមមុននឹងទទួលបាននូវជំនាញ និងសមត្ថភាពដែលកំណត់ដោយបច្ចេកវិទ្យាថ្មីៗ ហើយនិងត្រូវបានប្រើប្រាស់នៅក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម។ វាត្រូវបានបញ្ជាក់ដោយនិយោជកថា និស្សិតដែលបានបញ្ចប់ការសិក្សាពី TVET មានភាពខ្វះខាតជាច្រើនដូចជា កង្វះជំនាញមូលដ្ឋាននៅក្នុង ការអាន ការសរសេរ និងគណិតវិទ្យាដែលវាមិនមែនជាកំហុសទាំងស្រុងនៃការបណ្តុះបណ្តាលវិជ្ជាជីវៈនោះទេ ប៉ុន្តែវាជាកង្វះខាតនៃការអប់រំ។

ការបង្កើនប្រសិទ្ធភាពការងាររបស់កម្លាំងពលកម្មក៏ត្រូវបានលើកឡើងផងដែរ ពីព្រោះដោយសារការប្រែប្រួលអត្រាប្រជាសាស្ត្រកើនឡើង កម្លាំងពលកម្មអាចថយចុះជាចាំបាច់ ហើយការចំណាកស្រុកទៅប្រទេសជិតខាងអាចធ្វើឱ្យមានកង្វះខាតកម្លាំងពលកម្មជំនាញក្នុងស្រុកថែមទៀត។

**ការកាត់បន្ថយអត្រាបោះបង់នៃការសិក្សា៖** ភាគច្រើននៃការបោះបង់ចោលការសិក្សាប្រព្រឹត្តទៅមិនមែននៅចុងបញ្ចប់នៃឆ្នាំសិក្សាទេ ប៉ុន្តែនៅក្នុងដំណាក់កាលវង្វង់នៃការអបរំ ហើយអ្នកដែលបានបោះបង់នៅកម្រិតបឋមសិក្សាមានលក្ខណៈជាពិសេស និងជះឥទ្ធិពលធំធេង។ លទ្ធផលនៃការវិភាគរបស់យើងបានបង្ហាញថា ការកាត់បន្ថយអត្រាបោះបង់ចោលការសិក្សា នឹងជះឥទ្ធិពលភ្លាមៗទៅលើរយៈពេលជាមធ្យមនៃដំណើរការអប់រំ។

មូលហេតុជាច្រើននៃការបោះបង់ចោលការសិក្សាជាដំបូងអាចងាយយល់។ របាយការណ៍កន្លងទៅរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានលើកឡើងថា "ភាពក្រីក្របានជំរុញកុមារជាច្រើនឱ្យក្លាយជាកម្លាំងពលកម្មមុនពេលពួកគេទទួលបានការសិក្សាច្រើន ហើយការកង្វះអាហារូបត្ថម្ភបានជះឥទ្ធិពលដល់អ្វីដែលពួកគេអាចរៀនបាននៅពេលពួកគេនៅសាលារៀន" (ADB ឆ្នាំ២០១៥)។ ចំពោះបញ្ហាដែលបានលើកឡើងនេះ វាហាក់ដូចជាពាក់ព័ន្ធជាមួយនឹងការរៀបចំការស្ទង់មតិមួយដែលមានគោលបំណងស៊ើបអង្កេតតាមរបៀបសាមញ្ញអំពីមូលហេតុដើមនៃបញ្ហា និងដើម្បីរៀបចំនូវវិធានការមួយដែលមានប្រសិទ្ធភាពសម្រាប់ដោះស្រាយបញ្ហានេះ។

**ការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការអប់រំ៖** ការវិភាគបានបង្ហាញថា នាពេលអនាគតចំនួនសិស្សដែលបានចុះឈ្មោះចូលរៀននៅក្នុងប្រព័ន្ធអប់រំនឹងមិនមានការកើនឡើងច្រើននោះទេ ក្នុងដំណាក់កាលនេះវាហាក់ដូចជាមានលទ្ធភាពនិងសមស្របក្នុងការវិនិយោគលើគុណភាពនៃការអប់រំ។ យោងតាមការសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីដដែលបានបង្ហាញថា បញ្ហាប្រឈមមួយទៀតគឺគុណភាព និងភាពពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ការអប់រំដែលកំពុងផ្តល់នាពេលបច្ចុប្បន្ន។ មូលហេតុមួយនៃបញ្ហាគុណភាពនៅក្នុងការអប់រំគឺថាគ្រូខ្លួនឯងច្រើនតែមិនមានគុណភាពគ្រប់គ្រាន់។ ការកែលម្អគុណភាពគ្រូ និងសន្ទស្សន៍រវាងសិស្ស និងគ្រូ មិនត្រឹមតែអាចបង្កើននូវគុណភាពនាពេលបញ្ចប់

ការសិក្សាប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចកាត់បន្ថយអត្រារៀនត្រួតថ្នាក់ទៀតផង ដែលជាបញ្ហាមួយមានលក្ខណៈជាប្រព័ន្ធ និងប៉ះពាល់ដល់ភាពទៀងទាត់ និងប្រសិទ្ធភាពនៃដំណើរការបណ្តុះបណ្តាល។

**ការកំណត់តួនាទីរបស់ TVET ៖** របាយការណ៍នេះបានបង្ហាញតិចតួចអំពី TVET ហើយមូលហេតុចម្បង គឺចំនួនសិស្ស និងអត្រាបញ្ចប់ការសិក្សាពីសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមានកម្រិតទាប (ប្រហែល ១% នៃចំនួនសរុប) និងកង្វះខាតព័ត៌មានស្ថិតិ។ ទោះយ៉ាងណាក៏ដោយ វាត្រូវបានគេសង្ឃឹមថា តួនាទី និងភាពពាក់ព័ន្ធរបស់ TVET នឹងកើនឡើង។ មានកត្តាបីដែលអាចធ្វើអោយតួនាទីរបស់ TVET មានសក្តានុពល។

កត្តាទីមួយ TVET គួរតែដើរតួនាទីជាបណ្តាញសុវត្ថិភាពសម្រាប់កុមារា និងកុមារីដែលបានបោះបង់ចោលការសិក្សានៅកម្រិតមូលដ្ឋាន។ ការធ្វើតួនាទីបែបនេះ TVET អាចចូលរួមជួយកុមារទាំងនោះឱ្យទទួលបាននូវការអប់រំដែលចាំបាច់ ហើយក្នុងពេលជាមួយគ្នានោះក៏អាចផ្តល់ឱ្យពួកគេនូវសម្ភារទៅតាមតម្រូវការទីផ្សារផងដែរ។

កត្តាទីពីរ TVET គួរតែពង្រីកសកម្មភាពរបស់ខ្លួនដោយទាក់ទាញកុមារា និងកុមារីដែលបានបញ្ចប់ការអប់រំនៅកម្រិតមូលដ្ឋាន ឬកម្រិតសិក្សាខ្ពស់ហើយផ្តល់ឱ្យពួកគេនូវជំនាញ និងសមត្ថភាពដែលជាតម្រូវការទីផ្សារ។ វាជាបញ្ហាសារមេញទូទៅដែលការបណ្តុះបណ្តាលវិជ្ជាជីវៈនៅប្រទេសកម្ពុជា ត្រូវបានប្រឈមមុខដូចជា នៅប្រទេសជាច្រើនក្នុងពិភពលោកផងដែរ ដោយការយល់ឃើញបែបអវិជ្ជមានហើយត្រូវបានគេមើលឃើញថា វាជាដំណោះស្រាយជម្រើសទីពីរ។ ចក្ខុវិស័យនេះច្រើនតែបណ្តាលមកពីកង្វះខាតនៃការទទួលស្គាល់អំពីស្ថានភាព និងភាពជាប់ទាក់ទងនៃការងារដែល TVET រៀបចំសម្រាប់សិស្ស។ ដើម្បីពង្រីកវិសាលភាពនៃ TVET ឱ្យមានសារៈសំខាន់ វាមិនគ្រាន់តែជាការបង្ហាញពីភាពពាក់ព័ន្ធ និងផ្សព្វផ្សាយពីវត្តមានរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែគឺត្រូវធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសង្គម និងការផ្តល់សេដ្ឋកិច្ចប្រាក់ឈ្នួលសម្រាប់មុខរបរ TVET ផងដែរ។

កត្តាទីបី វាត្រូវបានគេទទួលស្គាល់ជាទូទៅថា នៅពេលខាងមុខការច្នៃប្រឌិតនៃបច្ចេកវិទ្យាដែលមិនធ្លាប់មានពីមុនមកនឹងជះឥទ្ធិពលដល់គ្រប់វិស័យសេដ្ឋកិច្ច។ កត្តានេះនឹងតម្រូវឱ្យមានការឆ្លើយតបមួយចំនួនធំដែលស្ថាប័ន TVET អាចផ្តល់កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន។

កត្តាមួយចំនួនចុងក្រោយ គឺការធ្វើឱ្យការងារនៅក្នុងវិស័យកសិកម្មមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍប្រទេស។ ការកាត់បន្ថយកម្លាំងពលកម្មយ៉ាងច្រើនដែលវិស័យនេះបង្ហាញថា ការដើរតួនាទីជាកណ្តាលដែលវិស័យនេះអាចធ្វើឱ្យសេដ្ឋកិច្ចរបស់កម្ពុជាមានការងើបឡើងវិញ ភាពចាំបាច់ក្នុងការបង្កើនផលិតភាពតាមរយៈការទទួលយកបច្ចេកវិទ្យាទំនើបបំផុតបង្ហាញថា ស្ថាប័ន TVET គួរតែយកចិត្តទុកដាក់ ជាពិសេសទៅលើវិស័យកសិកម្ម។

**គោលនយោបាយនៃការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឧស្សាហកម្ម៖** ដើម្បីរៀបចំផែនការ និងប្រព័ន្ធនៃការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្វីដែលយើងត្រូវការគឺជាការព្យាករណ៍នៃតម្រូវការការងារដែលមានលក្ខណៈសាមញ្ញ។ ជាដំបូង អ្នកសេដ្ឋកិច្ចមិនមែនជាគ្រូទាយទេ ហើយអ្វីដែលពួកគេអាចធ្វើបានគួរតែធ្វើ ដើម្បីផ្តល់នូវចក្ខុវិស័យថ្មីមួយសម្រាប់អនាគតដោយផ្អែកលើគុណតម្លៃខុសគ្នានៃបញ្ហាអថេរមូលដ្ឋាន។ សេណារីយ៉ូទាំងនេះនឹងប្រាប់អ្នកធ្វើគោលនយោបាយពីអ្វីដែលនឹងកើតឡើងប្រសិនបើព្រឹត្តិការណ៍ជាក់លាក់នឹងកើតឡើងហើយ ឬគោលនយោបាយជាក់លាក់នឹងត្រូវបានអនុម័ត។ សេណារីយ៉ូនេះ គឺជាឧបករណ៍ដែលជួយអ្នកធ្វើគោលនយោបាយឱ្យធ្វើការសម្រេចចិត្តផ្អែកលើភស្តុតាង។ កត្តាទីពីរ អនាគត គឺជាការបង្កើតដោយផ្ទាល់របស់ពួកយើង។ នេះបញ្ជាក់ថា ការបណ្តុះបណ្តាលដែលត្រូវ

ការដាំចាំបាច់ភាគច្រើនពឹងផ្អែកលើចំនួន និងប្រភេទនៃការវិនិយោគដែលត្រូវបានធ្វើគោលនយោបាយកសិកម្ម និងឧស្សាហកម្មដែលនឹងត្រូវបានអនុម័តថា តើយើងនឹងមានភាពល្អប៉ុណ្ណាក្នុងការពង្រីកវិស័យសេវាកម្ម។

ជារួមខណៈដែលទីផ្សារការងារ និងការព្រួយបារម្ភពីសេដ្ឋកិច្ចគួរតែមានសេណារីយ៉ូមួយ ការសម្របសម្រួលដ៏សមស្រប និងបន្តជានិរន្តគួរតែត្រូវបានបង្កើតឡើងផងដែររវាងការរៀបចំ និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច ហើយនិងការរៀបចំ និងការអនុវត្តគោលនយោបាយបណ្តុះបណ្តាលគួរតែត្រូវបានកំណត់ឱ្យបានទូលំទូលាយ។

**បង្កើនប្រព័ន្ធទីផ្សារការងារ** (Labour Market Intelligence) ដូចជាប្រទេសដទៃទៀតដែរ កម្ពុជាគួរតែប្រកាន់ខ្ជាប់នូវគោលការណ៍ផ្អែកលើគោលនយោបាយដែលមានមូលដ្ឋានលើគ្រប់វិស័យ ជាពិសេសនៅក្នុងវិស័យគោលនយោបាយទីផ្សារការងារដែលបានកំណត់យ៉ាងទូលំទូលាយ និងគោលនយោបាយអប់រំប្រកបដោយបរិយាប័ន្ន ព្រមទាំងគោលនយោបាយអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ប្រព័ន្ធទីផ្សារការងារពឹងផ្អែកលើភាពអាចរកបាននៃព័ត៌មានស្ថិតិ និងសមត្ថភាពក្នុងការបកស្រាយព័ត៌មាននេះដោយប្រកាន់ខ្ជាប់នូវគំរូ (Model) និងនីតិវិធីវិភាគត្រឹមត្រូវ។

បច្ចុប្បន្ននេះ ប្រព័ន្ធទីផ្សារការងារត្រូវបានផ្តល់ជាចម្បង (ទាំងស្រុង) ដោយការវិភាគដូចជាការវិភាគបច្ចុប្បន្នដែលអនុវត្តដោយ NEA ដូចជា ការព្យាករណ៍តម្រូវការការងារ (NEA, ២០១៧) និងកង្វះជំនាញ និងគម្លាតជំនាញ (NEA, ២០១៥, ២០១៦, ២០១៨) និងដោយអង្គការអន្តរជាតិដូចជា អង្គការអន្តរជាតិខាងការងារ (ILO) ធនាគារពិភពលោក (World Bank) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

កិច្ចខិតខំប្រឹងប្រែងដើម្បីព្យាករណ៍តម្រូវការការងារ និងជាទូទៅដើម្បីបង្កើតសេណារីយ៉ូទីផ្សារការងារត្រូវបានធ្វើឱ្យមានការលំបាកយ៉ាងខ្លាំងដោយកង្វះខាតព័ត៌មានស្ថិតិដែលអាចទុកចិត្តបាន។ នេះជាការពិត ជាពិសេសសម្រាប់តម្រូវការការងារដែលទាក់ទងទៅនឹងមុខរបរអាទិភាពរបស់ TVET ដែលជាការពិតបានផ្តល់ឱ្យកម្រិតការងារពួកគេនូវទំហំតូច ហើយមិនត្រូវបានវាស់ដោយការស្ទង់មតិសេដ្ឋកិច្ចសង្គមទេ ហើយក៏មិនមានព័ត៌មានដែលអាចរកបានដែរ។

ចំពោះអ្វីដែលទាក់ទងនឹងសេណារីយ៉ូ ឬប្រភេទនៃការគ្រោងទុក និងការព្យាករណ៍នានាក្នុងប្រទេសកម្ពុជាកំពុងបាត់នូវព័ត៌មានមូលដ្ឋានដែលជាធម្មតា ត្រូវបានផ្តល់ដោយការស្ទង់មតិកម្លាំងពលកម្មដែលតំណាងឱ្យប្រភពដែលមិនអាចខ្វះបានសម្រាប់ការវិភាគទីផ្សារការងាររយៈពេលមធ្យម។ កង្វះទិន្នន័យទាំងនេះបង្កើតឱ្យមានការអនុវត្តនីតិវិធីស្មុគស្មាញ ដើម្បីប៉ាន់ស្មានពីទិន្នន័យដែលបាត់ហើយបន្ទាប់មកនឹងមានទិន្នន័យប្រកបដោយភាពជឿជាក់ និងមានកំណត់។ វាក៏ត្រូវគូសបញ្ជាក់ផងដែរថា ការបោះពុម្ពផ្សាយទិន្នន័យជំរឿននឹងមិនអាចដោះស្រាយបញ្ហាបានទេ ដោយសារការពន្យារពេលផ្សព្វផ្សាយដែលជាការពិតពួកគេប្រហែលជាមានបញ្ហាមួយចំនួនជាមួយព័ត៌មានដែលមាន ហើយនឹងអាចរកបានតែរៀងរាល់ ១០ឆ្នាំ។

វាក៏ត្រូវគូសបញ្ជាក់ផងដែរថា ប្រព័ន្ធអប់រំជាន់ខ្ពស់ទទួលរងពីបញ្ហាដែលព័ត៌មានស្ថិតិសំដៅទៅលើសកម្មភាពរដ្ឋបាល និងមិនមែនសម្រាប់និស្សិតដែលចាំបាច់ត្រូវបន្តដោយការស្មាននៅពេលដែលព្យាយាមផ្តល់ចម្លើយចំពោះសំណួរសាមញ្ញដូចជា តើមាននិស្សិតប៉ុន្មាននាក់បានចុះឈ្មោះ ឬបានបញ្ចប់ការសិក្សា? ចុងបញ្ចប់ស្ថិតិនៃការអប់រំខ្ពស់របស់ TVET បច្ចុប្បន្នមិនផ្តល់ព័ត៌មានអំពីចំនួនអ្នកចុះឈ្មោះចូលរៀន និងបញ្ចប់ការសិក្សាដោយមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់ (Department) នោះទេ។

សរុបសេចក្តីមក ដើម្បីធ្វើការវិភាគលើទីផ្សារការងាររយៈពេលមធ្យម និងរយៈពេលវែង វាចាំបាច់ណាស់ដែលវិទ្យាស្ថានជាតិស្ថិតិកម្ពុជា នឹងធ្វើការស្ទង់មតិលើកម្លាំងពលកម្មជាប្រចាំដែលក្រសួង និងគ្រឹះស្ថានទាំងអស់ត្រូវទទួលយកចំណាត់ថ្នាក់មុខរបរដែលប្រកបដោយស្តង់ដា។ ទន្ទឹមនឹងនេះ ការិយាល័យស្ថិតិនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរតែអនុវត្តការប្រមូលព័ត៌មានឱ្យបានហ្មត់ចត់ និងពេញលេញជាងមុនស្តីពីការចុះឈ្មោះ និងបញ្ចប់ការសិក្សាពីគ្រប់កម្រិតនៃវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈទាំងអស់។

កង្វះខាតជំនាញ និងការស្ទង់មតិគម្លាតជំនាញ គឺមានសារៈសំខាន់ខ្លាំងណាស់ ប៉ុន្តែបង្ហាញពីដែនកំណត់ដែលមានតម្លៃថ្លៃ ហើយមានអាយុចាស់នៅពេលពួកគេបញ្ចប់ការស្រាវជ្រាវ។ ជម្រើសត្រឹមត្រូវមួយ ដើម្បីស្វែងយល់ពីការបម្រែបម្រួលរយៈពេលខ្លីនៃតម្រូវការសម្រាប់មុខរបរជាក់លាក់ និងនិន្នាការផ្គត់ផ្គង់ត្រូវបានផ្តល់ដោយទិន្នន័យរដ្ឋបាលដែលអាចត្រូវបានប្រមូលដោយ NEA និង DLMI ដែលជាលទ្ធផលនៃសកម្មភាពរបស់ពួកគេ។ NEA អាចផ្តល់ទិន្នន័យជាចម្បង ប៉ុន្តែមិនត្រឹមតែផ្នែកតម្រូវការប៉ុណ្ណោះទេ DLMI នៅតែជាផ្នែកផ្គត់ផ្គង់ទិន្នន័យផងដែរ។ យើងដឹងថាទាំង NEA និង DLMI កំពុងធ្វើការ ដើម្បីកសាងប្រព័ន្ធព័ត៌មានរបស់ពួកគេ ប៉ុន្តែយើងមិនដឹងពីការខិតខំប្រឹងប្រែងក្នុងការសម្របសម្រួលការប្រមូលព័ត៌មានឆ្ពោះទៅរកគោលដៅរួមនោះទេ។

លើសពីនេះទៅទៀត វាហាក់ដូចជាសមស្របក្នុងការធ្វើការស្ទង់មតិតាមពេលវេលា (ត្រីមាស រៀងរាល់ឆ្នាំ) អំពីតម្រូវការកម្លាំងពលកម្មតាមមុខរបរ ដោយធ្វើការសាកសួរសំណួរដោយប្រើការសម្ភាសន៍តាមរយៈទូរស័ព្ទ កុំព្យូទ័រ (Computer Aided Telephone Interview-CoCATI) ឬសម្ភាសន៍ដោយមានជំនួយកុំព្យូទ័រតាមបណ្តាញអ៊ីនធឺណេត (Computer Aided Web Interview-CAWI) សូមពិនិត្យមើលលម្អិតតាមគេហទំព័រ៖

https://excelsior.unioncamere.net/images/metodologia /Nota_ Metodologica.pdf

ចុងបញ្ចប់ត្រូវគួសបញ្ជាក់ថា ការវិភាគអំពីកង្វះជំនាញ និងកិច្ចខិតខំប្រឹងប្រែង ដើម្បីព្យាករណ៍ពីតម្រូវការការងារ និងដើម្បីបង្កើតសេណារីយ៉ូត្រូវបានអនុវត្តដោយមានការគាំទ្រពីអ្នកជំនាញបរទេស ដែលជាទូទៅវាត្រូវបានទាមទារឱ្យបណ្តុះបណ្តាលមន្ត្រីក្នុងក្រសួង និងផ្តល់នូវសមត្ថភាពចាំបាច់ ដើម្បីអនុវត្តលើការវិភាគនាពេលអនាគត។

ទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំដែលផ្អែកលើបទពិសោធន៍ផ្ទាល់ គឺថាការខិតខំបែបនេះនឹងត្រូវបរាជ័យបើទោះជាមានការប្តេជ្ញាចិត្ត តាំងចិត្ត និងឆន្ទៈរបស់សិក្ខាកាមដើម្បីរៀនក៏ដោយ។ មូលហេតុដំបូង និងសំខាន់បំផុត គឺថាមានមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តិចណាស់ដែលបានសិក្សាផ្នែកសេដ្ឋកិច្ច (នេះមិនបានផ្តោតលើការអនុវត្តក្នុងវិស័យសេដ្ឋកិច្ច និងសេដ្ឋកិច្ចស្តីពីការងារ) និងស្ថិតិ។ បញ្ហាទី២ គឺដោយសារតែការសិក្សាពីមុន និងសកម្មភាពការិយាធិបតេយ្យ ពួកគេខ្វះការស្រាវជ្រាវ "ចិត្តគំនិត" បញ្ហាដែលត្រូវបានផ្សំដោយការពិតដែលថាពួកគេបន្តអនុវត្តសកម្មភាពការិយាធិបតេយ្យប្រចាំថ្ងៃដែលមិនមានទំនាក់ទំនង ឬគ្រាន់តែភ្ជាប់ទំនាក់ទំនងតិចតួចទៅនឹងការស្រាវជ្រាវវិទ្យាសាស្ត្រនោះទេ។ ជាចុងក្រោយ ពួកគេជាសមាជិកនៃការិយាធិបតេយ្យដ៏ស្មុគស្មាញនៅខាងក្នុង ដែលពួកគេសង្ឃឹមថានឹងឈានទៅកាន់មុខតំណែងខ្ពស់ និងប្រសើរជាងមុនមិនចាំបាច់ស្របតាមសកម្មភាពដែលពួកគេទទួលបានការបណ្តុះបណ្តាលនោះទេ។

ដើម្បីឱ្យមានភាពងាយស្រួល មិនអាចទៅរួចទេក្នុងការហ្វឹកហាត់ក្នុងរយៈពេល ពីរបីសប្តាហ៍ ឬសូម្បីតែពីរបីខែមនុស្សដែលមិនមានប្រវត្តិនៅក្នុងសកម្មភាពស្រាវជ្រាវសំខាន់ៗ និងស្មុគស្មាញដែលត្រូវការការសិក្សា និងការអនុវត្តជាច្រើនឆ្នាំ។ ម្យ៉ាងវិញទៀត ទោះបីវគ្គបណ្តុះបណ្តាលនេះទទួលជោគជ័យក៏ដោយក៏គ្មានយន្តការណាមួយធានាថាអ្នក

ដែលបានបណ្តុះបណ្តាលនឹងបន្តប្រើប្រាស់សមត្ថភាពដែលទទួលបានដើម្បីវិភាគទីផ្សារការងារនៅក្នុងក្រសួងក្នុងរយៈពេលជាក់លាក់ណាមួយនោះទេ។

សរុបសេចក្តីមក ដើម្បីទទួលបានប្រព័ន្ធទីផ្សារការងារដែលចាំបាច់ក្នុងការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវការអ្នកអង្កេតទីផ្សារការងារដែលអាចជាស្ថាប័នឯករាជ្យដែលបង្កើតឡើង ដោយបង្កើតអ្នកជំនាញដែលមានកំណត់មួយចំនួន ហើយពួកគេមានសាវតាសិក្សាចាំបាច់ និងមានការយកចិត្តទុកដាក់ក្នុងការអនុវត្តការងាររបស់ពួកគេ។

## ផែនការសកម្មភាព

ដើម្បីធ្វើការអនុវត្តសេចក្តីណែនាំគោលនយោបាយមុនៗ នឹងត្រូវប្រតិបត្តិការជាជំហានៗដូចខាងក្រោម៖

ក). ដើម្បីធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃប្រព័ន្ធអប់រំ និងបង្កើនកម្រិតអប់រំជាមធ្យមនៃការចាកចេញពីដំណាក់កាលបណ្តុះបណ្តាលចាំបាច់៖

- ដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សា
- លើកកម្ពស់គុណភាពគ្រូ និងការបង្រៀន
- ដើម្បីផ្តល់សំណាញ់សុវត្ថិភាពសម្រាប់ការបោះបង់ការសិក្សា។

ដើម្បីឈានដល់គោលដៅសំខាន់ទាំងនេះ ចាំបាច់ដើម្បីទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនាពេលអនាគត និងរៀបចំឱ្យសិស្សចាកចេញពីប្រព័ន្ធសាលារៀន ដើម្បីទទួលបានជំនាញវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរតែបង្កើតក្រុមការងាដែលនឹង៖

- រៀបចំការស្រាវជ្រាវលើដើមហេតុនៃការបោះបង់ការសិក្សា និងកំណត់តំបន់ភូមិសាស្ត្រដែលរងផលប៉ះពាល់ច្រើនបំផុតពីបញ្ហានេះ។
- ផ្តល់ការត្រួតពិនិត្យសមត្ថភាពជំនាញរបស់បុគ្គលិកបង្រៀន។
- កំណត់វិធីល្អបំផុតដើម្បីរៀបចំសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានណែនាំដល់និស្សិតវ័យក្មេងដែលបានបោះបង់ចោលការសិក្សាមុនពេលបញ្ចប់ការសិក្សាមូលដ្ឋាន ហើយមានគោលបំណងដើម្បីបញ្ចប់ការអប់រំមូលដ្ឋានរបស់ពួកគេ និងផ្តល់ឱ្យពួកគេនូវជំនាញចាំបាច់ដើម្បីបន្តអាជីព។ វិធានការណ៍នេះគួរតែរួមបញ្ចូលទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់គ្រួសារកុមារ និងសម្រាប់កុមារខ្លួនឯង ព្រោះមូលហេតុចម្បងនៃការបោះបង់ការសិក្សា គឺភាពក្រីក្រ។
- កំណត់សកម្មភាពបណ្តុះបណ្តាល និងធ្វើការបណ្តុះបណ្តាលឡើងវិញទៅដល់គ្រូដែលមានសមត្ថភាពមិនគ្រប់គ្រាន់ដោយប្រើបុគ្គលិកដែលមានសមត្ថភាពបំផុត និងបច្ចេកវិទ្យាទំនើបដូចជាការរៀនសូត្រពីចម្ងាយ។

ខ). កំណត់ ពង្រីកតួនាទី និងសកម្មភាពរបស់ TVET នេះ គឺជាគោលដៅស្មុគស្មាញដែលគួរតែត្រូវបានអនុវត្តដោយថ្នាក់ដឹកនាំកំពូលនៃក្រសួងដែលគាំទ្រដោយក្រុមការងារដែលអាចប្រមូលករណីសិក្សា និងការបំផុសគំនិតពីអ្វីដែលបានធ្វើនៅក្នុងអាស៊ានផ្សេងទៀត ប៉ុន្តែជាពិសេសបណ្តាប្រទេសសហភាពអឺរ៉ុបដែលបញ្ហាទាំងនេះត្រូវបានពិភាក្សា និងប្រឈមជាង ៤០ឆ្នាំមកហើយ។ គោលដៅគួរតែជាការប្រៀបធៀបតួនាទីខុសគ្នាដែលការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដើរតួនៅក្នុងប្រទេសផ្សេងៗគ្នានៅដំណាក់កាលអភិវឌ្ឍន៍ផ្សេងៗគ្នា។ លទ្ធផលគួរតែជាចក្ខុវិស័យពេញលេញ

និងស្មុគស្មាញបន្ថែមទៀតនៃតួនាទីដែលការបណ្តុះបណ្តាលវិជ្ជាជីវៈអាចដើរតួសម្រាប់ក្រុមអាយុខុសគ្នា (កុមារក្នុងវ័យទទួលការអប់រំមូលដ្ឋាន សិស្សលើសអាយុក្នុងការទទួលការអប់រំមូលដ្ឋាន មនុស្សក្នុងក្រុមអាយុវ័យកណ្តាល ប៉ុន្តែក៏ជាកម្មករវ័យចំណាស់) អ្នកធ្វើការនៅក្នុងវិស័យមួយចំនួនធំរួមមានវិស័យកសិកម្ម និងស្ថានភាពផ្សេងៗគ្នា (អ្នកស្វែងរកការងារដំបូង អ្នកគ្មានការងារធ្វើ អ្នកមានការងារធ្វើដែលចង់ស្វែងរកអាជីពផ្សេង និងកម្មករដែលមានសមត្ថភាពហួសសម័យ)។

គ). ធ្វើការសម្របសម្រួលគោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហគ្រាសៈ តម្រូវការបណ្តុះបណ្តាលមិនត្រឹមតែត្រូវបានកំណត់ដោយនិន្នាការសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែក៏ជាលទ្ធផលនៃគោលនយោបាយអភិវឌ្ឍន៍ និងឧស្សាហកម្មផងដែរ។ ផលប៉ះពាល់ គឺថាជាផែនការឧស្សាហកម្ម និងផែនការបណ្តុះបណ្តាលវិជ្ជាជីវៈគួរតែត្រូវបានបង្កើតជាមួយគ្នា ព្រោះប្រភេទនៃការអភិវឌ្ឍឧស្សាហកម្មនឹងត្រូវការការបណ្តុះបណ្តាលជាក់លាក់មួយខណៈពេលដែលលទ្ធផលនៃការបណ្តុះបណ្តាលដែលបានផ្តល់អាចជាការលើកទឹកចិត្តត្រឹមត្រូវ ដើម្បីកំណត់ច្រកអភិវឌ្ឍន៍ជាក់លាក់មួយ។

ឃ). លើកកម្ពស់ការប្រមូលទិន្នន័យស្តីពីការងារៈ ក្រសួងការងារ និនងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរតែដើរតួនាទីយ៉ាងសកម្មក្នុងការជំរុញការអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ នៃការស្ទង់មតិកម្លាំងពលកម្មជាបន្តបន្ទាប់។

ង). ធ្វើការបង្កើតអ្នកឃ្លាំមើលទីផ្សារការងារឯករាជ្យ - ដោយបង្កើតអ្នកសង្កេតការណ៍ទីផ្សារការងារឯករាជ្យ (ឬអ្នកសង្កេតការណ៍សេដ្ឋកិច្ច) - តាមគំនិតរបស់ខ្ញុំដំណោះស្រាយដែលសមហេតុផល និងមិនសូវថ្លៃចំពោះបញ្ហានៃការប្រមូលទិន្នន័យ និងប្រព័ន្ធទីផ្សារការងារដែលគួរតែពិចារណាឱ្យបានហ្មត់ចត់។ អ្នកឃ្លាំមើលទីផ្សារការងារគួរតែទទួលបន្ទុកប្រព័ន្ធព័ត៌មានទីផ្សារការងារ ធ្វើការប្រមូល និងរៀបចំទិន្នន័យពីការិយាល័យស្ថិតិ និងពីក្រសួងផ្សេងៗដែលគាំទ្រដោយ NEA និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការប្រមូលព័ត៌មានស្តីពីលំហូរទីផ្សារការងារ និងសកម្មភាព TVET គាំទ្រដល់និយមន័យនៃវិធីសាស្ត្រទំនើបបន្ថែមទៀត ដើម្បីប្រមូលព័ត៌មានស្តីពីតម្រូវការការងារតាមមុខរបរ និងគម្លាតជំនាញ។

# ឯកសារយោង


ADB. 2015. Cambodia: Addressing the skills gap. Mandaluyong City, Philippines.

Bruni Michele. 1988. A stock flow model to analyse and forecast labor market variables. Labour, n.1.

Bruni Michele. 1993. Per una economia delle fasi della vita. in Italian Statistical Association, Popolazione, tendenze demografiche e mercato del lavoro, Rome.

Bruni Michele. 2017. Egypt Labour market report. Demographic trends, labour market evolution and scenarios for the period 2015-30. International Organization for Migration, Cairo.

Bruni Michele. Likanan Ljuch and Somena Kuoch. 2013. Skill shortages and skills gaps in the Cambodian labour market: Evidence from employer skills needs survey. ILO Asia-Pacific Working Paper Serie; ILO Bangkok.

Cambodia Socio-economic Survey 2013. 2014. National Institute of Statistics, Ministry of Planning.

Cambodia Socio-economic Survey 2014. 2015. National Institute of Statistics, Ministry of Planning.

Cambodia Socio-economic Survey 2015. 2016. National Institute of Statistics, Ministry of Planning.

Cambodia Socio-economic Survey 2016. 2017. National Institute of Statistics, Ministry of Planning.

Cambodia Socio-economic Survey 2017. 2018. National Institute of Statistics, Ministry of Planning.

Education Statistics and Indicators. Ministry of Education, Youth and Sport. EMIS.

ILO. 2016. Cambodia Garment and Footwear Sector Bulletin. Issue 3.

Ministry of Economy and Finance. 2019. Budget in Brief. Fiscal year 2019.

Ministry of Labor and Vocational Training. 2017. National Technical Vocational Education and Training Policy 2017-2025.

National Employment Agency. 2015. Skills Shortages and Skills Gaps in the Cambodian Labour Market: Evidence from Employer Skills Needs Survey 2014. Phnom Penh.

National Employment Agency. 2016. Skills Shortages and Skills Gaps in the Cambodian Labour Market: Evidence from Employer Skills Needs Survey 2015. Phnom Penh.

National Employment Agency. 2017. Labor Demand Forecasts 2017-2021. Phnom Penh.

National Employment Agency. 2018. Skills Shortages and Skills Gaps in the Cambodian Labour Market: Evidence from Employer Skills Needs Survey 2017. Phnom Penh.

Phann Dalis. 2014. Links between Employment and Poverty in Cambodia, CDRI Working Paper Series No. 92.

Royal Government of Cambodia. 2015. Cambodia Industrial Development Policy 2015-2025.

UNDP Cambodia. 2014. Competitiveness and Linkages in Cambodia’s Manufacturing Sector. Discussion Paper No. 12.

United Nations. Department of Economic and Social Affairs. 2019. World Population Prospects. The 2019 Revision. Highlights, United Nations, New York.

World Bank. 2019a. Cambodia’s Future Jobs: Linking to the Economy of Tomorrow.

World Bank Group. 2019b. Cambodia Economic Update.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ និន្នាការប្រជាសាស្ត្រ

## ១. សាចតានៃប្រជាសាស្ត្រក្នុងរយៈពេលវែង

### ១.១. ការផ្លាស់ប្តូរប្រជាសាស្ត្រ ពេលវេលា និងផលប៉ះពាល់

នៅចន្លោះឆ្នាំ១៩៥០ និងឆ្នាំ២០១៥ ប្រជាជនកម្ពុជាបានកើនឡើងពី ៤.៤លាននាក់ ទៅ ១៥.៥លាននាក់ ទោះបីមានការធ្លាក់ចុះក្នុងរបបខ្មែរក្រហមក៏ដោយ។ យោងតាមការព្យាករណ៍របស់នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម របស់អង្គការសហប្រជាជាតិ (UNDESA ឆ្នាំ២០១៩) ក្នុងសេណារីយ៉ូនៃការគ្មានចំណាកស្រុក (Zero-migration) ប្រជាជនកម្ពុជានឹងកើនដល់ ២៣លាននាក់នៅឆ្នាំ២០៥០ អតិបរមាស្មើរតែ ២៥លាននាក់នៅឆ្នាំ២០៨០ ហើយ បន្ទាប់មកថយចុះបន្តិចក្នុងអំឡុងពេល ២០ឆ្នាំក្រោយ។

**រូបភាពទី១.១. ចំនួនប្រជាជនចាប់ពីឆ្នាំ១៩៥០-២១០០ (គិតជាខ្ទង់ពាន់) ឆ្នាំជ្រើសរើសរវាងឆ្នាំ១៩៥០ និងឆ្នាំ២១០០**




*ប្រភព៖ Elaboration on UN DESA estimates 1950–1955 to 2010–2015 and forecast (zero migration scenario) 2015–2020 to 2095–2100; UN DESA, 2019.*

## ១.២. មរណភាព ការបន្តកំណើត និងតុល្យភាពធម្មជាតិ

